តៅ ហ៊ឹង

# ភាសិតសំរាយ



* ដំបូន្មាន

* ឱវាទ

សំរាប់ជនប្រុសស្រីត្រូវត្រាប់

www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅ " **ភាសិតសំរាយ** " នេះខ្ញុំបានចាប់ផ្តើមសរសេរតាំងពីឆ្នាំ ១៩៥០មក គឺកាលដែលខ្ញុំនៅធ្វើជាសាស្ត្រាចារ្យក្នុងអនុវិទ្យាល័យបាត់ដំបងនៅឡើយ ។ កាលគ្រានោះ ខ្ញុំបានពិនិត្យឃើញថាសិស្សានុសិស្សភាគច្រើន ចាប់តាំងពីថ្នាក់ទី៥ ដល់ទី ៣ ទំនើបជាតិនៅវិទ្យាល័យ និងអនុវិទ្យាល័យនានាមានសេចក្តីលំបាកពេក ក្នុងការអធិប្បាយសំរាយភាសិតខ្មែរ ។ ដូច្នេះហើយខ្ញុំក៏មានឧត្តមគតិមួយ ឆ្លៀតសរសេរសៀវភៅនេះ ដើម្បីណែនាំសិស្សដែលពុំសូវស្ទាត់ជំនាញខាងរបៀបសរសេរខ្មែរ ឲ្យមានគំនិតថ្មីៗ ប្លែកៗ ថែមទៀត ហើយនឹងស្គាល់ទំនងតែងខ្លះក្នុងការពន្យល់ភាសិត ។

សៀវភៅ " **ភាសិតសំរាយ** " នេះ ខ្ញុំបានរៀបរៀងតាមកម្មវិធីនៃការសិក្សា នៅថ្នាក់ទី ៣ ទំនើបជាតិ កាលជំនាន់នោះ គឺមានភាសិតដែលបានស្រង់យកពី " **ច្បាប់កេរ្តិ៍កាល ច្បាប់ពាក្យចាស់ ច្បាប់ក្រមទៅ** " និងភាសិតផ្សេងៗ ដែលបុព្វាចារ្យយើងបានចងក្រងទុកមក ព្រមទាំងមានសេចក្តីខ្លះដែលខ្ញុំបានស្រង់ពីសៀវភៅ **គតិលោក** " និង " **សុភាសិត** " ។

ក្នុងការពន្យល់ភាសិតនេះ ខ្ញុំមានបង្ហាញទំនងតែង និងការបែងសេចក្តីវគ្គជាភាគ ហើយមានបញ្ចូលសេចក្តីអធិប្បាយជាគំរូខ្លះដែរ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា សេចក្តីអធិប្បាយទាំងនេះ សំរាប់តែសិស្សថ្នាក់ទី ៣ ទំនើបចុះមកក្រោមប៉ុណ្ណោះទេ ។

ម្យ៉ាងទៀតដោយគំនិតរបស់មនុស្សក្នុងលោកប្លែកៗគ្នានោះ ខ្ញុំមានសេចក្តីបារម្ភណាស់ក្រែងយោបល់របស់ខ្ញុំ មិនស្របតាមយោបល់របស់អស់

www.elibraryofcambodia.org

លោកអ្នក ប៉ុន្តែបើមានសេចក្ដីខ្លះផ្គាំផ្គង មិនសមហេតុផល មិនស៊ីគ្នានិងន័យរបស់ភាសិត ឬក៏មានខ្វះសេចក្ដីត្រង់ណាក្ដី ដែលខ្ញុំមើលមិនឃើញ គិតមិនដល់នោះ ខ្ញុំសូមថ្លែងអំណរគុណជាមុន ចំពោះលោកអ្នក ដែលមេត្តាជួយតម្រែតម្រង់រំឭកខ្ញុំ ដើម្បីនឹងឲ្យខ្ញុំថែមថយសេចក្ដីខ្លះបានដល់ពេលបោះពុម្ពលើកក្រោយទៀត ។

សៀមរាប, ថ្ងៃទី ១០ ធ្នូ ឆ្នាំ 1968

**តៅ ហ៊ុខ**

**សំគាល់** : ខ្ញុំបានសម្រួលពាក្យពេចន៍ និងឧទាហរណ៍ខ្លះ ក្នុងការបោះពុម្ពលើកនេះ ដោយហេតុឧទាហរណ៍ខ្លះដែលបានសរសេរបញ្ជាក់ន័យរបស់ភាសិត តាំងពីឆ្នាំ ១៩៥០មកនោះ វាហួសកាលសម័យទៅហើយ ។

www.elibraryofcambodia.org

# របៀបពន្យល់ភាសិត

*ដើម្បីនឹងពន្យល់ភាសិតឲ្យបានល្អ :*

ក. ត្រូវអានភាសិតនោះដោយប្រុងប្រយ័ត្ន ដើម្បីឲ្យជ្រួតជ្រាបច្បាស់នូវន័យរបស់ភាសិត

ខ. ក្នុងសេចក្ដីផ្ដើមត្រូវចុះសេចក្ដីនៃភាសិតទាំងមូលដោយប្រាប់ឲ្យច្បាស់លាស់ តើភាសិតនោះ គេស្រង់យកពីក្នុងសៀវភៅណាមក ឬក៏ជាភាសិតរាយរងដែលតែងតែឮគេពោលតៗមក។

គ. ឯការពន្យល់ន័យរបស់ភាសិតមានពីរយ៉ាងគឺ :

១-បើជាភាសិតមានសេចក្ដីត្រង់ៗទេ នោះគ្រាន់តែស្រាយន័យឲ្យបានធំទូលាយដើម្បីឲ្យស្ដាប់បានស្រួល

២-បើជាបញ្ហាបញ្ឆិតបញ្ឆៀងវិញ នោះត្រូវពន្យល់ន័យតាមអត្ថានុរូបរបស់ភាសិត(គឺអធិប្បាយតាមសេចក្ដីដើមនៃសុភាសិត) រួចហើយពន្យល់ន័យតាមអត្ថបដិរូបទៀត (គឺពន្យល់តាមសេចក្ដីលំរៀងដែលជាខ្លឹមសាររបស់ភាសិត) ព្រោះភាសិតទាំងឡាយនេះ បុរាណបណ្ឌិត បានចងក្រងទុកមកដោយមានការពិនិត្យមើលសភាវៈ ឬកិរិយានៃវត្ថុក្នុងធម្មជាតិ ហើយយកមកប្រៀបធៀបនឹងឥរិយាបថនៃមនុស្សក្នុងសង្គម។

ឃ.លុះពន្យល់ន័យរបស់ភាសិតហើយ គប្បីរើសរកឧទាហរណ៍ ដែល



www.elibraryofcambodia.org

ប្រទះឃើញក្នុងជីវភាពនៃមនុស្សជាតិ ឬរកឧទាហរណ៍ខ្លះក្នុងសៀវភៅរឿងនានា ដែលបានអានមកហើយ ដើម្បីបញ្ជាក់ន័យភាសិតនោះឲ្យរឹតតែក្បោះក្បាយពិស្តារឡើងទៀត។

ង. លុះពន្យល់ន័យរបស់ភាសិតហើយ កាលបើឃើញថាភាសិតណាមួយមានសេចក្ដីខ្លះមិនសមហេតុផល តាមកាលៈទេសៈយើងអាចនឹងអធិប្បាយទទឹងជំទាស់នឹងសេចក្ដីនោះបាន ដើម្បីបំផុសឲ្យឃើញថាចរិយារបស់មនុស្សលោកមិនចេះតែស្របតាមសេចក្ដីទូន្មាននៃភាសិតរាបទេ។ តែត្រូវចាំឲ្យច្បាស់ថា សុភាសិតទាំងឡាយមិនដែលមានសេចក្ដីខុសស្រឡះទាំងអស់ឡើយ គង់នឹងមានកន្លែងខ្លះល្អមយកជាគតិបាន។

ច. ក្នុងសេចក្ដីបញ្ចប់ត្រូវបង្ហាញខ្លឹមសាររបស់ភាសិត ត្រូវបំផុសឲ្យឃើញសីលធម៌គឺសេចក្ដីទូន្មាន និងគតិល្អ ដែលជាគន្លងបំភ្លឺមហាជនធ្វើដំណើរទៅមុខយ៉ាងស្រួលឥតប៉ះទង្គិចនិងឧបសគ្គផ្សេងៗ។



www.elibraryofcambodia.org

ក្នុងការធ្វើអ្វីមួយ ត្រូវធ្វើឲ្យមានព្រំដែន គឺកុំធ្វើឲ្យជ្រុលពេកកុំធ្វើឲ្យហួសកម្លាំងទ្រព្យរបស់ខ្លួន ព្រោះការសប្បុរសហួសប្រមាណនេះរមែងតែងធ្វើអោយ"**ចាញ់ធន**" គឺឲ្យវិនាសរលោះទ្រព្យសម្បត្តិមិនខាន ដោយការចំណាយក្នុងផ្លូវសប្បុរសវាច្រើនជាងចំណូលធម្មតា ។

សេដ្ឋីដែលមានរាប់រយលានប្រាក់ ក៏គង់នឹងរលាយឃ្លាំងទ្រព្យទៅបាន កាលបើចេះតែសប្បុរសហួសកំរិតឥតពិចារណា ។

*__វគ្គទី ២__* : **នានុរជនចាញ់ឥន្ទ្រីយ៍**

"ទុរជន" គឺជនដែលមានចិត្តអាក្រក់ ។ ជនទុច្ចរិតគ្រប់ឋានៈ ចោរខ្មាំងទាំងឡាយ ជនដែលមានចិត្តសាហាវក្នុងការលបលួចធ្វើឃាតកម្មឬវិនាសកម្មផ្សេងៗ លោកចាត់ថាជាពួកទុរជនទាំងអស់ ។ តាមសេចក្តីភាសិតនេះ គេរាប់ជាពួកទុរជនដែរ ជនណាដែលកំណាញ់កាញ់សម្បត្តិទុក មានចិត្តអាក្រក់ឥតមេត្តា ករុណា ដល់អ្នកកំសត់ទុគ៌ត ផ្ទុយគ្នាពីពួកសប្បុរសជន ។

"**ចាញ់ឥន្ទ្រីយ៍**" គឺអាប់ឱនវិនាសអន្តរាយដល់រូបរាងកាយរបស់ឯង ។ ជនចិត្តអាក្រក់ជាទីគំនុំ ជាទីសំអប់នៃអ្នកដទៃ វារមែងតែងសៅហ្មង ឬវិនាសដល់ខ្លួនវា ។ គេតែងលបលួចកាប់សម្លាប់ជនទាំងនេះឥតប្រណី ។ជនដែលល្បីថាចេះធ្មប់អាប ពួកចោរព្រៃទាំងឡាយនោះ នឹងត្រូវគេចាប់ធ្វើបាបវាយដំច្រំផាក់ ឬប្រហារជីវិតចោលក៏មាន ។ ពួកជនទុច្ចរិត នឹងត្រូវរាជការដាក់ទោសផ្ដន្ទាទាវាឲ្យរាងចាល ។ ជនអ្នកកំណាញ់ពិតមែនតែមិនធ្វើទុក្ខទោសដល់គេ តែដោយហេតុចិត្តខ្មៅក្រៅតម្រា



www.elibraryofcambodia.org

នោះ គេតែងតែស្អប់ ប្រមាថមើលងាយដោយអាការៈផ្សេងៗសេចក្ដីអាប់ឱនដល់ខ្លួនក៏កើតឡើងដែរ ។ ផលអាក្រក់គ្រប់បែបដែលធ្លាក់ដល់ទៅលើពួកទុរជននេះហើយ ហៅថា"**ទាញ់ឥន្ទ្រីយ៍**" ឬសៅហ្មងដល់ខ្លួន ឬវិនាសខ្លួននោះឯង ។

ឯពួកទុរជនមានឧបមេយ្យដូចសត្វសង្កើច ឬសត្វដែលខាំចុចគេឲ្យបានក្ដីឈឺចាប់ តែមិនរួចពីគេទះសម្លាប់ឡើយ ។ ពួកមនុស្សទោសនៅក្នុងពន្ធនាគារ ដែលនឿយកាយបាយមិនឆ្ងាញ់គ្រប់វេលា នេះជាពួកទុរជនដែលកំពុងទទួលកម្មអាក្រក់លើអាត្មាវិញ ពោលគឺ "**ឥន្ទ្រីយ៍**" របស់គេកំពុង "**ទាញ់**" ។

**សេចក្ដីបញ្ចប់**

ការធ្វើទានត្រូវលៃឲ្យល្មមសមរម្យនឹងធនធាន ។ កុំភ្លេចឲ្យសោះពាក្យចាស់លោកថា "**ចិត្តល្អក្រខ្លួន**" ។ "**ចិត្តល្អឥតរើគិតកុំមានចិត្តអាក្រក់**" នេះហើយដែលអ្នកប្រាជ្ញចង់ទូន្មាន ។

## ២-"ឈើផ្លែច្រើនចាញ់ស្លឹក ត្រីច្រើនទឹកល្អក់ពុំជា"

## ទំនងតែង

**សេចក្ដីផ្ដើម :**

ភាសិតទាំងឡាយដែលនឹងចងក្រងឡើងបានទុកជាកេរ្តិ៍តំណែតកប្បកល្ប ក៏មកពីអ្នកប្រាជ្ញរកឃើញសេចក្ដីពិតដោយលោកស្គាល់ការសាកពិសោធន៍យ៉ាងល្អិតល្អន់ ក្នុងរបៀបរស់នៅនៃសង្គម ដោយមាន



www.elibraryofcambodia.org

ការសង្កេតមើលលក្ខណៈនៃវត្ថុក្នុងធម្មជាតិ ហើយយកទៅប្រៀបធៀបនឹងលក្ខណៈកិរិយានៃមនុស្សក្នុងលោកដូចយ៉ាងក្នុងច្បាប់កេរ្តិ៍កាល លោកថែងមកថា : " **ឈើផ្លែច្រើនចាញ់ស្លឹក ត្រីច្រើនទឹកល្អក់ពុំជា** "

*__អត្ថាធិប្បាយរបស់ភាសិត__*

*__វគ្គទី១__* : **ឈើផ្លែច្រើនចាញ់ស្លឹក**

ឈើណាដែលមាន " **ផ្លែច្រើន** " នោះស្លឹកវាតែងវិនាស ។ ពីព្រោះអ្វី? គឺកាលបើគេឃើញឈើនេះមានផ្លែច្រើនហើយ គេនាំគ្នាចង់បានផ្លែនោះដោយគ្រវែងនឹងដុំថ្ម ឬដំបង ថ្កក់មួលយកទាំងស្លឹកឬអង្រួនមែកឬកាប់យកទាំងមែកដើម្បីនិងប្រឡេះយកផ្លែឲ្យបានស្រួល ជាហេតុបណ្តាលឲ្យស្លឹកឈើដែលជាទីជំរកនៃផ្លែនេះ រុះរោយវិនាសព្រោះតែផ្លែច្រើន ។

*__វគ្គទី២__* : **ត្រីច្រើនទឹកល្អក់ពុំជា**

ទីណាដែលមាន " **ត្រីច្រើន** " ទឹកនោះនឹងល្អក់ខ្វល់ ។ ពីព្រោះអ្វី? គឺកាលបើគេឃើញមានត្រីច្រើនហើយ គេក៏ចង់បានត្រីនោះដោយនាំគ្នាទៅចាប់ ទៅដួស ទៅបង់ ទៅត្រង់ ដាក់ទ្រូ ដាក់លប ជញ្ជូត់ ឬវាយទឹកដេញត្រីបញ្ចូលសិង ជាហេតុបណ្តាលឲ្យទឹកនោះ ដែលជាទីជំរកនៃត្រីទៅជាល្អក់ខ្វល់អស់ ព្រោះតែត្រីច្រើន ។

*__អត្ថបដិរូបរបស់ភាសិត__*

បញ្ហាទាំងពីរវគ្គនេះបានសេចក្តីថា : ជនណាដែលមានទ្រព្យធន



www.elibraryofcambodia.org

ច្រើនតែងជួបប្រទះនឹងការអន្តរាយច្រើនប្រការ ព្រោះទ្រព្យធននេះតែងទាញចិត្តពួកពាល ឬចោរកំណាចឲ្យចង់បានឥតបីស្រាក វិស័យដូចគេប្រាប់ថាផ្លែឈើ ឬនេសាទជនប្រាថ្នាត្រីដែរ ។ ជនដែលរងគ្រោះ សៅហ្មងអន្តរាយ ដោយសារតែទ្រព្យរបស់ខ្លួនយ៉ាងនេះ មានការប្រៀបធៀបទៅនឹងស្លឹកឈើដែលវិនាសរុះរោយដោយសារផ្លែច្រើន ឬក៏ដូចជាទឹកដែលល្អក់ដោយសារតែមានត្រីច្រើននោះឯង ។

*__សំគាល់ (សំរាប់ជាសេចក្តីបញ្ចប់)__*

ដោយហេតុដែលទ្រព្យសម្បត្តិជាចំណីនៃពួកពាល ហើយដែលអាចបង្កើត" **ការល្អក់** "គឺសេចក្តីសៅហ្មង ឬវិនាសអន្តរាយដល់ម្ចាស់ទ្រព្យបាន នោះត្រូវប្រុងស្មារតីជាដរាបក្នុងការរក្សាទ្រព្យរបស់ខ្លួន ។ ភាសិតនេះមិនមែនធ្វើឲ្យយើង គេទាំងឡាយខូចទឹកចិត្តមិនចង់មានមិនចង់បាននោះទេ ។ សេចក្តីប្រឹងប្រែងក្នុងការរកទ្រព្យត្រូវតែព្យាយាមធ្វើជាដរាប ព្រោះទ្រព្យធនបង្កើតសេចក្តីថ្លៃថ្នូរណាស់តែកាលបើមានទ្រព្យនេះហើយ ត្រូវប្រុងប្រយ័ត្នដើរឧបាយយ៉ាងណាកុំឲ្យ" ចាញ់ " ឬ "ល្អក់" ទៅបានដោយសារតែទ្រព្យសម្បត្តិឯង ។

☆☆☆



www.elibraryofcambodia.org

### ៣-ធម្មតាអ្នកជាជាតិ ការកេរ្តិ៍អាទិឱ្យគិតគូរ

ធម្មតាកើតមកជា "អ្នកជា" គឺអ្នកល្អត្រឹមត្រូវ មានពាហនៈអ្នកដែលមិននៅខ្ញុំកញ្ចះគេ ត្រូវឲ្យចេះ "គិតគូរការកេរ្តិ៍អាទិ" គឺការពារកេរ្តិ៍ពីដើមឲ្យបានល្អគង់វង្សតរៀងទៅ ។ ឯកេរ្តិ៍នេះសំដៅយក :

១-កេរ្តិ៍មតិក ពោលគឺទ្រព្យសម្បត្តិដែលទទួលពីម៉ែឪជូនតាមក

២-កិត្តិនាមល្អ ដែលធ្លាប់មានពីបុព្វបុរសរបស់យើងមកហើយ ពោលគឺកេរ្តិ៍ឈ្មោះជាអ្នកជានោះឯង ។

### ៤-ផ្លូវវៀចកុំបោះបង់ ផ្លូវណាត្រង់កុំដើរហោង

សេចក្តីនេះសំរាប់រំឭកដល់អ្នកជំនួញជួញប្រែគ្រប់ឋានៈ និងអ្នកធ្វើនយោបាយផ្សេងៗ ។

១-ការធ្វើជំនួញ កាលបើកាន់សច្ចៈពេកក៏គ្មានចំណេញដែរ ត្រូវឲ្យវៀចខ្លះ ឯវៀចនេះមិនមែនបំបាត់ប្រវ៉ាញ ថ្លឹងខ្វះក្អែកជញ្ជីង ឬចៀសវាងបំបាត់ពន្ធគយឲ្យតែខាងចំណេញច្រើននោះទេ ។ វៀចនេះគឺកុំនិយាយត្រង់ពេក បើចំណេញស្មើដើម ក៏មិនត្រូវប្រាប់គេត្រង់ បើទុកជាចំណេញក្នុងមួយឆ្នាំរាប់ម៉ឺនប្រាក់ ក៏កុំនិយាយប្រាប់ពាណិជ្ជងទៀត ឲ្យត្រង់អស់ពីពោះ ព្រោះកាលបើគេឃើញចំណេញច្រើនក្នុងមុខជំនួញណាមួយ គេប្រាថ្នារកជំនួញនោះដែរនាំឲ្យលាភរបស់យើងថយទៅវិញ ឬកំពប់អស់រលីងទៅវិញក៏មាន ។

២-ក្នុងការធ្វើនយោបាយ តែដើរតាមផ្លូវត្រង់ គេនឹងស្គាល់ "ពោះ



www.elibraryofcambodia.org

ទៀន" យើងគឺស្គាល់ចិត្តគំនិតយើងទាំងអស់ ។ កុំភ្លេចឡើយពាក្យចាស់លោកថា "**ស្លូតស្លាប់ ទៀចខេរមានតំពូអាយុយឺនយូរ**" (ស្លូតនេះគឺស្លូតត្រង់) ។

## ៥-យល់តូចកុំអាលខំ ទោះយល់ធំកុំអាលស្រាយ

*__វគ្គទី១__* : **យល់តូចកុំអាលខំ**

បើយល់ឃើញថា រឿងរ៉ាវនោះវាតូចទេ កុំអាលខំគឺកុំប្រញាប់បង្ហំនឹងនិយាយ ឬផ្ចាញ់ផ្ចាលរឿងនោះភ្លាម ។ ត្រូវខំអត់ធ្មត់សង្កេតមើលដំណើររឿងនោះទៅទៀត តើវានឹងសាបសូន្យទៅវិញឬរឹតតែធំឡើងទៀត ។

*__វគ្គទី២__* : **ទោះយល់ធំកុំអាលស្រាយ**

ទោះបីយល់ឃើញថារឿងរ៉ាវនោះវាធំហើយ ក៏កុំអាលស្រាយគឺកុំប្រញាប់និយាយពីរឿងនោះ ឲ្យវាបែកសាយឲ្យគេដឹង ឬកុំប្រញាប់ទៅសំរាយរឿងរ៉ាវនោះ ប្រាប់តុលាការ ពោលគឺកុំអាលប្តឹងផ្តល់ ព្រោះក្នុងច្បាប់កេរ្តិ៍កាលនេះ លោកទូន្មានតទៅទៀតថា "**គិតគ្នីអុំគិតខាយមើលពិនិត្យពិនិស្ស័យ**" ។

*__ខ្លឹមសាររបស់សុភាសិត__* :

ក្នុងរឿងរ៉ាវអ្វីក៏ដោយ (ក្នុងគ្រួសារឬក្រៅគ្រួសារ) ទោះតូចក្តី ធំក្តី កុំប្រញាប់ស្រាយ កុំប្រញាប់ផ្ចាញ់ផ្ចាលភ្លាមៗ ត្រូវខំអត់សង្កត់ចិត្តកុំចង់ផ្ចាញក្តី ព្រោះកាលបើកើតក្តីនឹងគ្នាហើយនោះ ទោះបីឈ្នះគេ ក៏គង់តែ



www.elibraryofcambodia.org

រិចរិលគឺរលោះទ្រព្យធនជាមិនខាន ។

បើក្នុងគ្រួសារវិញ ការដែលខំអត់ធ្មត់សង្កត់ចិត្ត យកធម៌ខន្តីដាក់ខ្លួននាំឲ្យបានសេចក្តីសុខជាប្រាកដ ។

<u>*សំគាល់*</u> : លោកមិនមែនទូន្មានថា បើឃើញរឿងនោះវាធំហើយៗ មិនឲ្យស្រាយសោះនោះទេ បើត្រូវស្រាយក៏ស្រាយដែរ តែកុំប្រញាប់ពេក ត្រូវគិតមើលឲ្យជ្រៅជ្រះ តើរឿងនោះនឹងហុចលទ្ធផលឲ្យយ៉ាងណាត្រូវពិនិត្យដំណើររបស់រឿងឲ្យជាក់លាក់ សឹមនិយាយឲ្យបានការតែម្តង ។

## ៦-ធ្វើអ្វីធ្វើឲ្យហើយ កុំទុកឡើយបង្កើតកេរ្តិ៍

លោកទូន្មានថា ការអ្វីក៏ដោយមិនថាតិចឬច្រើន ស្រួលឬពិបាក ត្រូវតែខំធ្វើឲ្យហើយស្រេច កុំមើលងាយថាការបន្តិចធ្វើតែមួយដង្ហើមក៏រួចស្រេចចាំស្អែកសឹមធ្វើក៏បាននោះ ៗ ។ ចុះបើគាប់ជួនស្អែកឡើងមានការអ្វីផ្សេងៗមកផ្ទួនថែមទៀត ឬក៏មានជំងឺអ្វីមកបៀតបៀន នោះការបន្តិចនេះក៏ច្បាស់ជាមិនបានធ្វើរួចឡើយ ។

លោកប្រដៅថា ការអ្វីក៏ដោយកុំទុកទៅថ្ងៃក្រោយឲ្យសោះ ព្រោះនាំ"បង្កើតកេរ្តិ៍" ពោលគឺជាបង្កើតការទម្លាប់អាក្រក់ គឺការទម្លាប់អាក្រក់នេះហើយ ដែលនាំឲ្យខ្លួនទទួលកំហុសផ្សេងៗ ដោយត្រូវគេស្តីបន្ទោសត្មះតិះដៀលថាជាមនុស្សខ្ជិល ជាមនុស្សរាយមាយធ្វើការមិនទៀងទាត់ ជាហេតុធ្វើឲ្យកេរ្តិ៍ឈ្មោះរបស់ខ្លួនសៅហ្មងដរាបទៅ ។



www.elibraryofcambodia.org

*សំគាល់* ៖ មានការខ្លះ គេមិនអាចនឹងបង្ហើយបានក្នុងមួយម៉ោងឬមួយថ្ងៃដែរ ដូចយ៉ាងអ្នកធ្វើតុ ឬទូ ឬឆ្លាក់ក្បាច់រចនាផ្សេងៗ តែទោះបីការនោះត្រូវធ្វើក្នុងរយៈពេលដ៏យូរយ៉ាងណា ក៏ត្រូវប្រញាប់ចាប់ធ្វើតាំងពីដើមទីឲ្យទៀងទាត់ពេលវេលា លុះត្រាតែហើយការមួយមុខសឹមចាប់មួយមុខទៀត កុំចាប់ស្រវានោះមិនឆ្គោះត្រង់ណា នាំឲ្យការដែលបានចាប់ធ្វើមកហើយ អាក់ខានមិនបានទាន់ពេលវេលាទៅវិញនោះ ។

*ឧទាហរណ៍* ៖ ក្នុងពេលប្រាំពីរថ្ងៃ សាស្ត្រាចារ្យបានដាក់ចំណោទមួយឲ្យសិស្សធ្វើ ហើយត្រូវប្រមូលយកដល់ថ្ងៃចូលរៀនវិញ មានសិស្សខ្លះគិតតែសប្បាយដោយអាងថា ចំណោទតែមួយនឹងធ្វើតែមួយភ្លែតក៏ហើយស្រេច ថ្ងៃនេះមិនបានធ្វើថាចាំថ្ងៃស្អែក ដល់ស្អែកឡើងមានគេបបួលដើរលេងក៏ទៅនឹងគេ មួយថ្ងៃផុតទៅថាមួយថ្ងៃទៀត ។ ឥឡូវព្រឹកនេះចូលរៀនហើយ សិស្សនេះក៏តាំងចាប់ធ្វើចំណោទ យប់នោះឯងទទួលវាឈឺក្បាលខ្លាំងក៏ដេកយកកំលាំងលក់លង់ទាល់ភ្លឺស្រាង ពេលក៏ខ្លី ចំណោទក៏ធ្វើមិនទាន់ហើយ ដល់ពេលដែលសាស្ត្រាចារ្យត្រូវការសួររកនោះកំហុសក៏ធ្លាក់ទៅលើសិស្សពេញទី ត្រូដាក់ទណ្ឌកម្មឲ្យឥតញញើតនេះហើយផលអាក្រក់ដែលកើតឡើងពីការធ្វេសប្រហែល ធ្វើអ្វីមិនគិតធ្វើឲ្យហើយ ចេះតែទុកថ្ងៃនេះជាថ្ងៃនោះទាល់តែសាស្ត្រាចារ្យសំគាល់ថាជាសិស្សរាយមាយ ខ្ជិលច្រអូសហើយនាំឲ្យខូចកេរ្តិ៍ឈ្មោះរបស់ខ្លួនឯង ។



www.elibraryofcambodia.org

# ច្បាប់ពាក្យចាស់

## ៧-កាន់កពស់ឲ្យខ្ជាប់ ក្រែងក្រឡាប់ខាំឯប្រាណ

## ទំនងតែង

**សេចក្តីផ្តើម :**

ដើម្បីជាថ្នាំដាស់សតិបញ្ញាដល់ជនណាដែលប្រាថ្នាចោទប្រកាន់ចាប់ផ្ទាក់ពីទោសនរណាមួយ កុំឲ្យគេរើរួចពីពាក្យចោទបាន ជាបណ្ឌិតព្រឹទ្ធាចារ្យទូន្មានក្នុងច្បាប់ពាក្យចាស់ថា : "កាន់កពស់ឲ្យខ្ជាប់" ក្រែងក្រឡាប់ខាំឯប្រាណ ។

*__អត្ថន័យរបស់ភាសិត__* - កាលបើចាប់ពស់ដែលជាសត្រូវរបស់យើងតោងចាប់ត្រង់កឲ្យខ្ជាប់ គឺឲ្យមាំ ទើបពស់មិនអាចនឹងរើបំរះបកក្បាលមកចឹកយើងវិញបាន តែចាប់ខុសកន្លែង ឬក៏ចាប់ត្រង់កដែរ តែដោយបន្ធូរដៃនោះ មុខជាកញ្ច្រោលរកចឹកវិញ ជាហេតុនាំឲ្យឈឺចាប់ ឬវិនាសជីវិតដោយពិសរបស់វា ។

*__អត្ថបដិរូបរបស់ភាសិត__*- "**កាន់កពស់**" គឺការចោទចាប់ប្រកាន់ទោសសត្រូវរបស់យើង ។ ឯត្រូវនេះសំដៅយកជនណា ដែលធ្វើឲ្យយើងកើតទុក្ខមិនសុខចិត្តពីរឿងអ្វីមួយ ។ យើងត្រូវផ្ចាញ់ផ្ចាលទោសវាដោយបែបបទផ្សេងៗ ។ លោកថាឲ្យ "កាន់ត្រង់ក" ហើយ "កាន់ឲ្យខ្ជាប់" ផង គឺកាលបើយើងប្ដឹងចោទប្រកាន់គេហើយ តោងចោទយកបទណា



www.elibraryofcambodia.org

ដែលយើងបានស្នើច្បាប់ស្រេច ហើយយល់ច្បាស់ថាជាកន្លែងធ្វើឲ្យសត្រូវ "ស្លាប់ក្រឡា" គឺវារកផ្លូវបំរះរើមិនរួចពីកណ្តាប់ដៃយើង ហើយកុំភ្លេចឲ្យសោះត្រង់ "**កាន់ឱ្យខ្ជាប់**" គឺខំប្រឹងគិតការរបស់យើងដោយហ្មត់ចត់តែធ្វើលេងៗ ក្រែង "**ពស់ក្រឡាប់ខាំងប្រាណ**" គឺប្រយ័ត្នក្រែងសត្រូវកញ្ច្រោលរួចពីពាក្យចោទ ហើយត្រឡប់ជាប្តឹងយកខ្លួនយើងឲ្យមានទុក្ខទោសទៅវិញ ដោយចោទថាយើងក្លាវទោសបង្កាច់ត្រកូលមួលមារយាទវាឲ្យខ្មាសគេ ។

<u>*ឧទាហរណ៍*</u> : ១-ពាណិជ្ជ **សុខ** បានដំណឹងពីនាយអាយថាចាងហ្វាង "**ស្ងួន**" បានទទួលសំណូកពីនាយ **សៅ** ដោយជួយនាយ **សៅ** ឲ្យរួចពីទោសឧក្រិដ្ឋ ។ ដោយ **សុខ** មិនចូលចិត្តនឹង **សៅ** ហើយស្អប់ចាងហ្វាងផងនោះ "**សុខ**" ក៏ចេញមុខប្តឹងតុលាការភ្លាម ។ ដល់តុលាការសួរចម្លើយសុខឆ្លើយថាឃើញ **សៅ** ចេញចូលផ្ទះលោកចាងហ្វាងជាញឹកញាប់ ហើយស្រាប់តែឃើញ **សៅ** គ្មានជាប់ទោសអ្វីសោះ ។ តើឲ្យ **សៅ** ជាប់ទោសឧក្រិដ្ឋឯណាបាន បើចាងហ្វាងរកភស្តុតាងមិនឃើញផង ។ ដូច្នេះការដែលចោទចាងហ្វាងទទួលសំណូកពីនាយ **សៅ** ក៏ត្រូវតុលាការបដិសេធយោលយកជា ការមិនបានទៅ តែម្តងនេះត្រូវវេនចាងហ្វាងនិងនាយ**សៅ**ប្តឹងយកពាណិជ្ជ **សុខ** វិញ ព្រោះ **សុខ** ចង់បង្ខូចគេឲ្យអសោចន៍ឈ្មោះ ។ **សុខ** ត្រូវតុលាការផ្តន្ទាទោសជាទម្ងន់ កើតក្តីឈឺចាប់ដល់ចិត្ត ជាហេតុបណ្តាលពី "**កាន់កពស់មិនឱ្យខ្ជាប់**" ហើយ "**ពស់ក្រឡាប់ខាំងប្រាណ**" វិញនោះឯង ។



www.elibraryofcambodia.org

២-ម៉ុក និងម៉ៅទាស់ទែងខ្វែងគំនិតគ្នាជាច្រើនលើកមកហើយ ។ ក្នុងរាត្រីពេញបូណ៌មីខែចូលឆ្នាំ ម៉ុក ត្រូវគេកាប់បែកក្បាល ។ ដោយនឹកក្នុងចិត្តថាគ្មាននរណាជាសត្រូវក្រៅពីម៉ៅ ម៉ុកក៏ក្តៅកើតប្តឹងយកម៉ៅដាក់គុក ។ ម៉ៅជាអ្នកល្បីចិត្តមុតមែន វិស័យដូចពស់ដែលគេខ្លាចព្រោះមានពិសដែរ តែដោយម៉ុករកភស្តុតាងឲ្យច្បាស់លាស់មិនបាននោះពាក្យបណ្តឹងក៏អសារឥតការទៅ ។ ម៉ៅបានចិត្តប្តឹងយកម៉ុកឲ្យទទួលទោសវិញវិស័យដូចពស់ក្រឡាប់ខាំអ្នកដែលកាន់កវាមិនជាប់ដែរ ។

**សេចក្តីបញ្ចប់**

ក្នុងការសព្វសារពើដែលប្រារព្ធធ្វើ ត្រូវតែពិចារណាជាមុនឲ្យដឹងតើអំពើដែលធ្វើទៅនោះនឹងហុចផលល្អ ឬអាក្រក់មកឲ្យវិញ ។ កាលបើប្តេជ្ញាថាចាប់ធ្វើការនោះហើយត្រូវប្រុងស្មារតីវៃវាងជាដរាប លុះត្រាតែការនោះបានសម្រេច ។

☆☆☆



www.elibraryofcambodia.org

## ៨-អូសទូកកុំឲ្យលំអាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក

## ទំនងតែង

**សេចក្ដីផ្ដើម :**

វដ្តទុក គឺទុក្ខទោសទាំងឡាយដែលវិលវល់ចុះឡើងប៉ះពាល់រាល់រូបឥតស្រាកស្រាន្ត ។ ដូច្នេះ បណ្ដាអ្នកប្រាជ្ញគ្រប់សាសន៍បានចងក្រងជាបញ្ហា ជាភាសិត ជាបទចរិយាសាស្ត្រផ្សេងៗ ដើម្បីជាឱសថរំលត់ទោស និងជាយានដឹកនាំគាំពារបុថុជ្ជនក្នុងលោកឲ្យចាកជៀសផុតពីអន្លង់ទុក្ខ និងឧបសគ្គគ្រប់ជំពូកដែលកើតឡើងឥតទៀងទាត់ ។ ដូចយ៉ាងក្នុងច្បាប់ពាក្យចាស់ លោកទូន្មានថា "អូសទូកកុំឲ្យលំអាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក" ។

***អត្ថាន័យ និងអត្ថបដិរូបរបស់ភាសិត***

*វគ្គទី១* : **អូសទូកកុំឲ្យលំអាន**

"**អូសទូក**" នេះគឺទាញទូកពីគោកទៅដាក់ទឹក ។ "**កុំឲ្យលំអាន**" គឺកុំឲ្យមានស្នាមនៅលើដី ឬមានស្នាមនៅបាតទូក ព្រោះជាការនាំឲ្យសឹកដាច់បាតទូក ឬអន្តរាយធ្លុះធ្លាយទូកក៏មាន ។

អ្នកប្រាជ្ញចង់ទូន្មានថា : កាលបើអូសទូកគឺប្រកបការអ្វីមួយយ៉ាងពិបាកដោយមានឧបសគ្គជាច្រើននៅរាំងរា នោះត្រូវប្រយ័ត្ន "អូសកុំឲ្យលំអាន" គឺធ្វើការនោះទៅកុំឲ្យមានស្នាមពោលគឺកុំឲ្យមានស្មៅហ្មងមានរឿងរ៉ាវអ្វីផ្សេងៗដែលអាចឲ្យទុក្ខទោសដល់ខ្លួន នៅវេលាកំពុង



www.elibraryofcambodia.org

ប្រតិបត្តិការនោះ ។

*វគ្គទី១២* : **ចាប់ត្រីបានកុំឱ្យល្អក់ទឹក**

គឺធ្វើម្តេចឲ្យបានត្រី ហើយទឹកនៅតែថ្លាដូចដើម ។

អ្នកប្រាជ្ញចង់ទូន្មានថា បើយើងប្រាថ្នានឹង "**ចាប់ត្រី**" គឺនឹងធ្វើអ្វីឲ្យបានលាភមានផលដល់យើងនោះ បើបានលាភហើយត្រូវប្រយ័ត្នកុំឲ្យមាន "**ទឹកល្អក់**" គឺកុំឲ្យមានការសៅហ្មងដិតដល់ខ្លួន កុំឲ្យមានទុក្ខទោសដល់ខ្លួនក្នុងគ្រាក្រោយ ។

*ឧទាហរណ៍* : ការដែលឃោសនាខាងបោះឆ្នោតរើសតំណាងរាស្ត្រជាការមួយធ្វើពិបាក ព្រោះមានឧបសគ្គជាច្រើនមករាំងរា ។ នោះក្នុងការដែលឃើញថាពិបាកនេះ បេក្ខជនដែលនិយាយឃោសនាឲ្យរាស្ត្របោះឆ្នោតជ្រើសខ្លួនជាតំណាង ត្រូវខំឆ្លងឲ្យផុតពីការលំបាក ដោយឥតមានសេចក្តីសៅហ្មងដិតដល់ខ្លួន គឺប្រយ័ត្នខំទាញខ្លួន ឲ្យចាកផុតនូវគំនរឧបសគ្គផ្សេងៗ ដោយគ្មានរឿងរ៉ាវអ្វី នឹងឲ្យទុក្ខទោសដល់ខ្លួនក្នុងវេលាប្រតិបត្តិការនោះ ។

បេក្ខជនដែលខំធ្វើឃោសនាយ៉ាងនេះ គឺដើម្បីនឹងឲ្យបានសំរេចបំណងមួយ ឲ្យបានជាប់ឈ្មោះជាតំណាងរាស្ត្រ ប៉ុន្តែបេក្ខជននេះមិនត្រូវភ្លេចថា "**ចេះចាប់ត្រីបានកុំឱ្យល្អក់ទឹក**" គឺបើនឹងជាប់ឆ្នោតជាតំណាងរាស្ត្រ ក៏ជាប់ដោយត្រឹមត្រូវ ដោយប្រព្រឹត្តល្អស្អាត កុំឲ្យមានរឿងរ៉ាវផ្សេងៗ ដែលត្រឡប់ជានាំខ្លួន "**ឱ្យល្អក់**" គឺកុំឲ្យទទួលកំហុសអ្វីមួយមកវិញបាន ។



www.elibraryofcambodia.org

ម្យ៉ាងទៀត ឯអ្នកជំនួញ នូវអ្នករាជការគ្រប់ជាន់ថ្នាក់ ក៏ត្រូវខំបំពេញកិច្ចការរបស់ខ្លួនរៀងៗខ្លួន ដោយជៀសវាងកុំឲ្យមានការសៅហ្មងជិតដល់ខ្លួនបាន ។ ដែលនឹងបានផលទៀត ក៏កុំឲ្យល្អក់ គឺបានមកដោយសុខ មិននាំឲ្យរំខានចិត្ត ។

**សេចក្ដីបញ្ចប់**

កិច្ចការសព្វសារពើដែលយើងបំរុងនឹងធ្វើឬដែលបានចាប់ធ្វើទៅហើយក៏ដោយ តោងខំអួសខំទាញខំប្រយុទ្ធឲ្យដល់ត្រើយដោយប្រុងប្រយ័ត្នជាដរាប កុំឲ្យការនោះហុចទុក្ខទោសមកដល់ខ្លួនវិញ ។

☆☆☆

## ៩-ស្លឹកឈើឥតកម្រើក បើកគ្រើកឥតខ្យល់បក់ ទឹកថ្លាល្អឹកបើល្អក់ ឥតរលកខ្លាំងសោះសា។

រឿងរ៉ាវតូចធំគ្រប់ជំពូកដែលកើតឡើងបាន សុទ្ធតែមានបុព្វហេតុគឺហេតុដើម ហេតុដំបូង វិស័យដូចដំបៅគ្រប់បែប ដែលកើតឡើងក៏មកពីមានស្នាមរបួសមុន ឬមានមេរោគទៅអាស្រ័យនឹងសាច់ស្បែកជាមុនដែរ ដូចយ៉ាងក្នុងច្បាប់ពាក្យចាស់លោកថា ស្លឹកឈើដែលកគ្រើកក៏មកពីមានខ្យល់បក់ ឯទឹកដែលល្អក់ក៏មកពីមានរលកខ្លាំងដែរ ស៊ីគ្នានឹងភាសិតបារាំងមួយថា "**មិនដែលមានផ្សែង ដោយគ្មានភ្លើង**" នោះទេ ។

<u>*ឧទាហរណ៍*</u> : ១-មនុស្សដែលមានទឹកមុខក្រៀមក្រំ ក៏មកពីមានទុក្ខក្នុងខ្លួន ។

២-មនុស្សដែលសម្លាប់ខ្លួនឯង ក៏មកពីមានរឿងអ្វីមួយយ៉ាងដែល



www.elibraryofcambodia.org

ជាបុព្វហេតុ ធ្វើឲ្យអ្នករងគ្រោះកើតទុក្ខមិនសុខចិត្តនឹងរស់នៅ ។

៣-រឿងក្ដីក្ដាំប្ដឹងផ្ដល់ ក៏កើតឡើងដោយគូវិវាទមានទាស់គ្នាពីហេតុអ្វីមួយ ។

☆☆☆

## ច្បាប់កូនចៅ

**១០-មួយនីក្រមច្បាប់ លោកពុំឱ្យគ្រាប់ អំពើពុតជ្រៃ កាលណាដូចដុះ ចាប់ចុះអាស្រ័យ គ្រប់ឋានណាអែ ឈ្លកដើមអន្តរាយ។**

## ចំនងតែង

### សេចក្តីផ្តើម

លោកីយសព្វថ្ងៃ សម្បូណ៌ពេកខាងមនុស្សដែលរមិលគុណអ្នកដែលបានធ្វើសេចក្ដីល្អដល់វា ។ គេហៅពួកអកតញ្ញូទាំងនេះ ថាជាពួកក្រពើ ឬពុំនោះសោតគេចាត់ជាពួកជ្រៃ ព្រោះក្នុងច្បាប់កូនចៅលោកបានចែងមកថា : "**មួយនីក្រមច្បាប់ លោកពុំឱ្យគ្រាប់ អំពើពុតជ្រៃ កាលណាដូចដុះ ចាប់ចុះរាស្រ័យ គ្រប់ឋានណាអែ ឈ្លកដើមអន្តរាយ។**

*អត្ថាធិប្បាយរបស់ភាសិត* :

ធម្មជាតិដើមជ្រៃ តែងដូចដុះចាប់ចុះអាស្រ័យ នៅដោយដើមឈើដទៃមានដើមត្នោតជាដើម (ជួនកាលក៏ចាប់កំណើតនៅតាមកំពែងឬលើខឿនប្រាសាទនានាដែរ) ។ ដើមជ្រៃដែលនឹងលូតលាស់រស់រានមាន



www.elibraryofcambodia.org

ជីវិត ក៏ដោយសារតែដើមត្នោត ដែលជាទីបង្អែកយ៉ាងមាំរបស់ជ្រៃ លុះកន្លងយូរឆ្នាំមក កាលបើជ្រៃភ្លូសមែកបែកឫសមាំទាំហើយ នោះវាក៏តាំងចាប់រួតរឹតស្រោបជិតជុំដើមត្នោត ជាហេតុឲ្យ"ម្ចាស់ដើម" គឺដើមត្នោតនេះវិនាសអន្តរាយបន្តិចម្តងៗ លុះត្រាតែបាត់រូបស្លាប់បង់ទៅក៏មាន ។

*__អត្ថបដិរូបរបស់ភាសិត__* :

ដើមជ្រៃមិនខុសអ្វីពីជន ដែលទៅពឹងពាក់ពុំនាក់អាស្រ័យនឹងអ្នកដទៃ ។ ដើមត្នោតគឺអ្នកដែលទំនុកបំរុងឧបត្ថម្ភគាំពារព្យាបាលគេឲ្យរឹងជំហរឡើង ។ គេតែងប្រទះឃើញជនដែលគេបានផ្គុងផ្តើមឲ្យរឹងជំហរនេះ ធ្វើឲ្យម្ចាស់ដើមអន្តរាយដោយសារខ្លួនវិញ ។

*__ឧទាហរណ៍បញ្ជាក់__* :

១- ក្នុងសៀវភៅគតិលោក រឿងមួយនិទានថា ឆ្កែកំដើមមួយទៅសុំរូងឆ្កែឈ្មោលដទៃ សំរាលកូន ។ ឆ្កែឈ្មោលក៏ឲ្យឆ្កែមេខ្ចីជាបណ្តោះអាសន្ន ។ លុះសំរាលកូនហើយ ឆ្កែមេនិយាយអង្វរឆ្កែឈ្មោលថា ចាំដល់កូនធំបន្តិចសឹមប្រគល់រូងវិញ ។ ឆ្កែឈ្មោលមានចិត្តសប្បុរសជាដរាប ។ លុះកន្លងយូរបន្តិចមក កូនឆ្កែទាំង៥ ក៏មានចង្កូមមាំទាំឡើង កាលបើឆ្កែឈ្មោលទៅសុំយករូងវិញ ឆ្កែមេក៏នាំកូនព្រួតខាំឆ្កែឈ្មោលទាល់តែស្លាប់ ហើយយករូងរបស់គេនៅរហូតទៅ ។

២- នាយម៉ៅដង្ហៅស្រូវគ្មានប្រពន្ធកូនបងប្អូនម្នាក់សោះ ។ ក្មេងជំទង់ដទៃម្នាក់មកនិយាយសុំនៅរកស៊ីជាមួយផង ។ នាយម៉ៅអាណិតក៏



www.elibraryofcambodia.org

ទទួលជួយឧបត្ថម្ភគ្រប់ជំពូក ។ កាលបើទុកចិត្តគ្នាហើយ នាយម៉ៅក៏ចុះសំបុត្រកំណើតនោះធ្វើជាកូន ។ ក្មេងដែលគេចិញ្ចឹមនេះ លុះធំដឹងក្តីមែនទែនហើយ ក៏ចង់ធ្វើជាអ្នកមានឲ្យទាន់ចិត្ត ។ ក្នុងពេលដែលដង្កៅម៉ៅនាំស្រូវតាមទូកទៅលក់ឯភ្នំពេញ ក្មេងអកតញ្ញូនេះ ប្រើឧបាយផ្សេងៗ មានជួលចោរជាដើមឲ្យទៅពួនស្ទាក់នាយម៉ៅសម្លាប់ចោល ដើម្បីយកទ្រព្យសម្បត្តិនាយម៉ៅធ្វើជាកេរ្តិ៍មរតករបស់ខ្លួនទាំងអស់ ព្រោះអាងថាសំបុត្រកំណើតបានចុះថាជាកូនដង្កៅស្រេចហើយ ។

៣-នាងគាំនិយាយនឹងប្តីថា៖ "មានកុមារីជំទង់ម្នាក់មកសូមនៅជាមួយផង ខ្ញុំមានចិត្តមេត្តាករុណាដល់នាងនោះពេកណាស់ ព្រោះជាក្មេងកំព្រាគ្មានទីបង្អែក" ។ បុរសប្តីទោះបីមិនចូលចិត្តយ៉ាងណាក៏យល់ព្រមតាមសេចក្តីអង្វររបស់ភរិយាដែរ ។ លុះនៅជាមួយគ្នាយូរទៅ កាលបើស្រីដែលគេរើសយកមកចិញ្ចឹមនេះពេញរូបរាងហើយ វាក៏ចាប់ចិត្តប្រតិព័ទ្ធជាមួយបុរសប្តីនាងគាំ ។ នាង "ជ្រៃ" ទៅជាប្រពន្ធចុងគេ ធ្វើឲ្យប្រពន្ធដើមក្តៅក្រហាយរោលរាលឈ្លោះវាយប្តីប្រពន្ធ កើតរឿងរ៉ាវយ៉ាងធំ ។ នាងប្រពន្ធចុង ចេះនិយាយលួងលោមប្តីទាក់រុកទាល់តែនាងជាប្រពន្ធដើមខ្ចាតចេញពីទីឋានដ៏ស្តុកស្តម្ភ ហើយធ្លាក់ខ្លួនថោកទាបអាប់ឱនស្រពោនចិត្ត ព្រោះតែនាង "ជ្រៃ" ។ នាង "ជ្រៃ" ក៏ឡើងជាមេផ្ទះពេញមុខ វិស័យដូចដើមជ្រៃទៅនៅអាស្រ័យនឹងដើមត្នោត ហើយធ្វើឲ្យត្នោតវិនាសទៅបាន ។

<u>*សំគាល់ (សំរាប់ជាសេចក្តីបញ្ចប់)*</u> ៖ យើងសង្កេតឃើញថា កាលដែល



www.elibraryofcambodia.org

ដើមត្នោតស្លាប់បាត់ទៅហើយ ដើមជ្រៃលូតលាស់រីងជំហរបែកមែក យ៉ាងល្អនៅកន្លែងនៃ"ខ្មោចត្នោត" ។ អ្នកប្រាជ្ញមិនមែនសរសើរជ្រៃ ដែលធំខ្ពស់រឹងប៉ឹងតែឯងដោយធ្វើឲ្យត្នោតវិនាសនោះទេ ។ ធម្មតាជន អកតញ្ញូមិនដែលរុងរឿង ស្ថិតស្ថេរចីរកាលឡើយ បើទុកជាក្នុងពេល នេះវាបានថ្កុំថ្កើងរឹងជំហរដូចដើមជ្រៃនោះ គេតែងប្រទះឃើញពួក ពាលនេះអន្តរាយទៅវិញក្នុងពេលយូរឬឆាប់ វិស័យដូចព្រូនដែលធំ ធាត់តែដំបូង លុះក្រោយទៅក៏វិនាសទៅវិញជាដរាប ។

ដោយឃើញថាដើមជ្រៃលូតលាស់យូរលង់បាន មិនត្រូវនឹកថាជន អកតញ្ញូ ក៏រុងរឿងយូរដូចជ្រៃដែរនោះឡើយ ត្រូវចាំឲ្យជាក់ថា :"បើ ធ្វើល្អបានផលល្អ ធ្វើអាក្រក់បានផលអាក្រក់ យកសុខទៅដូចសុខ យក ទុក្ខទៅដូរទុក្ខ" ។

## ១១-លោកថាល្ងាផង សម្បកក្រៅហោង គ្លីផ្លែកយល់យង់រឹង ក្នុងផ្លែ សឹងតែមមង់ ក្រាស់ក្រៃនៅក្នុង នោះហោងលោកថា

## សេចក្តីអធិប្បាយជាគំរូ

ដោយសង្កេតឃើញថា នៅនាលោកនេះមនុស្សមានច្រើន សណ្ឋាន"ខ្លះវៀច ខ្លះត្រង់ ខ្លះសាមាន្យ" ទើបបូរាណបណ្ឌិតព្រឹទ្ធាចារ្យ ចងជាបញ្ហាទុកក្នុងច្បាប់កូនចៅថា :"លោកថាល្ហាផង សម្បកក្រៅ ហោង ភ្លីផ្លេកយល់យង់រឹងក្នុងផ្លែ សឹងតែមមង់ ក្រាស់ក្រៃនៅក្នុង នោះហោងលោកថា" ។ ពាក្យនេះមានន័យថា :



www.elibraryofcambodia.org

ឯផ្លែល្វាកាលដែលទុំឡើង មានពណ៌ក្រហមរលោង មានសម្បករលីងស្រស់រលើប គួរឲ្យស្រើបស្រាលត្រេកត្រអាលចង់បេះប្រឡេះយកមកកាន់ យកមកភ្លក់អាស្រ័យណាស់ ប៉ុន្តែក្នុងផ្លែ មានសុទ្ធតែសត្វមមង់វារវុករវើកពាសពេញតាមចន្លោះសាច់ល្វានោះ គួរឲ្យខ្ពើមរអើមជៀសវាងរាងចាល លែងហ៊ានហែកកាន់មើលទៀត ។

ឯផ្លែល្វាដែលល្អល្អតែក្រៅនេះ លោកប្រៀបធៀបទៅមនុស្សណាដែលមានរូបឆោមលោមពណ៌ សាច់សល្អសមស្អាតស្អំស្រស់ប៉ប្រិមពុំទាស់ភ្នែកអ្នកដទៃ ក៏ប៉ុន្តែមនុស្សនោះឯងមានចិត្តអាក្រក់ពេកឬក៏មានឫកពាឥរិយាមិនសមរម្យ ជាហេតុធ្វើឲ្យអ្នកផងទាំងពួងស្អប់ខ្ពើមទៅវិញ ។

ប៉ុន្តែពាក្យអ្នកប្រាជ្ញនេះ មិនមែនសំដៅទៅលើតែមនុស្សណាដែលមានរូបឆោមរាងកាយឆើតឆាយ ដូចបានអធិប្បាយមកហើយនោះទេ លោកប្រៀបប្រដូចផ្លែល្វា ទៅនឹងជនណាដែលមានសំដីវាចាផ្អែមពីរោះ គួរឲ្យអ្នកផងទាំងពួង ទុកចិត្តចូលជិតរើសយកជាមិត្តស្និទ្ធស្នាលរាប់អានចងស្ពានមេត្រីដោយស្តាប់ពាក្យសំដីឃើញថា ប្រហែលជាមនុស្សនោះល្អបរិសុទ្ធត្រឹមត្រូវកាន់ផ្លូវត្រង់មែន ប៉ុន្តែមនុស្សសំដីល្អនេះច្រើនមានចិត្តល្អក់អាក្រក់ជាប់ ហេតុនេះបានជាអ្នកប្រាជ្ញបន្ថែមសេចក្តីទៀតថា : "**អ្នកមួយចែចូវ វើរវាវ ទៀចនោមស្ងួសមា ចញ្ចើមបញ្ចើ ពាក្យពេចមាយា ដូចផលផ្លែល្វា ល្អល្អះតែក្រៅ**" ។

សេចក្តីដែលបានសាធកៈមកហើយនេះឃើញថា ត្រូវអែះអៅអា



www.elibraryofcambodia.org

ប៉ុន្តែយើងនឹងថា មនុស្សណាដែលល្អតែមាត់ក្រៅ ហើយចិត្តសុទ្ធតែខ្មៅ អាក្រក់វៀចវេរឫស្យា ទាំងអស់នោះក៏មិនមែនដែរ ត្បិតមានខ្លះសំដីល្អ ហើយចិត្តក៏ល្អដូចផ្លែឈើខ្លះល្អខាងក្រៅ ហើយមានទាំងឱជារសផ្អែម ឆ្ងាញ់ពីសាផង ។ ប៉ុន្តែយើងប្រទះឃើញថា ក្នុងនាលោកនេះ កម្រមាន មនុស្សដែលមានសំដីល្អហើយឲ្យមានចិត្តល្អផងនោះណាស់ ច្រើនមាន តែមនុស្សសំដីផ្អែមចេះបញ្ចើចបញ្ចើ ហើយមានចិត្តអាក្រក់ ។ ធម្មតា មនុស្សអាក្រក់ ច្រើនមានវាចាវោហារផ្អែមពីរោះមករកយើង ដើម្បីឲ្យ យើងទុកចិត្តអស់ពីពោះថាវាល្អ ឯមនុស្សជំពូកនេះ កុំសូវទុកចិត្តវា កុំ យកធ្វើជាគ្នា ថ្ងៃក្រោយមិនយូរមិនឆាប់វានឹង"**ត្បកក្បាល**"យើងវិញជា មិនខាន ។

ដូចយើងដឹងស្រាប់ហើយក្នុងរឿងល្បើក"ក្អែកនិងកញ្ជ្រោង" ឬ" មាន់និងកញ្ជ្រោង" របស់កវីបណ្ឌិតឡាហ្វុងតែនដែលបានលើកទុកមក ជិតបីសតវត្សមកហើយ ចុះតើកញ្ជ្រោងវាធ្វើយ៉ាងដូចម្តេចដើម្បីនឹង បាននំពីក្អែក ឬបានមាន់ជាអាហារវា? ចូរយើងកុំភ្លេចឲ្យសោះ ពាក្យ បញ្ចើចបញ្ចើ ដោយប្រើសំដីផ្អែមល្ហែមត្រជាក់នេះហើយ ជានុយ បបោសអង្អែលចិត្តឲ្យក្អែកគិតថាពិតជាពាក្យត្រង់ ក៏ហាមាត់និយាយ ឡើងធ្លាក់ឯនំទៅដីបានជាចំណីនៃកញ្ជ្រោងវិញទៅ ។ ឯមាន់វិញក៏ស្លាប់ ខ្លួន ពីព្រោះតែពួកកញ្ជ្រោងនិយាយបញ្ឆោរដោយពាក្យផ្អែមពីរោះគួរទុក ចិត្តពន់ពេកណាស់ ។

ក្នុងរឿងមួយទៀតរបស់លោកម៉ូលីយារ៍ មាននិទានថា នាហ្មឺនម្នាក់



www.elibraryofcambodia.org

ឈ្មោះលោក ដូរង់ ចង់ទៅបោកប្រាក់អ្នកមានទ្រព្យសម្បត្តិម្នាក់ឈ្មោះ ហ្សូរដាំង ។ លោក ដូរង់ស្អប់ ហ្សូរដាំងពេក ប៉ុន្តែដោយលោកខ្វះប្រាក់ចាយ លោកក៏ធ្វើជារាប់អាន ហ្សូរដាំងទៅ លោកនិយាយប្រាប់ហ្សូរដាំងថា គ្មានស្រឡាញ់នរណាជាងហ្សូរដាំងទេ លោកកុហកថា លោកបានទៅនិយាយនៅក្នុងចំណោមសរសើរពីហ្សូរដាំងជាច្រើនដង លោកថានឹងរកមនុស្សណាឲ្យវិសេសជាងហ្សូរដាំងក៏គ្មាន... ឯពាក្យលោកទាំងប៉ុន្មានសុទ្ធតែពាក្យបញ្ឆោរបោកប្រាស់ទេ ប៉ុន្តែពីរោះផ្អែមហាក់ដូចជារឿងនោះពិតប្រាកដមែន គួរឲ្យហ្សូរដាំង "**ត្រចៀកស្រាល**" ទុកចិត្តពេក ។

ចូរយើងពិចារណាមើលចុះ ក្នុងរឿងទាំងពីរនេះសត្វកញ្ជ្រោងនិងលោក ដូរង់ មានសំដីល្អផ្អែមពីរោះតែមាត់ក្រៅ ឯចិត្តវិញសឹងអាក្រក់វៀចវេរចង់បំផ្លាញគេឲ្យវិនាសសោះ វិស័យដូចផ្លែល្វាដែលល្អ "ភ្លឺផ្លេក" តែសម្បកហើយខាងក្នុងសុទ្ធតែមមង់ដែរ ។

យើងមិនត្រូវទុកចិត្តមនុស្សណា ដែលយើងមិនទាន់ស្គាល់ឲ្យច្បាស់លាស់ឡើយ ត្បិតមនុស្សមានច្រើនសណ្ឋានណាស់ ខ្លះ "ចិត្តជាទេវទត្ត មាត់ដូចទេវតា" ខ្លះទៀត "អាក្រក់តែមាត់ចិត្តដូចទេវតា" ហេតុដូច្នេះហើយបានជាក្នុងច្បាប់កូនចៅដែលនេះ លោកបន្ថែមទៀតថា : វីសោតខ្នុរណាំង សម្បកស្ដោកស្ដាំង បន្លាច្រូងនៅ ឯក្នុងសឹងក្លែបក្រអែបផ្អែមទៅ ទាល់ក្នុងឥតសៅ រសសឹងពីសា" ។



www.elibraryofcambodia.org

## ១២- លោកថាឲ្យត្រាប់ នូវសត្វកុកសាប់ អំពើប្រពៃ កុំត្រាប់កុកស ភោភាវសព្វថ្ងៃ ហើរទំអាស្រ័យ ពុំប្លែកប្លែងប្រាណ

# ចំនងតែង

## សេចក្តីផ្តើម

ដើម្បីរស់នៅក្នុងសង្គមជន ឲ្យបានសុខសាន្តរៀងរាបទៅ ត្រូវនំធ្វើខ្លួនប្រាសចាកពាក្យនិន្ទាទាំងឡាយ និងភយន្តរាយគ្រប់ប្រការដោយព្យាបាលត្រិះរិះ ពិចារណាឲ្យយល់អស់អាថ៌ នូវពាក្យឱវាទ និងក្បួនតម្រាសុភាសិត ដែលបណ្ឌិតចារចែងបែងសេចក្តី ដើម្បីជាគតិនាំលោកទៅកាន់ស្ថានសុខ ដូចយ៉ាងក្នុងច្បាប់កូនចៅ លោកប្រដៅថា៖ ”ឲ្យត្រាប់នូវសត្វកុកសាប់ អំពើប្រពៃ កុំត្រាប់កុកស ភោភាវសព្វថ្ងៃ ហើរទំអាស្រ័យ ពុំប្លែកប្លែងប្រាណ” ។

***អត្ថាធិប្បាយរបស់ភាសិត***

***វគ្គទី១*** ៖ ”លោកថាឲ្យត្រាប់ នូវសត្វកុកសាប់ អំពើប្រពៃ” កាលបើកុកសាប់ ចុះទៅរកទំ ឬរកស៊ីនៅទីណា ដូចជាទំនៅលើមែកឈើ ឬចុះរកស៊ីនៅវាលស្រែ ឬក្នុងថ្លុកដីមានភក់ក្រខ្វក់ជាដើមនោះ គេឃើញស្លាបដែលស្រោបកាយរបស់វាមានពណ៌ប្រផេះ ឬសម្បុរត្រសក់ស្រដៀងគ្នា និងពណ៌ភក់ ឬពណ៌ស្លឹកឈើដែរ ។ ផ្ទុយពីនេះទៅវិញ កាលបើកុកសាប់ហិចហើរធ្វើដំណើរក្នុងវេហារស៍ដ៏ជាទីស្អាតស្រឡះល្អនោះគេឃើញស្លាបដែលលាតត្រដាងឡើងមានពណ៌សស្គុសដូច



www.elibraryofcambodia.org

សំឡី ។

*វគ្គទី២* : "កុំគ្រាប់កុកស គោតាខសពួថ្ងៃ ហើរធំអាស្រ័យ កុំប្លែកប្លែខ ប្រាណ"

មិនថានៅទីណា ពេលណា ទាំងថ្ងៃទាំងយប់គ្រប់តំបន់ កុកសឥត ប្រែប្រួលផ្លាស់ប្តូរពណ៌ ស្លាបដូចកុកសាច់ឡើយ ។ ពណ៌សដវាបនេះ អាចទាញភ្នែកអ្នកទាំងពួង មានព្រានបរបាញ់ជាដើម ឲ្យក្រឡេកមើល ស្គាល់ថាជាសត្វកុកភ្លាមៗ មិនចាំបាច់ពិនិត្យយូរផង ការដែលហើរ ដែលទំអាស្រ័យមិន "ប្លែកប្លែងប្រាណ" គឺមិនមានប្លែកគ្រឿងសំគាល់ ក្រៅនេះតែងទទួលនូវផលអាក្រក់ផ្សេងៗ មិនខាន ជួនកាលវិនាស អន្តរាយដល់ខ្លួនក៏មាន ។

*អត្ថបដិរូបរបស់ភាសិត*

អ្នកប្រាជ្ញទូន្មានថា ឲ្យធ្វើតាមកុកសាប់វិញ ព្រោះជា " អំពើដ៏ ប្រពៃ" ។ យើងឃើញថា កុកសាប់ចេះផ្លាស់ពណ៌សម្បុរតាមទីកន្លែង តាមពេលវេលា (ព្រោះពេលឈប់ កុកសាប់ក៏ត្រូវគ្របដណ្តប់កាយ ដោយស្លាបប្រផេះដែរ) ដើម្បីកុំឲ្យគេឆាប់ចាប់ភ្នែកទៅរកវាដើម្បីរក្សា ខ្លួនឲ្យបានសេចក្តីសុខ គឺជៀសវាផលអាក្រក់ ឬការអន្តរាយដល់ខ្លួន បាន ។ អ្នកប្រាជ្ញចង់ប្រដៅយើងថា :

ក- ឲ្យចេះផ្លាស់ប្តូរឫកពាកិរិយាតាមទេសៈកាលៈ គឺចេះធ្វើឫកពា ឲ្យច្រឡំនឹងគេឯងតាមទីកន្លែង នឹងពេលវេលាដែលតាំងនៅ កុំធ្វើឲ្យ ឆ្គងកុំឲ្យឈ្លើយកុំឲ្យប្លែកឆ្លៀដាច់គេនោះ កន្លែងណាពេលណា ត្រូវ



www.elibraryofcambodia.org

លើកខ្លួនសឹមលើក កន្លែងណាពេលណាត្រូវដាក់ខ្លួន យើងត្រូវតែដាក់ ដើម្បីរក្សាសេចក្ដីសុខ ។

កាលបើមានធុនធានច្រើននោះ ក៏មិនចេះតែ"ភោភាវសព្វថ្ងៃ" គឺ បង្ហាញឫកពាឲ្យឃើញឆ្អែតជាដរាបនោះទេ ជាហេតុនាំឲ្យគេជិនឫក ឲ្យ គេស្អប់ឬពេបជ្រាយនិយាយដើម ពោលគឺនាំតែសៅហ្មងដល់ខ្លួន ។

ខ- ឲ្យចេះរៀបចំតែងកាយតាមទេសៈកាលៈ គឺកុំឲ្យភោភាវតែសព្វ ថ្ងៃ ឬភោភាវតែគ្រប់កន្លែង ដូចសត្វកុកសនោះ ឧបមាបើនៅស្រុកស្រែ ចំការ របៀបរៀបចំតែងខ្លួនក៏ល្មមឲ្យស៊ីគ្នានឹងកន្លែងដែលយើងនៅ អាស្រ័យ ដើម្បីកុំឲ្យអ្នកផងបាញ់ភ្នែកមករកយើងព្រោះតែអាការ ភោភាវនេះ ជាហេតុធ្វើឲ្យគេរិះគន់ស្អប់ទាំងខ្លួនក៏មាន ។ បើនៅក្រុងឬ ត្រូវចូលក្នុងទីចំណោមធំដុំនោះ របៀបស្លៀកពាក់ក៏មានភាពសមរម្យ ស៊ីគ្នានឹងទីនោះឬពេលនោះដែរ ។

គ- ឲ្យចេះក្លែងខ្លួន ដោយផ្លាស់សំលៀកបំពាក់តាមទេសៈកាលៈ ដើម្បីជៀសវាងភយន្តរាយខ្លះបាន :

***ឧទាហរណ៍*** : ឧបមាដូចយើងជាអ្នកមានទ្រព្យច្រើន ត្រូវធ្វើដំណើរ ផ្លូវឆ្ងាយ ដោយកាត់ភូមិ កាត់ព្រៃផ្សៃនោះត្រូវស្លៀកពាក់ខោអាវណា ជំនុំជាមធ្យមកុំឲ្យមនុស្សខិលខូចថាយើងជាមនុស្សមានទ្រព្យសម្បត្តិ ច្រើន ហើយគុំគួនធ្វើបាប ។

ទាហានខ្លះ កាលបើធ្វើខ្លួនឲ្យប្លែកជារបៀបអ្នកស្រែហើយ ក៏អាច ចូលទៅបន្លំនៅក្បែរបន្ទាយសត្រូវបាន ដើម្បីស៊ើបការណ៍ផ្សេងៗ ឬក៏



www.elibraryofcambodia.org

ធ្វើឲ្យសត្រូវវិនាសដោយកលល្បិចរបស់ខ្លួនបាន ។ កាលបើផុតពីកន្លែងឬពេលដែលមានគ្រោះថ្នាក់ហើយ សឹមផ្លាស់សំលៀកបំពាក់តាមធម្មតាទៅ វិស័យដូចកុកសាប់ កាលបើផុតពីកន្លែងដែលរកស៊ី ឬកន្លែងដែលមានសត្រូវតែងបៀតបៀនហើយនោះឥតញញើតទៀតឡើយ និងបង្ហាញស្លាបរបស់វា ។

**សេចក្តីបញ្ចប់**

ដើម្បីធ្វើឲ្យជីវភាពរបស់ខ្លួនទទួលនូវសេចក្តីសុខកុកសាប់ជាគំរូប្រាប់ថា បើនឹងធ្វើអ្វីត្រូវឲ្យពិនិត្យមើលទេសៈកាលៈ គឺធ្វើអ្វីកុំឲ្យឆ្គៅខុសគេជានិច្ចជាកាលដូចកុកសនោះ ។ ក្នុង "សុភាសិតសង្គ្រោះ" របស់ព្រះបាឡាត់ឧត្តមលិខិតសុង- ស៊ីវ នោះក៏មានចែងមកហើយដែរគឺ "កុំត្រាប់កុកសគ្មានឧបាយ ឲ្យត្រាប់ប្រាជ្ញប្រាយសត្វកុកសាប់ រកស៊ីកៀនគោះដោយព្រៃស្ងាប់លាក់ខ្លួនខ្លាចស្លាប់គ្មានប្រមាទ" ។

**១៣-មួយសោតលោកថា កន្លង់និងផ្កា ស្ពានឆ្ងាយនិងនៃ ហេតុចិត្តចង់ក្រេប ជញ្ជក់ក្លិននៃ ហើរហួសច្រៀវច្រៃ រស់រកបុប្ផា**

ជនខ្លះមានចិត្តចង់ដឹងនូវធម៌វិន័យ ឬច្បាប់ក្បួនតម្រាវិទ្យាសាស្ត្រផ្សេងៗ ក៏ស្វះស្វែងជាអចិន្ត្រៃយ៍ រកអ្នកដែលមានប្រាជ្ញាតម្រេះវិជ្ជាមិនថានៅឆ្ងាយឬជិត ដើម្បីក្រេបជញ្ជក់យកខឹជារសនៃវិជ្ជា វិស័យដូចសត្វកន្លង់ដែលសង្វាតព្យាយាមហើរសព្វឋានដើម្បីស្កាត់រកបុប្ផា ប្រាថ្នានឹងក្រេបជញ្ជក់យកជាតិនូវក្លិននៃផ្កាទាំងឡាយនោះឯង ។



www.elibraryofcambodia.org

**១៤-លោកថាដែកផង ហៅរឹងកន្លង គេដុតជំងាន រូសកោស ជាការ តាមចិត្តប្រមាណ ពុំដែលនឹងមាន ប្រកែកឡើយណា...**

ដែកហើយហៅរឹង គង់តែដុតឲ្យក្ដៅទៅដំកើតជារាងរៅពូថៅ កាំបិទតាមចិត្តប្រាថ្នាបាន ចំណែកមនុស្សពាលដែលមានចិត្តរឹងរូស ប្រទូស្តឃោរឃៅនោះ វារឹងលើសពីដែកទៅទៀត គេមិនអាចប្រដៅវាឲ្យទៅជាល្អតាមចិត្តប្រាថ្នាឡើយ ។

ដូច្នេះហើយបានជាមាតាបិតាគ្រូអាចារ្យទាំងឡាយ ខ្វល់ខ្វាយយកចិត្តទុកដាក់ក្នុងការហ្វឹកហ្វឺនប្រៀនប្រដៅ កូនចៅដែលកំពុងនៅក្មេងតូចល្មមនឹងកាច់បង្អឹកបង្វែរ បំបែរបំបត់ពត់វាឲ្យចូលក្នុងផ្លូវល្អបាន តែបណ្តែតបណ្តោយឲ្យវារឹងត្អឹងធ្វើតាមអំពើចិត្តហើយ នោះមិនលែងឡើយ វានឹងចូលក្នុងពួកអន្ធពាលដែលគេមិនអាចនឹងផ្សាំង និងបំពត់វាឲ្យល្អបានឡើយ ។

☆☆☆



www.elibraryofcambodia.org

# សុភាសិតផ្សេងៗ

## ១៥-ទំពក់វាទៅ ទើបញ៉ោវាជ្រុះ

## ទំនងតែង

### សេចក្ដីផ្ដើម

"ទំពក់វាទៅ ទើបញ៉ោវាជ្រុះ" សេចក្ដីយ៉ាងខ្លីនេះមានអត្ថរស យ៉ាងសំខាន់ ដើម្បីនឹងញ៉ាំងចរិយាជនណាដែលខ្ជិលទំរន់ក្នុងកិច្ចការសព្វសារពើ កុំឲ្យដេកចាំតែព្រេងវាសនាជូនផលឲ្យ ។

***អត្ថាធិប្បាយរបស់ភាសិត*** :

បើយើងចង់បានផ្លែញ៉ោដែលនៅជាប់នឹងសណ្ដង់នៅឡើយ យើងត្រូវខ្វល់ខ្វាយរកទំពក់ទៅផ្ដក់ទាញយកមកទើបវាជ្រុះ ដើម្បីយកមកធ្វើជាចំណីរបស់យើង ។

បើនៅតែស្ងៀមអង្គុយចាំឲ្យផ្លែញ៉ោជ្រុះមកតែម្ដងនោះ កុំសង្ឃឹមថា នឹងបានអាស្រ័យ មុខជា"អង្គុយលេបទឹកមាត់" ហើយ ។

***អត្ថបដិរូបរបស់ភាសិត*** :

ផ្លែញ៉ោដែលយើងចង់បាននេះ គឺគេចង់និយាយពីផលឬបំណងអ្វីមួយដែលយើងប្រាថ្នានឹងឲ្យបានសម្រេចមកយើង ។ យើងមិនមែនដេកចាំឲ្យផលនេះវាត់មករកយើងទេ គឺត្រូវខំប្រឹងប្រែងខ្នះខ្នែងប្រើកំលាំងកាយ ឬកម្លាំងចិត្តដើម្បីទៅផ្ដក់យកផលនោះ វិស័យដូចគេរំខ្នុះ



www.elibraryofcambodia.org

ខ្នែងធ្វើទំពក់រួចហើយ ទំថ្កក់យកផ្លែព្នៅជាចំណី ។

*ឧទាហរណ៍* : ១-កូនសិស្សដែលប្រាថ្នាចង់បានសញ្ញាប័ត្រអ្វីមួយនោះ ត្រូវខំប្រឹងប្រែងរៀនសូត្រឲ្យណាស់ ព្រោះចំណេះដែលបានពីការខំនេះហើយជាទំពក់យ៉ាងមាំ ដើម្បីទៅថ្កក់ការយកសញ្ញាប័ត្រ ។

២-មាតាបិតាទាំងឡាយបើចង់ឲ្យរកភរិយាឲ្យកូនប្រុសតាមច្បាប់នោះត្រូវតែគិតគូរខ្នះខ្នែងរកគេឯង ឲ្យជួយស៊ើបសួរអ្នកចូលទៅដណ្តឹងដល់ម៉ែឪខាងកូនស្រី ។ បើមិនដូច្នោះទេ កូនស្រីអ្នកមានពូជពង្សមិនងាយនឹង "ជ្រុះដោយងាយទេ ទាល់តែមានទំពក់ទៅ ទើបព្នៅវាជ្រុះមក កុំសង្ឃឹមថា គេនឹងលើកឲ្យដោយងាយនោះ ។

៣-ប្រទេសកម្ពុជាដែលបានឋានៈជារដ្ឋឯករាជ្យនេះក៏មិនមែនបានមកដោយគ្មានយក "ទំពក់ទៅថ្កក់" ដែរ ។ ចុះអ្វីជាទំពក់នេះ? គឺគ្មានអ្វីក្រៅពីសេចក្តីប្រឹងប្រែងរបស់សម្តេចព្រះបិតាឯករាជ្យជាតិទេ ។ ព្រះអង្គទ្រង់ប្រើព្រះរាជនយោបាយដ៏ភ្លឺថ្លាធ្វើជាទំពក់ដើម្បីទៅថ្កក់ទាញយកឯករាជ្យជូនប្រទេសជាតិ ។

**សេចក្តីបញ្ចប់**

បើចង់ឲ្យបានផលអ្វីមួយ ដូចសេចក្តីបំណងយើងកុំនៅស្ងៀមឲ្យផលរត់មករកនោះ ត្រូវចាំឲ្យជាក់ថា : "បើចង់ស្រួចដូចបន្លាត្រូវតែឧស្សាហ៍ដុសដែកដុស ទោះមានកុសលអកុសល កុំចាំសេសផលនោះជួយជូន" ។



www.elibraryofcambodia.org

## ១៦-ម្នៅៗ យកដំរពៅមកតៀ្បតក្លៀក

## សេចក្ដីអធិប្បាយយ៉ាងសង្ខេប

ដំរពៅវាស្អិតជិតជាប់សាច់ពិបាកលាងណាស់ ហេតុនេះ គប្បីជៀសវាងកុំឲ្យដំរពៅប្រឡាក់បាន ។

ភាសិតនេះមានន័យថា នៅសុខៗ ម្ដេចក៏ទៅទទួលយកកិច្ចការណាមួយដែលដល់ទីបំផុត វាហុចផលអាក្រក់ឲ្យ នាំឲ្យពិបាកចិត្ត ពិបាកគិត ពិបាកកាយ ឥតមានផលចំណេញអ្វីដល់ខ្លួនសោះ គឺនាំតែនឿយខ្លួនអសាឥតការ ។

ដូចយ៉ាងរ៉ាប់រងធានាអ្នកជាប់ចោទពីបទណាមួយ ឬទទួលបញ្ញើអ្នកណាមួយ ដល់ថ្ងៃក្រោយមកទៀត ទើបដឹងថាជារបស់ចោរ ឬក៏ទទួលក្មេងណាមួយមកចិញ្ចឹម បង្កើតហេតុឲ្យទាស់ទែងខ្វែងគំនិតប្ដីប្រពន្ធឯង ។ កាលបើឃើញផលអាក្រក់ផុសឡើងវេលាណា ទើបលាន់មាត់ទាំងស្ដាយហើយខ្នាញ់ក្នុងចិត្តផងថា "ម្នៅៗយកដំរពៅមកតៀ្បតក្លៀក" ។

កាលបើដឹងដូច្នេះហើយ ក្នុងការអ្វីក៏ដោយ មុននឹងទទួលធ្វើ គប្បីពិនិត្យពិចារណារកហេតុផលជាមុនដរាប ឲ្យយល់ជាក់តើនឹងបានសុខឬទុក្ខទៅថ្ងៃក្រោយ ។



www.elibraryofcambodia.org

## ១៧-ឆ្កែខាំឲ្យរកម្ចាស់ គោឆ្កឹះឲ្យរកនាយ

# ទំនងតែង

## សេចក្តីផ្តើម

បើទុកជាធ្វើត្រូវក៏តែងធ្លាក់ក្នុងផ្លូវខុសវិញដែរ ជនណាដែលធ្វើអ្វីមិនពិចារណាឲ្យជ្រៅជ្រះ មិនចេះអត់សង្កត់ចិត្តរំលត់ក្តីមោហៈ ។ ការដែលយក "កំហល់ទល់កំហែង" គឺខំច្រឡោតមិនគិតមុខគិតក្រោយតែងបង្កើតទុក្ខទោសដល់ខ្លួនជាញឹកញាប់ ដូច្នេះហើយបានជាបុរាណណាចារ្យទូន្មានថា "ឆ្កែខាំឲ្យរកម្ចាស់ គោឆ្កឹះឲ្យរកនាយ" ដែលជាភាសិតសន្មតថាជាច្បាប់ទូន្មានខ្លួន ។

*__អត្ថាធិប្បាយរបស់ភាសិត__* :

ឯឆ្កែនិងគោនេះវាមានម្ចាស់ ។ កាលបើឆ្កែវា "ខាំ" ឬគោវា "ឆ្កឹះ" កុំទៅវាយដំវាយ ឬសម្លាប់វា ព្រោះជាសត្វមានម្ចាស់ ។ កាលបើម្ចាស់សត្វនេះដឹងថា យើងវាយសត្វគេនោះ គេត្រឡប់ជាស្តីបន្ទោសយើងវិញ ឬបើវាសត្វទាល់តែបែកបាក់ ឬទាល់តែស្លាប់ផង នោះនឹងសងសោហ៊ុយគេពេញទី ។

ដូច្នេះកាលបើឆ្កែខាំ ឬគោឆ្កឹះ តោងរកម្ចាស់ឲ្យគេជួយរកថ្នាំបិទឬជួយចេញសោហ៊ុយថ្លៃការថែស្នាមរបួសនោះ ដោយអ្នកម្ចាស់សត្វនេះប្រហែលមិនបានឃ្លុំមាត់ឆ្កែ ឬចងឲ្យជាប់ ឬមិនបានចងគោឲ្យមាំ ឬបង្ខាំងវាទុកក្នុងក្រោលខ្លួន ។



www.elibraryofcambodia.org

*អត្ថបរិយាយរបស់ភាសិត* :

កាលបើមានរឿងនឹងកូនក្មេង ដោយវាប្រមាទក្នុងការផ្សេងៗ (ធ្វើឲ្យឈឺចិត្ត ឬធ្វើឲ្យមានស្នាមរបួស) នោះត្រូវរកឪពុកម្តាយ ឬគ្រូអាចារ្យ ឬអ្នកដែលទទួលភារៈគ្រប់គ្រងវា ឬជេរស្តីប្រដៅ ដើម្បីផ្សះជម្ងឺនេះ ។ សូម្បីតែបាវព្រាវរបស់គេក៏តោងតែរកនាយចៅហ្វាយវាឲ្យជេរស្តីប្រដៅដែរ ។

បើមានភ្នាក់ងារក្រសួងណាមួយប្រមាថមើលងាយ ដោយអាការៈផ្សេងៗ នោះត្រូវរកនាយចៅហ្វាយភ្នាក់ងារនោះឲ្យជួយផ្សះផ្សា លប់លាងរឿងហេតុទាំងសងខាង គឺឲ្យស្រួលចិត្តទាំងអ្នកទទួលគ្រោះ ស្រួលចិត្តទាំងអ្នកប្រព្រឹត្តល្មើសវិស័យដូចរកម្ចាស់សត្វ ឲ្យរកថ្នាំបិទរបួស ហើយឲ្យប្រយ័ត្នកុំលែងសត្វកាចឲ្យខាំឲ្យឆ្កេះគេទៀតដែរ ។

ភាសិតនេះ មានន័យទំលំទូលាយទៅទៀតថា បើព្រឹត្តិការណ៍អ្វីមួយ ឬរឿងហេតុអ្វីមួយកើតឡើងហើយ ត្រូវស្រាវជ្រាវរកបុព្វហេតុដែលនាំឲ្យកើតជារឿងនោះឡើង ដើម្បីខំប្រឹងប្រែងផ្សះផ្សារំលត់នូវបុព្វហេតុនោះ កុំឲ្យរឿងហេតុរាលដាលវែងឆ្ងាយទៅទៀត ។

## ១៨-ជាងខុំមិនកើតទៅចន្លោសដែក

កាលបើធ្វើការអ្វីមួយ មិនបានផល មិនបានល្អ គេតែងតែរករឿងដោះស្រាយ នាយអាចថាដូច្នេះដូច្នោះ ឬក៏ថាមានឧបសគ្គនេះនោះបណ្តាលឲ្យធ្វើការមិនស្រួលឲ្យខូចការអស់ ដើម្បីសំរាលទោសរបស់ខ្លួន



www.elibraryofcambodia.org

ដើម្បីកុំឲ្យអ្នកដទៃគេបន្តុះបង្អាប់ថាខ្លួនមិនកើតមិនប្រសប់ មិនវៃ មិនចេះ វិស័យដូចជាងដែក កាលបើធ្វើកាំបិតមិនស្មើមុខមិនស្រួចមុត ឬមិនសមរាង ថាមកពីដែកមិនស្រួចសុទ្ធដែរ ។

*ឧទាហរណ៍* : ១- សិស្សប្រឡងមិនជាប់ ថាមកពីថ្ងៃនោះស្តាប់គ្រូហៅសរសេរតាមសូត្រមិនច្បាស់ ឬក៏ថាមកពីពេលវាខ្ជីរៀនមិនបានសព្វគ្រប់ ។

២- មេចុងភៅដាំបាយមិនបានឆ្អិនល្អ ថាមកពីអង្ករមិនស្រួលល្អ ។ បើម្ហូបមិនឆ្ងាញ់ ថាមកពីឧសមិនស្រួលស្ងួត ភ្លើងមិនឆេះ ។ល ។

## ១៩- មានះបាត់មិត្ត ឥតអ្នកជាផៅ ក្រេវក្រោធឃោរឃៅរមែងបាត់អង្គ

*វគ្គទី១* : **មានះបាត់មិត្ត ឥតអ្នកជាផៅ**

នរណាដែលមានះ គឺមានចិត្តរឹងត្អឹងរបឹងចចេសកម្រព្រមព្រៀងទោរទន់ធ្វើតាមមតិ ឬពាក្យទូន្មាននៃអ្នកដទៃនេះឯង រមែងតែង "បាត់មិត្ត" គឺគ្មានមិត្តចង់មូលចូលគំនិតជាមួយ ឬបើមានមិត្តមកហើយ ក៏មិនលែងបាក់បែកគ្នាមិនខាន ព្រោះសេចក្តីមានះនេះ ធ្វើឲ្យខូចការសាមគ្គីរវាងគ្នានឹងគ្នា ។

ដែលថា "ឥតអ្នកជាផៅ" គឺបើមានះហើយកុំថាឡើយ បាក់តែត្រឹមមិត្ត សូម្បីតែបងប្អូនញាតិសាលោហិតដែលជាពូជអម្បូរជាមួយ ក៏មិនចង់មូលគំនិតរួមចិត្តយកធ្វើជាគ្នាដែរ ។

*វគ្គទី២* : **ក្រេវក្រោធឃោរឃៅរមែងបាត់អង្គ**



www.elibraryofcambodia.org

មនុស្សខឹងខ្លាំង ពាលកំណាចកាចហួសប្រមាណបំពារបំពានគ្មានថយចិត្ត គំនិតរឹងរូសប្រទូស្ត ខឹងឃោរឃៅរបញ្ញោរខុសច្បាប់ទម្លាប់នោះរមែងបាត់អង្គ គឺតែងវិនាសខ្លួន ស្លាប់ខ្លួនថ្ងៃណាមួយ ពីព្រោះពួកសាហាវកំណាចនេះជាទីគំនុំ ជាទីសំអប់របស់ពួកជនទាំងឡាយ ។

**២០-អ្នកមានកុំអាលអរ អ្នកក្រកុំភ័យ**

## សេចក្តីអធិប្បាយជាគំរូ

"អ្នកមានកុំអរ អ្នកក្រកុំភ័យ" ជាពាក្យព្រេងតែងឮជាលំដាប់មកសំរាប់ដាស់តឿន ជនានុជន ទាំងអ្នកមាន ទាំងអ្នកក្រឲ្យប្រុងប្រយ័ត្នក្នុងការខ្នះខ្នែងរកទ្រព្យសម្បត្តិ ហើយនឹងក្នុងការរក្សាធនធាន ដែលមានហើយ ។

ក្នុងវគ្គទីមួយលោកថា "អ្នកមានកុំអរ" គឺលោកប្រដៅអ្នកមានទ្រព្យសម្បត្តិ ឲ្យចេះព្រួយបារម្ភក្នុងការថែរក្សាធនធាន ព្រោះអ្នកមានទ្រព្យខ្លះដោយអាងថាខ្លួនមានបរិបូណ៌ហើយ ក៏ធ្វើព្រងើយកន្តើយពុំគិតគូរនឹងរកទ្រព្យសំចៃតទៅទៀត ពុំខ្លាចក្រែងដល់គ្រាក្រោយនឹងមានអាសន្នអន្ធក្រ ហើយគិតតែត្រេកអរហ៊ឺហាវាយឫកលើកកំពស់ ជួនកាលពុំមានចិត្តមេត្តាករុណាដល់អ្នកកំសត់ទុគ៌តឡើយ ម្ល៉ោះហើយអ្នកក្រតែងពោលជាពាក្យផ្តន្ទាថា : "អ្នកមានកុំអាលអរ ក្រែងធ្លាក់ក្រទៅថ្ងៃក្រោយ" ។

ក្នុងវគ្គទីពីរលោកថា "អ្នកក្រកុំភ័យ" ពាក្យនេះបានសេចក្តីថា បើ



www.elibraryofcambodia.org

ជនណាក្រហើយ មិនត្រូវព្រួយចិត្តអស់សង្ឃឹមគិតថាខ្លួននឹងក្រមួយជីវិតឡើយ ត្រូវគិតថា ថ្ងៃណាមួយ មុខជានឹងបានប្រទះលាភអ្វីមួយយ៉ាង ។ ពាក្យព្រេងនេះលោកចង់ទុកមកសម្រាប់សំរាលចិត្តអ្នកខ្សត់ទុគ៌ត កុំឲ្យមានទុក្ខភ័យពេកនឹងការក្រីក្ររបស់ខ្លួន ហើយសម្រាប់កំឡាទឹកចិត្តអ្នកក្រឲ្យខំធ្វើការរកស៊ីឲ្យពេញកំលាំងឡើង ។

យើងក៏បានដឹង បានឃើញជាញឹកញយណាស់មកហើយថា មានមនុស្សខ្លះមានភោគសម្បត្តិច្រើន ប្រហែលទ្រព្យមហាសេដ្ឋីមួយ មិនយូរប៉ុន្មានគាប់ជួនមានសេចក្តីអកុសលមកផ្តល់កាយ ទ្រព្យនោះក៏រលាយខ្ចាយខ្ចាត់រសាត់បាត់សូន្យទាំងកិត្តិយសកេរ្តិ៍ឈ្មោះផង ។ មានមនុស្សខ្លះទៀត ខ្សត់ខ្សោយដោយទ្រព្យធនធាន គ្មានអ្វីជាទីពឹងបង្អែកសោះ ប៉ុន្តែក្រោយមក ស្រាប់តែបានងើបរួចពីក្រលំបាក ទៅជាមានមុខមាត់មួយនឹងគេ ដោយអ្នកនោះឯងព្យាយាមធ្វើការចេះសំចៃទុក នេះប្រការមួយ ខ្លះទៀតក៏កើតមានបានដោយសារសំពាយព្រេងរបស់ខ្លួន នេះប្រការពីរ (ដូចយ៉ាងអ្នកក្រខ្លះត្រូវឆ្នោតជាតិជាដើម) ។

អ្នកមានទ្រព្យទាំងឡាយអើយត្រូវចាំថា "កើតជាមនុស្សនេះ ដូចកាំរទេះវិលត្រូវគ្រប់គ្នា ជួនកាលត្រូវគេល្វែងអាត្មា ..." ពោលគឺកុសលនិងអកុសលជាការមិនទៀងទាត់ ក្នុងពេលនេះ ខ្លួនអ្នកមានទ្រព្យ ក្នុងពេលក្រោយ គេនឹងមានទ្រព្យវិញក៏មិនដឹង កុំអាងតែខ្លួនមានធនធានហើយ ក៏ចេះតែសប្បាយរីករាយពុំមានចិត្តអាសូរករុណាដល់អ្នកក្រីក្រលំបាកនោះ ។



www.elibraryofcambodia.org

ឃើញគេក្រកុំមើលងាយគេ ព្រោះក្រែងថ្ងៃក្រោយ ខ្លួនឯងធ្លាក់ក្រវិញ នឹងបានទទួលសេចក្តីផ្តន្ទាច្រើន ។ ចំណែកអ្នកក្រវិញ ត្រូវចាំថា "ការរស់នៅ គឺជាការប្រយុទ្ធមួយ" ដូច្នេះត្រូវក្រោកឡើង កុំរួញរាម៉ឺម្នាតយុទ្ធនឹងការលំបាក ដើម្បីឲ្យមានជ័យជំនះយ៉ាងថ្លៃថ្នូរ ដោយចេះប្រឹងបំរះឲ្យផុតភ័យពីក្តីក្រ ។

## ២១- កុំចំពត់ស្រឡៅ កុំដៅមនុស្សខូច

ស្រឡៅជាឈើមួយយ៉ាង ដែលគេមិនអាចនឹងបំពត់ ឬបង្កោងតាមបំណងបានឡើយ ។ លោកថា កុំពត់ស្រឡៅដូច្នេះ ព្រោះជាការនាំឲ្យខាតពេលបង់តែកម្លាំងឥតអំពើ ។

ដរាបណា ដែលស្រឡៅនេះគេបំពត់មិនបាន ដរាបនោះមនុស្សខូចមនុស្សពាល ក៏គេបំបែរបំបត់ពត់វាឲ្យចូលផ្លូវល្អមិនបានដែរ វាមិនទោរទន់ទៅបានដោយសេចក្តីទូន្មានរបស់អ្នកល្អទេ ព្រោះកម្លាំងពាលនេះ វាផ្តួចផ្តុះចុះចាប់ក្នុងចិត្តវាពីកំណើតមកហើយ ។ គេពិបាកនឹងវាយដែកគោលច្រេះឬវៀចឲ្យចូលក្នុងសាច់ឈើ ណាមិញ មនុស្សខូចក៏ពិបាកនឹងណែនាំវាឲ្យចូលផ្លូវល្អដែរ ។ ក្នុងច្បាប់កូនចៅលោកក៏បាននិយាយដែរត្រង់ការពិបាកនឹងប្រដៅពួកពាលនេះ លោកថា "ពាលប្រទូស្តប្រទះរឹងរូស ពុំលុះប្រដៅ រឹងលើសពីដែក និងដីរីនៅ ដោយអ្នកកម្លៅកម្លាំងមោហោ" ។



www.elibraryofcambodia.org

## ២២-ត្រុកៗ អ្នកស្រុកមើលងាយ រលាស់គូថខ្វាយមានឱតមានភាន់

អ្នកខ្លះមានជំរេះវិជ្ជា ឬសំដីថ្វីមាត់ស្ទាត់ពូកែ ប៉ុន្តែធ្វើឫកពាកិរិយា ត្រុកៗ មិះៗ ញើបៗ ហាក់ដូចគ្មានចេះគ្មានដឹងអ្វីសោះ ដោយហេតុនេះ អ្នកផងក៏មើលងាយ លុះពេលវេលាដល់ហើយ អ្នកនោះឯងក៏ "រលាស់គូថខ្វាយ" គឺសំដែងចំណេះវិជ្ជា ឬបញ្ចេញសំដីថ្វីមាត់យ៉ាងជំនាញ "មានឱតមានភាន់" គឺមានរបៀបបែបបទប្រាកដច្បាស់ ធ្វើឲ្យអ្នកផងទាំងពួង ស្ងើចសរសើរគោតក្រែងរអែងចិត្ត លែងហ៊ានមើលងាយទៅទៀត ហើយក៏ទៅជាទីទុកចិត្ត ជាទីរាប់អាននៃជនទាំងឡាយទៅ ។

## ២៣-ដំរីសារស្លាប់ យកចង្អេរបាំង

### ចំណងជើង

### សេចក្តីផ្តើម

កំហុសដែលបានប្រព្រឹត្តហើយ មិនងាយនឹងបិទបាំងឲ្យជិតឡើយ ដូច្នេះហើយបានជាគេតែងនិយាយចំអកឲ្យអ្នកប្រព្រឹត្តខុសថា "ដំរីសារស្លាប់ យកចង្អេរបាំង" ។

***<u>អត្ថន័យរបស់ភាសិត</u>*** :

ដំរីសារគឺដំរីដែលធំដល់កំណត់ ។ កាលបើដំរីនេះស្លាប់ គេមិនអាចនឹងបិទបាំងសាកអសុភ ឬក្លិនអសោចន៍របស់វាជិតដោយយកចង្អេរមួយទៅប្រើការបានឡើយ ព្រោះចង្អេរមានទំហំតូចជាងឆ្ងាយណាស់ ។



www.elibraryofcambodia.org

***អត្ថបដិរូបរបស់ភាសិត*** :

ដំរីសារស្លាប់ គឺកំហុសអ្វីមួយយ៉ាងធំ ។ យកចង្អេរបាំង គឺប្រើមធ្យោបាយណាមួយដែលរាក់ៗ ទៅបិទបាំងលុបលាងកំហុសចេញ ។ ដរាបណាដែលចង្អេរបាំងខ្មោចដំរី ឬក្លិនសំអុយមិនជិត ដរាបនោះគលល្បិចបន្តិចបន្តួច ក៏មិនអាចបាំងបាត់នូវកំហុស ឬចំណាយអាក្រក់នៃរឿងរ៉ាវដែលបានប្រព្រឹត្តមកហើយនោះដែរ ។

***ឧទាហរណ៍*** : កាលពីយូរឆ្នាំមកហើយ មេឃុំមៀនបានឃុំឃាំងនាយស៊ុំ ដែលប្រព្រឹត្តបទល្មើសដោយទាន់ជាក់ស្តែង ។ នាយ ស៊ុំ នេះកាលពីថ្ងៃមុន មានរឿងទាស់ទែងម្តងនឹងមេឃុំនោះឯង ។ ក្នុងវេលារាត្រីស្ងាត់ មេឃុំមៀនចូលទៅក្នុងបន្ទប់រករឿងវាយនាយស៊ុំតែពីរបីដំបង ស្រាប់តែស្លាប់ភ្លាម ។ ដើម្បីបិទបាំងកំហុសដោះខ្លួនឲ្យរួចពីទោសភ័យនោះ មេឃុំកំណាចក៏ដោះអាវនាយស៊ុំ រួចចងកខ្មោចយ៉ាងតឹង ភ្ជាប់ទៅនឹងជើងតុក្នុងបន្ទប់នោះ តើមេឃុំគេចកែបំបែរបំបិទឯណានឹងជិត បើគេដឹងថាខ្លួនឯងជាអ្នកកាន់កូនសោបន្ទប់ បើពេទ្យពិនិត្យឃើញសាច់ស៊ុំជាំដោយដំបង ហើយគ្មានទំនងនឹងជឿថា ស៊ុំចងកខ្លួនឯងផង ។ រឿងប៉ុនដំរីសារ យកឯការតូចប៉ុនចង្អេរទៅបំបាំងកុំឲ្យស្អុយ ។ កាលបើបានធ្វើឃាតកម្មយ៉ាងស្តែងដូច្នេះហើយ មេឃុំមៀនភ័យខ្លាំងខ្លាចជាប់គុក ក៏យកឯចេកមួយស្ទង និងខ្នុរពីរទៅជូនចៅក្រមឲ្យគេជួយ ។ នរណានឹងជួយរួចបើទោសឯងប៉ុនដំរីសារ ហើយយកឯចង្អេរទៅបំបាំងនោះ គប្បីណាស់ជួលមេធាវីតក្តីទៅគ្រាន់សង្ឃឹមថា នឹងបានរួចខ្លួនខ្លះ!



www.elibraryofcambodia.org

*សំគាល់* : ក- ដីរីសារស្លាប់នេះ សំដៅយកកំហុសណាមួយយ៉ាងធំ ដូចសម្លាប់គេ ប្លន់គេ ចាប់ស្រីមិនទាន់គ្រប់ការ... សរុបទៅគឺបទល្មើស ទាំងឡាយដែលអាចធ្វើឲ្យអ្នកដទៃដល់ជាប់គុកជាទម្ងន់បាន ក្នុងច្បាប់ តុលាការ ។ កំហុសនេះមិនងាយនឹងលុបលាងបានដោយងាយទេ ដូច្នេះ កាលបើដឹងថា អំពើអាក្រក់ទាំងឡាយពិបាកនឹងបិទបាំងហើយ វាតែង ហុចទុក្ខទោសមកដល់ខ្លួនវិញ ត្រូវតែជៀសឲ្យផុត កុំប្រព្រឹត្តឲ្យសោះ ទើបប្រសើរជាង ។

តែបើបានជាថ្លស់ធ្លោយ ធ្លាក់ខ្លួនត្រឹបក្នុងកំហុសធំនេះហើយ គប្បី រិះរកកលឧបាយយ៉ាងចំណាន ដើម្បីឲ្យមានកម្លាំងទប់ទល់កុំឲ្យជាប់គុក បាន ពោលគឺធ្វើដូចម្ដេចកុំឲ្យគេចំអកបានថា : "ដីរីសារស្លាប់" ទៅយកឯ "ចង្កេះមកបាំង" ។

ខ-ម្យ៉ាងទៀតពាក្យចាស់នេះសម្រាប់និយាយចំអកឡកឲ្យជនណា ដែលមានញាតិផៅ ប្រព្រឹត្តខុសជ្រុលហើយ ខំនិយាយដោះស្រាយ នាយអាយដើម្បីលាក់លៀមលុបលាងកំហុសនោះ ដូចយ៉ាងឪពុកម្ដាយ ខ្លះ ខំបិទបាំងកូនស្រីដែលមិនមានកិរិយាទួនសមរម្យជាស្រីគ្រប់ លក្ខណា តើបិទបាំងដោយសំដីឯណានឹងជិត បើកំហុសនោះវាធំហើយ ចោលក្លិនអសោចន៍បីដូចជាដីរីសារស្លាប់ទៅហើយនោះ ។

## ២៤- ដំបៅមិនឈឺ យកឈើចាក់

បើទុកជាដំបៅមិនឈឺក៏ដោយ កាលបើគេយកឈើទៅចាក់ឆ្កេះវា



www.elibraryofcambodia.org

មុខជាចេញឈាមកើតហើមដែរ ពោរសាច់ឈឺចាប់ជាមិនខាន ។

ចំណែករឿងរ៉ាវណាមួយដែលមានមកហើយ បើទុកជាមិនបង្កើតសេចក្តីឈឺចាប់យ៉ាងណាក៏ដោយ កាលបើគេចេះតែរករឿងចាក់ដោតឆ្កឹះកកាយដោយពាក្យសំដី ឬអាកប្បកិរិយាផ្សេងៗ នោះរឿងនេះនឹងរាលដាលកើតជាធំនាំឈឺចាប់ជាមិនខាន ។

## ២៥-គោដំបៅខ្នង ក្អែកហើររំលង រំសាយកន្ទុយ

## ទំនងតែង

### សេចក្តីផ្តើម

ដើម្បីធ្វើឲ្យយើងចេះសង្កេតលក្ខណៈរបស់ពួកទុរជនដែលតែងតែប្រើអាកប្បកិរិយាផ្សេងៗ ដើម្បីលាក់ពុតកំហុសរបស់វា បុរាណបណ្ឌិតបានចងជាភាសិតមកថា :

**" គោដំបៅខ្នង ក្អែកហើររំលង រំសាយកន្ទុយ "**

***អត្ថាធិប្បាយរបស់ភាសិត*** :

កាលបើមានដំបៅខ្នងហើយ គោតែងស្រៀវជានិច្ចខ្លាចក្រែងក្អែកទំចឹកចោះ ម្ល៉ោះហើយកាលបើឃើញក្អែកហើររំលងពីលើក៏តាំង " រំសាយកន្ទុយ " គឺលើកកន្ទុយគ្រវីចុះឡើង ដើម្បីការពារវាំងបិទបាំងដំបៅ មិនឲ្យក្អែកចុះទំលើខ្នងនាំប៉ះពាល់ដល់ដំបៅ ។

***អត្ថបរិយាយរបស់ភាសិត*** : ក-ជនណាដែលបានប្រព្រឹត្តបទអាក្រក់ ឬកំហុសអ្វីមួយ តែងតែខំបិទបាំងអំពើដ៏លាមកទាំងនោះ ដើម្បីនឹង



www.elibraryofcambodia.org

ជៀសវាងពាក្យនិន្ទា ជៀមដាមរបស់គេ តែបើគាប់ជួនជាហេតុ "សត្វក្អែកមួយហើររំលងកំហុសខ្លួន ពោលគឺមានពាក្យណាមួយដែលនិយាយទៅហើយមានទំនងទាក់ទង នឹងរឿងរ៉ាវដែលខំលាក់លៀមនោះ អ្នកនោះឯងរមែងតែងនឹងស្រៀវរអៀសខ្លួនជាដរាប មានប្រើអាការៈផ្សេងៗ ដូចជាខំនិយាយពង្វាងបង្វែរកែសេចក្ដីឲ្យបានល្អដល់ខ្លួន ដើម្បីកុំឲ្យប៉ះពាល់ "ដំបៅ" ខ្លួន ហើយកុំឲ្យគេសង្ស័យថាខ្លួនមានកំហុសអ្វី? វិស័យដូចគោខំ "**រំសាយកន្ទុយ**" ដើម្បីជាកិច្ចរាំងរាការពារដំបៅនឹងក្អែកដែរ ។

ខ-ក្នុងបញ្ហានេះ គេអាចយល់បានថា : ក្អែកជាសត្វដែលតែងតែស្វះស្វែងរកចោះចឹកដំបៅ ឬគំរង់ កាលបើឃើញគោរំសាយកន្ទុយហើយ ក៏អាចដឹងភ្លាមថាគោមានដំបៅជាដាច់ខាត ។ ក្អែកនេះមានការប្រៀបធៀបទៅនឹងភ្នាក់ងារនៃក្រុមស៊ើបអង្កេតរកពួកទុរជន ។ ពួកទុរជននេះ ដោយខ្លួនឯងជាអ្នកមានដំបៅស្រេចទៅហើយ ក៏តែងតែប្រើអាកប្បកិរិយាផ្សេងៗ ដើម្បីបិទបាំងកំហុសខ្លួនជាហេតុធ្វើឲ្យគេយល់ជាក់ថា មានប្រើកិរិយាលាក់ដំបៅជាប្រាដក ។ ដូច្នេះគេអាចនឹងស្គាល់បានដោយងាយនូវពួកគោដំបៅខ្នង ឬពួកមនុស្សលាក់កំហុសឯង ។

<u>*ឧទាហរណ៍បញ្ជាក់*</u> : ភរិយាមន្ត្រីម្នាក់តែងលួចលាក់លេងបៀរ នៅក្បែរផ្ទះខ្លួនរាល់ពេលដែលប្ដីចេញទៅធ្វើការ ។ ថ្ងៃមួយភ្ញៀវម្នាក់មកលេងផ្ទះមន្ត្រី ហើយនិយាយលេងពីនេះពីនោះទៅ ស្រាប់តែធ្លាក់ដល់



www.elibraryofcambodia.org

សំដីមួយថា : "ខ្ញុំឮថានៅជិតផ្ទះលោកនេះ មានគេលេងបៀរច្រើន ខ្ញុំកោតហើយគេអាចអង្គុយលេងវាស់ៗល្ងាចបាន មិនចេះឈឺខ្នង ឈឺចង្កេះ" ។ ឯភរិយាមន្ត្រីដែលរអៀសខ្លួន ព្រោះមានជំពៅស្រេចមកហើយ ក៏តាំងឆ្លើយតបភ្លាមតាំងពីផ្ទះបាយមកថា : "យីលោកបានដំណឹងពីណាថានៅជិតនេះ មានលេងបៀរនោះម្ដេចក៏ខ្ញុំនៅជិតមិនដឹងនរណាអើយចេះតែនិយាយផ្ដេសផ្ដាសសំអុយឈ្មោះគេយ៉ាងនេះ!" ។ នេះហើយសំដីស្រីអ្នកល្បែងដែលមានកិរិយា "**គោរំសាយគន្ទុយ**" បិទបាំងរាំងរាការពារកុំឲ្យគេឃើញជំពៅខ្លួន ។

## សេចក្ដីបញ្ចប់

បញ្ហានេះបង្គាប់ឲ្យរៀនសង្កេតរកសេចក្ដីពិត គឺប្រាប់ថានរណាដែលមានជំពៅក្នុងខ្លួនហើយ មិនងាយនឹងលាក់លៀមឲ្យបានជិតឡើយ ។

## ២៦-គេខុសកុំអាលអរ គេសាធរកុំអាលអួត

***វគ្គទី១*** : "**គេខុសកុំអាលអរ**"

កាលបើឃើញគេប្រព្រឹត្តអ្វីខុស កុំអាលអរ ព្រោះក្រែងថ្ងៃណាមួយកំហុសនឹងធ្លាក់មកលើខ្លួនវិញ ។ កាលបើឃើញគេខុសគប្បីយកកំហុសនោះមកពិចារណាត្រិះរិះរកហេតុផលឲ្យឃើញ ដើម្បីជាគតិនាំយើងឲ្យជៀសវាងបាននូវកំហុសនោះ ឬបើពុំនោះសោត គប្បីដាស់តឿនពន្យល់អ្នកប្រព្រឹត្តខុសឲ្យកែប្រែគំនិតមារមាទចេញ ដើម្បីសេចក្ដី



www.elibraryofcambodia.org

ចំរើនដល់មនុស្សជាតិ ។

*វគ្គទី២* : "គេសាទរកុំអាលអួត"

កាលបើឃើញគេសាទរ គឺត្រេកអររួសរាយរាក់ទាក់មករកយើងនោះ កុំអាលអួតសរសើរភ្លាម ព្រោះមានមនុស្សខ្លះសំដីល្អរាក់ទាក់មែនតែចិត្តគ្មានស្មោះសល្អស្អាតទេ ជួនកាលគេប្រើវាចាចរិយារាក់ទាក់ដើម្បីជាផ្ទាក់យកផលប្រយោជន៍របស់គេក្នុងការផ្សេងៗ ។

ដែលនឹងអួតសរសើរថាល្អបាន ល្គិកណាតែពិនិត្យសង្កេតក្នុងពេលដ៏យូរ ។ កាលបើសង្កេតឃើញច្រើនដងច្រើនគ្រា ថាគេត្រេកអរសាទររាក់ទាក់ដោយស្មោះចំពោះនោះ គប្បីអួតសរសើរថាល្អចុះ ។

## ២៧-អណ្តើកនៅជើង បាច់អីក្តក់ផ្តែ

## សេចក្តីអធិប្បាយជាគំរូ

មានជនណាខ្លះព្យាយាមណាស់ ក្នុងការស្វះស្វែងរកលាភ តែមិនសូវមានបញ្ញាស្មារតីវាងវៃ ដើម្បីក្រសោបយកលាភដែលជួបប្រទះនោះឲ្យបានមក ឬជួនកាលទទួលលាភហើយ តែមិនបានពេញបរិបូណ៌ ជាហេតុមួយធ្វើឲ្យអ្នកប្រាជ្ញនឹកឃើញលើកជាបញ្ហាទូន្មានថា : " អណ្តើកនៅជើង បាច់អីក្តក់ផ្តែ"

អណ្តើកជាទីស្វះស្វែងរបស់ព្រាន ។ កាលបើឃើញអណ្តើក "នៅជើង" គឺនៅបង្កើយជិតនឹងខ្លួនហើយចាំបាច់ហៅផ្តែមកជួយអ្វីទៀត គប្បីចាប់ដាក់ជាលភ្លាមទៅ ។ បើរវល់តែងាយ "ក្តក់ផ្តែ" គឺហៅផ្តែឲ្យ



www.elibraryofcambodia.org

ជួយស្ដាក់ ប្រយ័ត្នក្រែងអណ្ដើករត់ទៅបាត់ ឬបើទុកជាក្ដក់ហៅផ្ដែមក ក៏មិនជាមានប្រយោជន៍អ្វី ព្រោះជាការល្មមធ្វើបានតែឯងហើយ ។ ឧបមា បើផ្ដែនេះជាមនុស្សវិញ កាលបើបានអណ្ដើកមក យើងនាំពិបាក ទើសទាល់ចែកចំណែកជាសគុណទៅគេទៀត ។

អណ្ដើកនេះ គឺជាលាភផ្សេងៗ ដែលយើងស្វះស្វែងរក ។ ចុះបើ ប្រទះពើបពះនឹងលាភ ដែលល្មមនឹងទទួលយកផលបានខ្លួនឯងហើយ ចាំបាច់អីទៅក្ដក់ហៅគេឯងឲ្យជួយទៀត ត្រូវចាប់យកភ្លាមទៅ ព្រោះ លាភ "នៅនឹងជើង" សោះ ។ បើរវល់តែងាយហៅគេឯងប្រយ័ត្នក្រែង លាភវារលាយបាត់ទៅវិញ ឬមួយបើយើងហៅគេឯងមកនោះ កាលបើ បានលាភហើយ តោងតែបែងចែកជាចំណែកទៅគេទៀតជាកំរៃ ជាស គុណដល់គេទទួលលាភវាតិចផង ច្បាស់ជាសល់មកយើងដោយស្ដួច ស្ដើង ។

ការធ្វើជំនួញគឺការស្វែងរកលាភ ប៊ីដូចព្រានស្វែងរកអណ្ដើក ដែរ ។ ចុះបើឃើញចំណេញលើគោក ដូចអណ្ដើកនៅជើងហើយ ល្មម នឹងធ្វើខ្លួនឯងកើតចាំបាច់ក្ដក់ហៅនរណាទៀត ម្ដេចមិនចង្រ្កុបយក លាភទៅ ។

បុរាណសុភាសិតនេះមិនមែនបង្គាប់ជនទាំងឡាយ ឲ្យប្រព្រឹត្តបទ អត្តទត្តភាពគឺភាពជាអ្នកប្រាថ្នាតែប្រយោជន៍ចំពោះខ្លួនឯងតែម្នាក់នោះ ទេ គឺទូន្មានយើងឲ្យចេះប្រុងប្រយ័ត្នក្នុងការស្វែងរកលាភកុំប្រទះលាភ ហើយនៅទីមទាម មិនរៀសរៀងចាប់យកលាភនោះ រវល់តែក្ដក់ហៅ



www.elibraryofcambodia.org

គេឯងឲ្យរលាយទ្រព្យ ឬសល់លាភតិចទៅវិញដោយហេតុផ្សេងៗ ។ តែបើសិនជាយល់ឃើញថាលាភនោះវាពិបាកនឹងក្រសោបយក នោះក្នុងការសព្វសារពើ ហើយច្រើនតែក្នុងពាណិជ្ជកម្មផង តោងរកគ្គក់ហៅគ្នីគ្នា"បង្រួមកម្លាំង" ទៅត្រងយកលាភនោះឲ្យបានស្រួលដែរ ។

## ២៨-គ្នាច្រើនអន្សមខ្លោច គ្នាដូចស្រមោចអន្សមនៅ

ពិតមែនតែមានមនុស្សច្រើនដូចស្រមោច អន្សមគង់នឹងខ្លោច ឬនៅ បានដោយមិនដឹងជានរណា ត្រូវថែភ្លើងនិងទឹកស្ងោរអន្សមនោះឲ្យប្រាកដប្រជា ។

ភាសិតនេះមានន័យទូលាយឆ្ងាយទៅទៀត ។ គេច្រើនពោលពាក្យនេះនៅពេលដែលឃើញថាការណា ដែលមានមនុស្សធ្វើច្រើនគ្នាទៅជាមិនបានផលល្អទៅវិញ ឬក៏ខូចខាតអសារបង់ដោយមកពីអ្នកធ្វើការទាំងនោះរវល់តែប្រចាំគ្នាទៅវិញទៅមក ឬក៏សំអាងថាអ្នកនេះធ្វើហើយអ្នកនោះធ្វើហើយ ។

ដូច្នេះក្នុងការគ្រប់ជំពូក កាលបើមានមនុស្សធ្វើច្រើន ត្រូវឲ្យមានរបៀបរៀបរយក្នុងកិច្ចចាត់ការនោះ ពោលគឺត្រូវឲ្យចេះចាត់ចែងមុខការដោយឡែកៗ ហើយជ្រើសតាំងក្នុងបណ្ដាមនុស្សទាំងអស់នោះឲ្យធ្វើជាមេកោយដោយប្រាកដប្រជា គឺឲ្យមានអ្នកទទួលការខុសត្រូវលើខ្លួនពេញទី ។

ម្យ៉ាងទៀត បើមានមនុស្សច្រើនមែន តែមិនប្រសប់ចាត់ចែងការ



www.elibraryofcambodia.org

នោះ សុខចិត្តបើមានមនុស្សតិចក៏តិចចុះ ប៉ុន្តែឲ្យបានការគឺ : ធ្វើការដែលគេប្រគល់ឲ្យដាច់មុខនោះដោយហ្មត់ចត់ដោយមានឆន្ទៈល្អ ដោយមានសតិសម្បជញ្ញៈ ដើម្បីសម្រេចការកុំឲ្យ "ខ្លោច" ឬ "ឆៅ" ។

## ២៩-ឈើពុកកុំអង្គុយលើ

# ទំនងតែង

## សេចក្ដីផ្ដើម

កុំថាឡើយជនដែលឆោតល្ងង់មិនដឹងអ្វី សម្បីតែជនខ្លះដែលមានចំណេះដឹងល្មមនិងឈ្វេងយល់ការអាក្រក់ល្អហើយ ក៏គង់មានភាន់ភាំងគំនិតភ្លាត់ស្លុះស្លុងក្នុងរណ្ដៅគ្រោះម្ដងៗដែរ ដូច្នេះហើយបានជាបុរាណបណ្ឌិតគិតបារម្ភពេកណាស់ក្រែងជនទាំងឡាយនេះ ចេះតែវង្វេងស្មារតីទៅលោយឡំនឹងរឿងរ៉ាវ ដែលអាចបណ្ដាលឲ្យមានភ័យន្តរាយដល់ខ្លួនបាន លោកក៏ទូន្មានជាបទបញ្ញាមួយ ឲ្យជនគ្រប់ឋានៈចាំឲ្យស្ទាត់ថា "ឈើពុកកុំអង្គុយលើ" ។

***<u>អត្ថាន័យរបស់ភាសិត</u>*** :

កាលបើគេអង្គុយលើឈើពុក ឈើនេះនឹងបាក់នាំឲ្យធ្លាក់មក ជាហេតុនាំឲ្យឈឺខ្លួន ឬបណ្ដាលឲ្យមានគ្រោះថ្នាក់ផ្សេងៗដល់ខ្លួនផង ។

***<u>អត្ថបដិរូប</u>*** : ឈើពុកនេះលោកចង់ប្រៀបធៀបទៅនឹងហេតុការណ៍ណាដ៏លាមកដែលមិនស្អាត ឬកន្លែងណាដែលអាចបង្កើតរឿងហេតុគ្រោះថ្នាក់ផ្សេងៗ បើជនណាមួយទៅលោយឡំនឹងការណ៍នោះ ឬ



www.elibraryofcambodia.org

ក៏ទៅតាំងនៅកន្លែងមិនស្អាតដូចខាងលើនេះ រមែងមានការសៅហ្មង ឬវិនាសអន្តរាយជិតដល់ខ្លួនជាមិនខាន វិស័យដូចជាអង្គុយលើឈើពុក វាតែងនឹងបាក់ធ្លាក់ដូច្នេះឯង ។

_ឧទាហរណ៍_ : យើងដឹងច្បាស់ថា រាជការកំពុងតែរកស៊ើបអង្កេតយកការណ៍នឹងភស្តុតាងឲ្យបានជាក់ច្បាស់ពីជនម្នាក់នៅក្នុងភូមិដែលមានគេលួចប្តឹងថា ជាជនធ្លាប់លួចប្លន់គេជាញឹកញាប់ ។ ដើម្បីជៀសវាងកុំឲ្យមានការសៅហ្មងជិតដល់ខ្លួនបាននោះ យើងមិនត្រូវទៅមកឡើងចុះផ្ទះជន ដែលគេសង្ស័យនោះឡើយ ។ ដែលធ្វើយ៉ាងដូច្នេះ គឺមកពីចង់ជៀសវាងឲ្យផុតពីគ្រោះថ្នាក់ដល់ខ្លួនឯង ។

**សេចក្តីបញ្ចប់**

ខំធ្វើខ្លួនឲ្យចាកផុតនៅកងទុក្ខ ដោយត្រងត្រាប់ស្តាប់ឱវាទទាំងឡាយ នេះហើយដែលបុព្វាចារ្យរបស់យើងចង់ទូន្មាន ។

**៣០-ទូកនៅកំពង់នៅ**

## ទំនងតែង

**សេចក្តីផ្តើម**

វិសោតបុប្ផានានា ទោះបីមានរសគន្ធាឈ្ងុយឈ្ងប់យ៉ាងណា កាលបើរុះរោយជ្រុះស្រទាប់ហើយ នោះគន្ធពិដោរក៏រលាយសូន្យបាត់ក្នុងពេលនោះដែរ ។ ចំណែកឯបុគ្គលប្រព្រឹត្តល្អវិញ តែងមានកិត្តិយសព្ទក្រអូបសាយសព្វគ្រប់ទិសទីអស់ពេលដ៏យូរមិនងាយនឹងសាបសូន្យទៅ



www.elibraryofcambodia.org

វិញបានឡើយ ដូច្នេះហើយបានជាបុព្វាចារ្យរបស់យើងទូន្មានជាបទបញ្ហាមួយថា "ទូកទៅកំពង់នៅ"

*ន័យរបស់ភាសិត*

**កាលបើរូបនៅបាត់ ពោលគឺ :**

ក- ចាកចេញទៅឆ្ងាយលែងតាំងនៅក្នុងកន្លែងណាមួយ

ខ- ឬក៏រូបរលត់ផុតអាយុសង្ខារទៅ

នោះតោងតែឲ្យកេរ្តិ៍ឈ្មោះ ល្អគង់នៅកុំឲ្យបាត់ វិស័យដូចទៅតែទូក ក៏ប៉ុន្តែកំពង់នៅដែលជាទីចំណតនៃទូក ឋិតនៅដដែលក្នុងពេលដ៏យូរអង្វែង ។

ដូច្នេះកាលបើទៅតាំងនៅទីណា ស្រុកណាតោងរក្សាកេរ្តិ៍ឈ្មោះល្អ ដែលហៅថារក្សាកេរ្តិ៍ឈ្មោះល្អនេះគឺ :

ក- ខំប្រព្រឹត្តជាមនុស្សមានអភិគុណសម្បត្តិ ពោលគឺជាមនុស្សសុចរិត មានចិត្តភក្តី មានមនសិការ: (គឺយកចិត្តទុកដាក់ក្នុងកិច្ចការរបស់ខ្លួន) ។ល ។

ខ- ខំបំពេញកិច្ចណាមួយ ទុកជាថ្វីដៃដំណែលដែលជាសាធារណៈប្រយោជន៍ ដូចចំណាយប្រាក់សង់សាលារៀន មន្ទីរពេទ្យ ឬស្ម័គ្រចិត្តប្តូរជីវិតបូជាជាតិក្នុងចំបាំងជាដើម ។

គ- ខំរកទ្រព្យសម្បត្តិទុកជាកេរ្តិ៍មត៌កឲ្យកូនចៅតរៀងទៅ ។

**សេចក្តីបញ្ចប់**

សុភាសិតនេះមានអត្ថប្រសើរណាស់ គប្បីជនានុជនត្រងត្រាប់ស្តាប់



www.elibraryofcambodia.org

ឲ្យយល់ ព្រោះជាថ្នាំលើកទឹកចិត្តឲ្យផ្លាស់គំនិតគិតខំប្រព្រឹត្តតែសេចក្ដីល្អ ដើម្បីធ្វើកិត្តិនាមឲ្យប្រសើររុងរឿងស្ថិតស្ថេរថាវរៈ ។

## ៣១-កុំយកមេឃទ្រាប់អង្គុយ

យើងដឹងហើយថាមេឃនៅខ្ពស់រកទីបំផុតគ្មាន ។ កាលបើគេថាអ្នកណាមួយយកមេឃទ្រាប់អង្គុយហើយ គឺអ្នកនោះឯងវាយឫកលើកកំពស់ហួសប្រមាណ ដោយបញ្ចេញសំដី អាការកិរិយាមិនសមរម្យតាមភាពតាមឋានៈរបស់ខ្លួន ពោលគឺលើកខ្លួនឲ្យបានខ្ពស់នៅពីលើមេឃទៅទៀត ហើយយកមេឃទ្រាប់អង្គុយផង ។

ជនណាដែលយកមេឃទ្រាប់អង្គុយនេះ ទោះបីមានភោគសម្បត្តិមានបណ្ដាស័ក្តិ មានចំណេះវិជ្ជាយ៉ាងណាក៏ត្រូវគេស្អប់ជាដរាប ។

" កុំដើយហួស កុំឱនហួស " ត្រូវនិយាយស្ដីនិងធ្វើឫកពាឲ្យល្មមសមរម្យតាមឋានៈរបស់ខ្លួន នេះហើយដែលព្រឹទ្ធាចារ្យចង់ទូន្មាន ។

## ៣២-ចង់ពិសាឱ្យរកអន្លក់ ចង់ស្រណុកឱ្យនឿយពីក្មេង

*__វគ្គទី១__* : " ចង់ពិសា " គឺចង់ឆ្ងាញ់ ។ បើចង់ឆ្ងាញ់បាយ គេត្រូវខំប្រឹងប្រែងស្វះស្វែងដើររកបេះអន្លក់ ព្រោះអន្លកនេះជាគ្រឿងផ្សំឲ្យម្ហូបឆ្ងាញ់ ម្យ៉ាងទៀត កាលបើគេបែកញើសអស់កម្លាំងជាមុនក្នុងការរកអន្លក់ហើយ ក្រោយពីនេះគេនឹងឆ្ងាញ់បាយជាមិនខាន គឺឆ្ងាញ់បាយដែលខំរកបានខ្លួនឯងផង ឆ្ងាញ់ដោយការនឿយហត់អស់កម្លាំងជាមុនផង ។



www.elibraryofcambodia.org

*វគ្គទី១២* : "សេចក្តីក្នុងវគ្គទីពីរសំរាប់ស្រាយបញ្ហាក្នុងវគ្គទីមួយ ។ បើចង់ស្រណុកក្រោយត្រូវឲ្យនឿយជាមុន គឺកាលបើគេខំធ្វើការនឿយហត់ពីក្មេង គេនឹងមានទ្រព្យសម្បត្តិច្រើនដែលជាគ្រឿងធ្វើឲ្យស្រណុកចិត្តស្រណុកកាយក្នុងពេលក្រោយ វិស័យដូចការដែលខំរកអន្លក់ឲ្យបានមកជាមុន រួចគេក៏ឆ្ងាញ់បាយតាមក្រោយដែរ ។

ចំណែកវិជ្ជាដែលខំស្វះស្វែងយ៉ាងនឿយហត់ពីក្មេង នេះហើយជា "អន្លក់" យ៉ាងឆ្ងាញ់ ដែលរកបានខ្លួនឯងហើយដែលធ្វើឲ្យអនាគតរុងរឿងនឹងឲ្យជីវភាពសប្បាយទៅថ្ងៃក្រោយ ។

ទ្រព្យសម្បត្តិដែលខំរកបានយ៉ាងនឿយហត់ក្នុងមជ្ឈិមវ័យនេះ ជាគ្រឿងធ្វើឲ្យបច្ឆិមវ័យ បានស្រណុកសុខសម្រាន្តរៀងរាបតទៅ ។

## ៣៣- ឃ្លោកលិច អំបែងអណ្តែត

*អត្ថន័យរបស់ភាសិត* :

តាមធម្មតាផ្លែឃ្លោកអណ្តែត ចំណែកអំបែងតែងតែលិចទៅបាតស្ទឹង ។ ផ្លែឃ្លោកមានសាច់ពេញ ចំណែកអំបែងវិញប្រហោងក្នុង ហើយធ្លុះធ្លាយប្រេះឆាច្រើនអន្លើ ។

*អត្ថបដិរូបរបស់ភាសិត* :

ឯផ្លែឃ្លោកមានសាច់នេះ សំដៅអ្នកមានទ្រព្យ ឬមានបណ្តាសក្តិធំៗ ចំណែកអំបែងគឺពួកអ្នកមានឋានៈថយថោក ។ តាមធម្មតាអ្នកមានភោគសម្បត្តិ ឬអ្នកមានយសសក្តិតែងអណ្តែត គឺមានមុខមាត់ខ្ពង់ខ្ពស់ធំដុំ



www.elibraryofcambodia.org

ចំណែកអ្នកក្រអ្នកតូចទាបវិញ ក៏លិចបាត់គឺគ្មានមុខមាត់អ្វីនឹងគេទេ ។

*ខ្លឹមសាររបស់ភាសិត* ៖ ភាសិតនេះពោលថា "ឃ្លោកលិច" ចំណែក អំបែងអណ្តែត"វិញ ព្រោះឋានៈរបស់មនុស្សឬរបស់រដ្ឋនីមួយៗ តែង ភាន់ប្រែមិនទៀងទាត់ជាដរាបទេ ដូចយ៉ាងអ្នកមានធ្លាក់ជាក្រ អ្នកខ្សត់ ឡើងជាមានដោយហេតុផ្សេងៗជាបច្ច័យ ។ មានប្រទេសខ្លះដែលធ្លាប់ តែ "អណ្តែត" រុងរឿងមកយូរហើយ ក៏ស្រាប់តែធ្លាក់អាប់មុខទៅជា ប្រទេសមួយយ៉ាងខ្សោយអន់ថយទៅជាអាណានិគមរបស់គេក៏សឹងមាន ផ្ទុយពីនេះទៅវិញ ប្រទេសខ្លះដែល "លិច" កប់បាត់ស្ទើររលត់ឈ្មោះ ដោយការជិះជាន់នៃប្រទេសដទៃ នោះថ្ងៃណាមួយស្រាប់តែផុស "អណ្តែត" ឡើង ដូចយើងធ្លាប់បានឃើញស្រាប់មកហើយដែរ ។ មាន អ្នកខ្លះជាចៅហ្វាយនាយគេ តែត្រឡប់ទៅជាធ្លាក់ក្រដោយវាសនា របស់ខ្លួន ចំណែកឯបាវព្រាវខ្លះពីដើមជាអ្នកបំរើគេ ស្រាប់តែរួចជាអ្នក ជា ហើយបើខំរកស៊ីព្រមទាំងភ័ព្វវាសនាល្អមកផ្សំផង ឬក៏ដោយ សេចក្តីជ្រោមជ្រែងនៃអ្នកដទៃនោះក៏ "អណ្តែត" ឡើងទៅជាអ្នកមាន ទ្រព្យសម្បត្តិវិញ ។

## ៣៤-សាច់មិនបានស៊ី យកឆ្អឹងព្យួរក

## សេចក្តីផ្តើម

ភាសិត "សាច់មិនបានស៊ីយកឆ្អឹងព្យួរក" នេះជាប់ជាកំណាប់រឿង ដោយមានគេបានសង្កេតឃើញថា មានមនុស្សខ្លះតែងទទួលនូវទុក្ខ



www.elibraryofcambodia.org

ទោស ព្រោះតែយកខ្លួនទៅធានាអះអាងរ៉ាប់រងក្នុងហេតុការណ៍ដែលបណ្ដាលឡើងរវាងអ្នកដទៃ ។

*<u>ន័យរបស់ភាសិត</u>* : "សាច់មិនបានស៊ីយកឆ្អឹងព្យួរក" គឺគ្មានបានផលប្រយោជន៍អ្វីសោះ ត្រឡប់ជាទទួលទុក្ខទោសមកដល់ខ្លួនវិញ ។

ក- ពាក្យនេះសំរាប់ស្ដីបន្ទោសជនណា ដែលនិយាយមិនគិតមុខគិតក្រោយពីរឿងអ្វីមួយដែលអ្នកដទៃខំលាក់ទុកបំបិទ មិនឲ្យលេចឮទៅណា (រឿងមិនគប្បីដែលប្រឌិតកើតឡើងក្នុងគ្រួសារណាមួយជាដើម) ។ ឯការដែលនិយាយពីគេនេះ ធ្វើឲ្យគេខូចការ ឬកើតសេចក្ដីអៀនខ្មាសជាហេតុឲ្យគេខឹង ឬជេរប្រទេចផ្ដាសា ពោលគឺជនអ្នកនិយាយពីគេនេះមិនបាន "សាច់ស៊ី" សោះ ចំណេញតែគេស្អប់ គេជេរនឹងទទួលទុក្ខទោសផ្សេងៗ ។

ខ-ម្យ៉ាងទៀត ពាក្យនេះគេតែងឮពោលឡើងនៅពេលដែលនរណាមួយបានជួយដោះទុក្ខអ្នកដទៃ ដោយប្រាថ្នាឲ្យគេបានសុខសាន្តក៏ប៉ុន្តែដល់សម្រេចសម្រួចទៅ អំពើដែលធ្វើនេះ វាហុចឯផលអាក្រក់មកឲ្យវិញគឺទទួលនូវទុក្ខទោសផ្សេងៗ ។

*<u>ឧទាហរណ៍</u>* : ១- ម៉ុកនិងម៉ៅ កំពុងវាយតប់គ្នា ។ ម៉ែនជាអ្នកជិតខាងឃើញដូច្នេះ ក៏ស្ទុះទៅជួយឃាត់ឃាំងរាំងរាកុំឲ្យវាយតប់គ្នាតទៅទៀត ។ កាលដែលម៉ែនកំពុងទាញម៉ុកចេញឆ្ងាយនោះ ម៉ៅឆ្លៀតឱកាសដាល់ម៉ុកពីរបីដៃឡើងបែកមុខ ។ ម៉ុកនឹកខឹងក៏ជេរស្ដីបន្ទោសម៉ែនយ៉ាងច្រើន ព្រោះយល់ថាដោយសារតែម៉ែនចាប់ទាញចេញ ទើបម៉ៅដាល់



www.elibraryofcambodia.org

ត្រូវម៉ែន គ្មានបានផលអ្វីសោះ ចំណេញតែគេជេរនិងបានមុំកជាសត្រូវវិញ ហើយក៏ពោលរអ៊ូថា "សាច់មិនបានស៊ីយកឆ្អឹងព្យួរក" នេះឯង ។

២-ពាណិជ្ជសួនបានចូលទៅធានាដង្ហៅសុខឲ្យនៅក្រៅឃុំ ពីរឿងជាប់ចោទអ្វីមួយ ព្រោះកាលពីរបីឆ្នាំមុននោះ សួននិងសុខ ធ្លាប់រកស៊ីជាមួយគ្នា ហើយសង្កេតឃើញថា សុខជាមនុស្សត្រឹមត្រូវដែរ ។ កាលបើចេញពីបន្ទប់ឃុំហើយ ដង្ហៅសុខនឹកខ្មាសគេ ហើយខ្លាចគេដាក់គុកផងក៏ភៀសខ្លួនចូលព្រៃបាត់ទៅ ។ ពាណិជ្ជសួនអ្នកធានាក៏ទទួលទោសជួសសុខបង់ប្រាក់កាសអស់រាប់ម៉ឺន ហើយត្រូវប្រពន្ធបន្ទោសថា "នេះហើយសាច់មិនបានស៊ីយកឆ្អឹងព្យួរក" ។

ក្នុងឧទាហរណ៍ខាងលើទាំងពីរអ្នកដែលជួយគេនេះ គ្មានប្រាថ្នាអ្វីក្រៅពីចង់ឲ្យគេបានសុខនោះទេ តែការដែលប្រាថ្នានោះថានឹងបានលទ្ធផលល្អ វាត្រឡប់ទៅជាហុចទុក្ខទោសនោះមកឲ្យវិញ ។ ដូច្នេះយើងនឹងបន្ទោសថាអ្នកដែលជួយដោះទុក្ខគេនោះមិនបានគិតពិចារណាទុកជាមុន ក៏មិនបានព្រោះជួនកាលគិតណាស់ដែរតែភ្លាត់ផ្សៀត ។

ម្យ៉ាងទៀត បើមនុស្សទាំងអស់គ្នាចេះតែជៀសវាងខ្លាច "យកឆ្អឹងព្យួរក" ហើយនោះពាក្យដែលទូន្មានថា "ត្រូវជួយគ្នាទៅវិញទៅមក" នេះ នឹងអស់តម្លៃហើយ ។

កាលបើនរណាមួយបានយកខ្លួនទៅប្តូរដោយស្មោះ ដើម្បីជាប្រយោជន៍ដល់គេ ហើយដល់ទីបំផុត វាត្រឡប់ជាមានទុក្ខទោសវិញ



www.elibraryofcambodia.org

នោះ គប្បីសន្មតក្នុងចិត្តថា អាត្មាអញត្រូវតែទទួលទុក្ខទោសដោយញញឹមចុះ ព្រោះបើមិនបានជួយគេក្នុងគ្រានោះ ក៏មិនស្រឡះចិត្តប៉ុន្មានដែរ ។

## សេចក្ដីបញ្ចប់

តែតាមធម្មតា ភាសិតនេះជាឱសថមួយសំរាប់ដាស់តឿនជនានុជនឲ្យប្រុងប្រយ័ត្នជាដរាបក្នុងការយកខ្លួនទៅលាយឡំនឹងរឿងរ៉ាវអ្នកដទៃ និងប្រយ័ត្នកុំឲ្យនិយាយឥតពិចារណាពីការទាំងឡាយណាដែលជាការរបស់អ្នកដទៃ ព្រោះជាដរាបក្នុងការយកខ្លួនទៅលាយឡំនឹងរឿងរ៉ាវអ្នកដទៃនិងប្រយ័ត្នកុំឲ្យនិយាយឥតពិចារណាពីការទាំងឡាយដែលជាការរបស់អ្នកដទៃ ព្រោះមានច្រើនណាស់មកហើយ ជនដែលមិនបាន "សាច់ស៊ី" ទៅបានឯ "ឆ្អឹងមកព្យួរក" វិញ ។

## ៣៥-ពួផ្គរកុំអាលចាក់ទឹកចោល

## សេចក្ដីផ្ដើម

"ឮផ្គរកុំអាលចាក់ទឹកចោល" នេះជាសុភាសិតមួយ គួរចារឹកទុកក្នុងសន្ដានចិត្តកុំបីបង់ ព្រោះជាឱវាទមួយដ៏ប្រសើរ សម្រាប់ទូន្មានប្រជានិករទូទៅក្នុងលោកឲ្យធ្វើដំណើរទៅមុខបានស្រួល មិនប៉ះទង្គិចពានពារទៅលើវិនាសអន្តរាយផ្សេងៗ មានការខាតបង់ទ្រព្យធនធាននិងបណ្ដាស័ក្ដិជាដើម ។

*__អត្ថាធិប្បាយរបស់ភាសិត__* :



www.elibraryofcambodia.org

កាលបើឮផ្គរលាន់ឡើងហើយ ព្រមទាំងមានមេឃខ្មៅមីរផង អ្នកស្រុកខ្លះតែងលាងពាងចាក់ទឹកចាស់ចោលអស់ ដើម្បីនឹងត្រងយកទឹកភ្លៀងថ្មីដែលសង្ឃឹមថានឹងធ្លាក់មកជាមិនខាន ។ ដោយអ្វីទាំងឡាយក្នុងធម្មជាតិមិនទៀងទាត់ គឺតែងតែប្រែប្រួលជាលំដាប់នោះ ជួនកាលផ្គរក៏ឲ្យដំណឹងខុស គឺត្រឡប់ជាគ្មានភ្លៀងធ្លាក់ទៅវិញ ធ្វើឲ្យអ្នកស្រុកដែលចាក់ទឹកចោលអស់ទៅហើយនោះ ខាតទាំងទឹកចាស់ ខាតទាំងកម្លាំងកាយដោយពិបាកទៅរែកជាថ្មីទៀត រួចក៏តាំងម្នោម្នីញស្ដាយក្រោយដោយពុំបានពិចារណាគិតទុកជាមុនថា "ផ្គរមិនមែនជាសញ្ញាថា មុខជានឹងភ្លៀងជរាបនោះទេ" ។

លោកចង់ប្រដៅថា : បើគ្រាន់តែឮសូរផ្គរមិនទាន់ធ្លាក់ភ្លៀងទេនោះកុំអាលចាក់ទឹកចោល ត្រូវរង់ចាំដល់ឃើញភ្លៀងធ្លាក់មកប្រាកដសិន សឹមលាងពាងត្រងយកទឹកថ្មីដែលឃើញច្បាស់ថាធ្លាក់ប្រាកដមែន ។

<u>*អត្ថាធិប្បាយរបស់ភាសិត*</u> : "ផ្គរ" នេះគឺជាដំណឹងល្អអ្វីមួយដែលគ្រាន់តែឮពីនាយអាយ ពីគ្រប់ទិសតំបន់ តែមិនទាន់ជាក់ថានឹងហុចផលឲ្យប្រាកដឬយ៉ាងណា វិស័យដូចឮសូរផ្គរគ្រប់ទិសទី តែមិនដឹងជាមានភ្លៀងឬក៏គ្មាន ។

"កុំអាលចាក់ទឹកចោល" គឺកាលបើបានឮដំណឹងល្អនេះហើយ កុំអាលបោះបង់ការដែលយើងធ្លាប់បំពេញជាប្រក្រតីទៅហើយនោះភ្លាមបើទុកជាការសព្វថ្ងៃនេះហុចផលស្ដួចស្ដើងយ៉ាងណាក៏ដោយ កុំអាល



www.elibraryofcambodia.org

ទុកចិត្តដំណឹងថ្មីភ្លាមនោះ ព្រោះជួនកាលជាដំណឹងខុស មិនមែនជាដំណឹងប្រាកដល្អ ដូចយើងសង្ឃឹមថានឹងធ្លាក់មកហើយ ត្រឡប់ជាគ្មានទៅវិញក៏មាន ។

តែបើយើងមិនគិតពិចារណាឲ្យជ្រៅជ្រះនោះទេ ហើយលះបង់ចោលលាភចាស់ដោយប្រាថ្នានឹងទទួលយកលាភថ្មីនោះ លោតែបែរទៅជាគ្មានវិញ យើងមុខជានឹងខាតទាំងលាភចាស់ ហើយអង្គុយស្ដាយក្រោយ ដូចអ្នកស្រុកស្ដាយទឹកចាស់ដែលចាក់ចោលទៅដីដែរ ។

*ឧទាហរណ៍* : នាយសឿនជាអ្នកបំរើលោកសួនដោយបានប្រាក់ខែ ៨០០រ ក្នុងមួយខែ ។ លុះកន្លងមកពីរឆ្នាំ អ្នកបំរើនេះឮសួរថាលោកសៅជាអ្នកមានចិត្តសប្បុរស ហ៊ានជួលឈ្នួលក្នុងមួយខែ ១៥០០រ ។ ដំណឹងនេះធ្វើឲ្យនាយសឿនតប់ប្រមល់ ចង់ឈប់បំរើលោកសួន ដើម្បីរកនាយចៅហ្វាយថ្មី ម្ល៉ោះហើយក៏តាំងតែរាយមាយលែងយកចិត្តទុកដាក់ បំពេញកិច្ចការរបស់ខ្លួនរហូតទាល់តែសុំលាលោកសួនឈប់ធ្វើការ ។ កាលបើបានចាកចេញពីផ្ទះលោកសួនហើយ នាយសឿនទៅសុំលោកសៅធ្វើការ តែមិនបានសំរេចដូចបំណងដោយលោកសៅទើបនឹងជួលឈ្នួលម្នាក់រួចមកហើយ ។ នាយសឿនត្រូវខកគំនិតដោយវិលទៅរកលោកសួនៗ ក៏លែងទទួល បែរទៅរកលោកសៅៗ ក៏លែងត្រូវការថែមឈ្នួលថ្មីទៀត ។

## សេចក្ដីបញ្ចប់

ក្នុងការសព្វសារពើ ត្រូវតែពិចារណាជាមុនឲ្យបានយល់ច្បាស់



www.elibraryofcambodia.org

សិន ។ ពាក្យចាស់លោកថា "ត្រូវគិតមុននឹងគូរ" កាលបើបានឮដំណឹងអ្វីមួយដែលធ្វើឲ្យយើងរីកចិត្តដោយយើងសង្ឃឹមថា នឹងហុចផលដល់យើងនោះកុំអាលជឿដំណឹងនេះភ្លាម ត្រូវឆ្លើះឆ្លៀលរកស៊ើបសួរឲ្យជាក់លាក់ ។ ត្រូវគិតគូរឲ្យកើតការសិន សឹមឈានជើងដើរពីកន្លែងចាស់ ។ កាលបើឃើញថា ការថ្មីបានធ្លាក់មកនៅក្នុងកណ្ដាប់ដៃហើយនោះ សឹមលះបង់ការចាស់ជាក្រោយ វិស័យកាលបើមានភ្លៀងធ្លាក់មកហើយ សឹមចាក់ទឹកចាស់ចោល រួចត្រងយកទឹកថ្លាដែរ ។

## ៣៦-ងើយស្កក ឱនដាក់គ្រាប់

## សេចក្ដីផ្ដើម

អាកប្បកិរិយានៃមនុស្សក្នុងសង្គមមានលំនាំប្លែកៗគ្នា ជាហេតុញុាំងបណ្ឌិតនានាឲ្យត្រិះរិះចងជាសុភាសិតោវាទយ៉ាងច្រើន ដើម្បីបើកផ្លូវលោកឲ្យមានដំណើរស្រួល តាមលំអាន ទៅកាន់សេចក្ដីសុខ សេចក្ដីចំរើនដូចយ៉ាងពាក្យថា "ងើយស្កក ឱនដាក់គ្រាប់" ជាដើម ។

<u>*អត្ថាធិប្បាយរបស់ភាសិត*</u> : កាលដល់រដូវស្រូវទុំ ដើមស្រូវណានៅតែ "ងើយ" គឺនៅត្រង់ទៅលើច្បាស់ជាផ្លែវា "ស្កក" ហើយ គឺគ្មានគ្រាប់នឹងគេទេពោលគឺគ្មានបានផលអ្វីសោះ ។

កាលបើដើមស្រូវ "ឱន" គឺទោរទន់ទៅដោយទម្ងន់ផ្លែនោះច្បាស់ជា "ដាក់គ្រាប់" គឺមានគ្រាប់ពេញលេញ ពោលគឺបានផលយ៉ាងសំខាន់ ។

<u>*អត្ថបដិរូបរបស់ភាសិត*</u>: ជនណាដែលវាយឫកលើកកំពស់ ធ្វើឫកពា



www.elibraryofcambodia.org

ក្រអើតក្រអោងឬឆ្មើយៗតែងតែមានសេចក្ដីហ្មងផ្គង ធ្វើឲ្យតែគេទ្រាន់ស្អប់ខ្ពើម ជាហេតុនាំឲ្យខាតផលប្រយោជន៍ផ្សេងៗ មិនខុសគ្នាពីដើមស្រូវដែល" ងើយ" ហើយតែងតែ"ស្កក" នោះឡើយ ។

ផ្ទុយពីនេះ ជនណាដែលចេះឱនលំទោន គឺចេះដាក់ខ្លួនមិនប្រកាន់ខ្លួន មិនធ្វើឬកក្រអើតក្រទាំ រមែងតែងបានសេចក្ដីគាប់ប្រសើរ ព្រោះគេចូលចិត្តអាណិតមេត្តា ម្ល៉ោះហើយប្រាថ្នាការអ្វីតែងតែបានផលប្រយោជន៍ផ្សេងៗដូចគ្នានឹងដើមស្រូវដែល"ឱន" វាតែងតែ"ដាក់គ្រាប់ "នោះដែរ ។

__*ឧទាហរណ៍*__ : ១- សិស្សនៅវិទ្យាល័យណាដែលអាងតែខ្លួនរៀនចេះដឹងគ្រាន់បើ ហើយតាំងតែវាយឬកលើកកំពស់ឲ្យឃើញធ្លោជានិច្ចថាឯងគ្រាន់បើ មិនមានញញើតកោតក្រែងគ្រូ ឬអនុរក្សសិស្សនោះឯងគេតែងស្អប់ ។ កាលបើគេស្អប់ហើយ តែងទទួលនូវផលអាក្រក់ផ្សេងៗជាមិនខាន ។

២- ក្នុងរឿង"បង្កួយនិងសេចក្ដីវិទេហរាស្ត្រ" យើងក៏ដឹងហើយថាក្នុងពេលបង្កួយមានអាការកិរិយាឱនលំទោន គំនាប់គោរពព្រះបរមរាជានោះ ក៏ត្រូវបានសាច់ពីនាយពិសេសទិញឲ្យអាស្រ័យរាល់ថ្ងៃ ប៉ុន្តែក្នុងពេលក្រោយមក ដែលបង្កួយនេះប្រែកិរិយាមារយាទធ្វើឬកក្រអឺតក្រអោងនោះ ក៏ត្រូវទទួលនូវទណ្ឌកម្មដល់សេចក្ដីស្លាប់ទៅ ។

__*ខ្លឹមសាររបស់ភាសិត*__ : ភាសិតនេះញ៉ាំងជនទាំងឡាយឲ្យចេះឱនលំទោន ឲ្យមានឬកពាសុភាពរាបសាឲ្យចេះគួរសមគោរពប្រណិបតន៍



www.elibraryofcambodia.org

ព្រោះកិរិយាទាំងនេះ ជាផ្នាក់ទាក់ចិត្តអ្នកដទៃឲ្យស្រឡាញ់រាប់អាន ហើយហុចផលប្រយោជន៍ម្យ៉ាងៗ ឲ្យមកវិញជាមិនខាន ប៉ុន្តែការដែលឱននេះក៏ត្រូវឱនទៅតាមកាលៈទេសៈដែរ មិនចេះតែឱនដរាបទេ ព្រោះមានជំពូកជនជាតិខ្លះ កាលបើឃើញយើងឱនហួស នោះវាតែងប្រមាថមើលងាយហើយជាន់ពន្លិចថែមទៀត ។

**សេចក្តីបញ្ចប់**

ដូច្នេះយើងត្រូវការចេះប្រើអាកប្បកិរិយាឲ្យល្មមឲ្យសមរម្យតាមវេលា គឺពេលណាដែលត្រូវ " ងើយ " នោះយើងត្រូវងើយម្តងៗដែរ ពេលណាដែលត្រូវឱនយើងក៏ត្រូវឱនដែរ ដើម្បីជាប្រយោជន៍ដល់យើងដរាបទៅ ។ តែទោះបីយ៉ាងណាយើងកុំភ្លេចឲ្យសោះ ឱវាទរបស់ព្រះបាទ្បាត់ឧត្តមលិខិត សុង-ស៊ីវ ដែលបានបោះពុម្ពផ្សាយក្នុងសៀវភៅ "សុភាសិតសង្ក្រោះ" ថា : "កុំចង់ខ្ពស់ស្មើមេឃ កុំឱនពេកអាប់រាសី ទោះដើរនិយាយស្តីលៃឲ្យល្មមតែគួរសម" ។



www.elibraryofcambodia.org

## គតិលោក

**៣៧**-ក្នុងរឿងល្បើក "**រឿងកូនចៀម និងឆ្កែព្រៃ**" ដែលឧកញ៉ា សុត្តន្តប្រីជាឥន្ទ បានរៀបរៀងចុះក្នុងគតិលោកភាគទី២ តើមានខ្លឹមសារយ៉ាងណាខ្លះ ក្នុងការប្រៀបធៀបមកឥរិយាបថនៃមនុស្សក្នុងសង្គម?

## សេចក្ដីអធិប្បាយ

ក្នុងបណ្ដារឿងល្បើក ដែលបណ្ឌិតនានាបានលើកទុកមក ដើម្បីបំផុសនូវកំហុសនៃពួកពាល នោះយើងពិនិត្យឃើញថា "រឿងកូនចៀម និងឆ្កែព្រៃ" មានខ្លឹមសារយ៉ាងសំខាន់ដែលគួរឲ្យយកមកពណ៌នាឲ្យបានជ្រៅជ្រះទៀត ។

កូនចៀមជាសត្វស្លូតត្រង់ ហើយឆ្លាតវាងវៃមានបញ្ញាដ៏មុតថ្លាអាចដោះស្រាយពាក្យគ្រាមបង្កាច់របស់ឆ្កែព្រៃបាន ប៉ុន្តែដោយហេតុដែលកូនចៀមតូចទន់ខ្សោយជាង នោះចចកពាលកំណាចដោយអាងមាឌធំជាង ក៏ប្រហារកូនចៀមជាចំណីបានដោយងាយ ។

ឯកូនចៀម លោកប្រៀបធៀបទៅនឹងជនណាដែលទន់ខ្សោយដោយកំលាំងកាយ ព្រោះនៅ "តូច" ឯឆ្កែព្រៃលោកទុកដូចជាជនណាដែលមានកម្លាំងច្រើន ព្រោះមាឌធំជាង ។ គេតែងប្រទះឃើញសិស្សធំៗជាដើមដែលតែងតែប្រព្រឹត្តរំលោភប្រមាថសិស្សតូចៗ ដោយអាងមាឌអាងកំលាំង ។ បើទុកជាកុមារតូចៗ នេះនិយាយត្រូវយ៉ាងណាក៏ច្រើន តែសិស្សធំៗ គំហកសន្ធាប់ឲ្យបាត់មាត់ ឬក៏កំញើញដោយអាកប្ប



www.elibraryofcambodia.org

កិរិយាកោងកាចធ្វើបំពារបំពានលើកំហុសរបស់ខ្លួន បង្វិលបង្វែរឲ្យបែរជាត្រូវទៅវិញបាននោះ ។

តែបញ្ហានេះ មានន័យធំទូលាយទៅទៀត : ឯពាក្យថា "តូច" នេះ គឺសំដៅត្រង់តូចដោយសក្តិ ឬក្រខ្សត់ធនធាន គឺអ្នកមានឋានៈថយថោក ។ ឯពាក្យថា "ធំ" គឺសំដៅត្រង់ធំដោយសក្តិ ឬធំដោយមានភោគសម្បត្តិជាច្រើន គឺពួកអភិជនអ្នកមានឋានៈរុងរឿងដ៏ខ្ពង់ខ្ពស់ ។

កាលជំនាន់ដើម គេតែងប្រទះឃើញ "អ្នកធំ" ប្រព្រឹត្តការរំលោភទៅលើ "អ្នកតូច" ហើយកាលបើអ្នកតូចកើតរឿងនឹងអ្នកធំនោះ បើទុកជាអ្នកតូចត្រូវយ៉ាងណាក៏ដោយ ក៏មិនងាយនឹងឈ្នះអ្នកធំបាន ព្រោះអ្នកធំនោះតែងយកកំលាំងសក្តិ ឬកំលាំងទ្រព្យ ទៅប្រើបំបែរប្រែក្រឡាប់ឲ្យ "ខុសផុសជាត្រូវ" បាន ពោលគឺអំណាចទ្រព្យ និងពហូសក្តិអាចប្រើរំលោភលើច្បាប់បាន ។ អ្នកតូចណាដែលហ៊ានប្រកួតយកឈ្នះចាញ់នឹងអ្នកធំ មុខជាដូចគេយក "ពងមាន់ទៅជល់នឹងថ្ម" ជាមិនខាន ។ សេចក្តីត្រង់នេះធ្វើឲ្យយើងគិតឃើញដល់ប្រសាសន៍លោករឹម-គិន ក្នុងសៀវភៅសូផាត (ជំពូក៤) ថា " មនុស្សតូចកើតទោសនឹងមនុស្សធំច្រើនតែចាញ់មនុស្សធំ" ។

តែក្នុងសម័យឥឡូវនេះ ច្បាប់ដែលមានតាំងឡើងសំរាប់រដ្ឋមានកម្លាំងណាស់ ព្រោះធ្វើឲ្យជនគ្រប់ឋានៈលែងហ៊ានប្រព្រឹត្តការរំលោភនិងប្រើអំណាចហួសហេតុ ដែលគេច្រើនប្រទះឃើញកាលជំនាន់ដើមនោះ ។



www.elibraryofcambodia.org

## សូផាត

**៣៨**-ក្នុងជំពូកទី១ និងទី២នៃរឿង"សូផាត" របស់លោករីម-គិន តើលោកស្នួនមានកិរិយាមារយាទយ៉ាងណាខ្លះ ។

## សេចក្តីអធិប្បាយ

បុគ្គលគ្រប់រូបក្នុងលោកិយ រមែងតែងមានគុណសម្បត្តិ និងគុណវិបត្តិទាំងពីរយ៉ាង ពោលគឺមនុស្សម្នាក់ៗ មានកិរិយាល្អ និងកិរិយាអាក្រក់ជាគ្រឿងសំគាល់ ។ តែកិរិយាទាំងនេះមានមិនស្មើគ្នាទេ ជនខ្លះក៏បរិបូណ៌ដោយសេចក្តីល្អ ខ្លះក៏លេចលង់ខ្លាំងទៅទៀតក្នុងគន្លងអាក្រក់ ។ ឯលោកស្នួនដែលជាតួចំណានមួយក្នុងរឿង សូផាត នោះ អ្នកនិពន្ធបណ្ឌិត រីម-គិន ក៏បានបំផុសឲ្យឃើញជាក់ស្តែងនូវគុណសម្បត្តិ និងគុណវិបត្តិទាំងពីរនេះដែរ តែក្នុងខណៈនេះ យើងសូមស្រង់មកពិនិត្យមើលតែកិរិយារបស់លោកស្នួនក្នុងជំពូកទី១ និងទី៤ តែប៉ុណ្ណោះទេ ។

-លោកស្នួនជាមនុស្សខ្វះសច្ចវាចា គឺនិយាយមិនទៀងទាត់ មិនចាំពាក្យសំដីនូវសម្បថរបស់ខ្លួន ។ មុនពេលដែលចេញចោលនាងសួយាជាគូសង្សារទៅនៅភ្នំពេញ លោកស្នួនបានសន្យានឹងនាងថា៖ "ចិត្តបងប្រាជកជាចាំនៅរូបអូន"" បងនឹងវិញថ្កានមករកប្អូនស្រីវិញ"បងនឹងលើកនាងឲ្យបានពេញមុខជាពុំខាន" ពាក្យសង្សារនេះកុំកែវគិត



www.elibraryofcambodia.org

សង្ស័យ បងស្បថឲ្យអូនបើបងដោះដៃឈប់អាល័យមិត្ត" ពាក្យដែលសន្យាទាំងប៉ុន្មាននេះ លោកសួនបានបំភ្លេចចោលទាំងអស់ ដូចមានសេចក្តីក្នុងសាច់រឿងជាភស្តុតាងថា : "តាំងតែពីគេផ្លាស់លោកសួនទៅនៅភ្នំពេញវិញ នាងសូយាមិនដែលបានទទួលសំបុត្រមួយបន្ទាត់ទាល់តែសោះ" ។

-លោកសួនក៏ដឹងដែរថា ម្តាយលោក "បានដណ្តឹងកូនគេបញ្ចាំចិត្តទុកឲ្យហើយៗបានប្តេជ្ញាថាកុំឲ្យទៅយកស្រីឯណាធ្វើជាភរិយា" ។ បណ្តាំទាំងនេះ លោកសួនបានចាំគ្មានភ្លេចទេ ប៉ុន្តែចិត្តទន់ខ្សោយរបស់លោកសួននេះ ទុកឲ្យរាគកាមតាមជិះជាន់គ្របសង្កត់ពេញកម្លាំងបាន ។ លោកដឹងជាមុនហើយថា លោកមិនបំរុងនឹងយកនាងសូយា ជាគូរព្រេងអស់មួយជីវិតទេ ដឹងជាមុនហើយថា អំពើដែលលោកបានប្រព្រឹត្តទៅនោះ នឹងកើតការសៅហ្មងទៅថ្ងៃក្រោយមិនខាន ប៉ុន្តែលោកនៅតែធ្វើបទបំពារបំពាននេះ ទៅលើសេចក្តីដែលដឹងនោះទៅទៀត ។ កិរិយានេះបានបង្ហាញថា លោកសួនជាមនុស្សទន់ខ្សោយ គ្មានចិត្តមានះឲ្យបានជ័យជំនះទៅលើអំពើអកុសលដែលបង្ហាញលទ្ធផលអាក្រក់ជាមុនហើយនោះ ។

-លោកសួនធ្វើឲ្យនាងសូយា ហែលក្នុងអន្លង់ទុក្ខដល់សេចក្តីស្លាប់កាលនៅក្រមុំ នាងសូយាមានទុក្ខព្រួយម្តង ព្រោះនាងអសោចិ៍កេរ្តិ៍ដោយស្លូងខ្លួន ធ្លាក់ក្នុងអន្ទាក់លោកសួនដែលប្រសប់ណាស់ "ខាងប្រើសំដីពីរោះឈ្ងុយឆ្ងាញ់" ឲ្យនាងជឿចិត្ត ។ វេលាមានផ្ទៃពោះហើយ



www.elibraryofcambodia.org

លោកស្ទួនក៏បោះបង់ចោលនាងទៅ ជាហេតុធ្វើឲ្យនាងពរទុក្ខជាទម្ងន់ដោយសេចក្តីក្រីក្រលំបាក ហើយដោយលោកស្ទួនមិនដែលមកចិញ្ចឹមនាងម្តងណាសោះ សូម្បីតែសំបុត្រមួយបន្ទាត់ក៏គ្មានដែរ ។ ដំណឹងពីភ្នំពេញមកថា លោកស្ទួនមានភរិយាថ្មី ធ្វើឲ្យនាងសូយាសូន្យជីវិតក្នុងសេចក្តីព្រួយនេះ ទុកឲ្យសូផាតដែលទើបនឹងកើតមកនេះ នៅកំព្រាតែក្បាលមួយក្នុងលោកនេះ ។

ប៉ុន្តែគួរឲ្យសរសើរលោកស្ទួនបន្តិចដែរ ព្រោះលោកអាចកាត់ចិត្តដកខ្លួនឲ្យផុតពីកំហុសភ្លាមៗបាន ដើម្បីទៅកាន់សេចក្តីល្អ ពោលគឺធ្វើឲ្យឪពុកម្តាយមានមុខមាត់ និងរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីឯភ្នំពេញតែទោះបីយ៉ាងណាក៏យើងមិនសមគំនិតដែរ ព្រោះលោកទៅប្រព្រឹត្តអំពើល្អ តែលោកដោយរលាស់ចោលគេឲ្យរងទុក្ខវេទនាទាល់តែស្លាប់ខ្លួន ។

ក្រៅអំពីកំហុសទាំងអម្បាលម៉ាន ដែលបានសារភាពមកហើយនេះលោកស្ទួនមានគុណសម្បត្តិមួយយ៉ាងវិសេសដែរ ដែលយើងអាចដឹងបានដោយសំដីរបស់អ្នកស្រុកថា" ស្លឹកឈើជ្រុះមិនឆ្ងាយហួសពីគល់" ពោលគឺ អ្នកស្រុកសិរីសោភ័ណចង់និយាយថា សូផាតជាកុមារឧស្សាហ៍ព្យាយាម ឆ្លៀវឆ្លាតចេះគួរសមគោរពចាស់ព្រឹទ្ធាចារ្យដូចលោកស្ទួនជាឪពុកដែរ ។

**៣៩**-ក្នុងរឿងសូផាតរបស់លោក រីម- គិន ចូរបំផុសកិរិយាមារយាទរបស់នាងសូយា និងម៉ានយ៉ាន ដោយឡែក រួចហើយ ចូរពន្យល់



www.elibraryofcambodia.org

ដោយពិស្តារ តើត្រង់កន្លែងណាដែលកិរិយាតួរឿងទាំងពីរនេះប្រហែលគ្នា ។

## ចំនងតែង

*__កិរិយាមារយាទនាងសូយា__* :

ក-កាលនៅកុមារនៅឡើយ នាងសូយាជាធីតា លុះដោយគ្មានគន្លងទូន្មានមាតាបិតា ។ ទើបអាយុបានដប់ពីរឆ្នាំនាងចេះគោរពប្រណិបតន៍បំរើម្តាយនាងដែលឈឺខ្លាំង ។

ខ-លុះអាយុបានដប់ប្រាំពីរឆ្នាំ កាមាចូលគ្របសង្កត់ធ្វើឲ្យសូយាសៅហ្មងកេរ្តិ៍ ត្រូវពាក្យដំនៀលគេដៀលគ្រប់មាត់ ព្រោះប្រព្រឹត្តកិរិយាមិនសមរម្យជាស្រីមានលក្ខណៈគឺ "លួចប្រតិព័ទ្ធដោយចិត្តនិងចិត្ត" និងលោកស្មួនមិនមានចាស់ទុំដឹងឮជាមុនផង ។ ប៉ុន្តែទោះបីសូយាប្រព្រឹត្តខុសប្រពៃណីខ្មែរយ៉ាងណាក៏យើងអាចសម្រាលកំហុសរបស់នាងបានខ្លះ ព្រោះ :

១-មកពីនាងកំព្រាតែលតោល គ្មានមាតាបិតាទូន្មានប្រៀនប្រដៅឲ្យហ្មត់ចត់ឲ្យបានជាធីតាគ្រប់លក្ខណា តាមកិរិយានៃនារីខ្មែរ ។

២-មកពីនាងគ្មាននរណាជាបង្គោលយ៉ាងមាំល្មមពឹងផ្អែកកក់ក្តៅដោយសារ ម្លោះហើយ ដោយឮសំដីលួងលោម "ពីរោះឈ្ងុយឆ្ងាញ់" របស់លោកស្មួន នាងក៏ប្តូរផ្ញើខ្លួននឹងលោកចៅហ្វាយស្រុកនេះទៅព្រោះសង្ឃឹមយ៉ាងមាំថា អនាគតរបស់នាងនឹងបានប្រសើរ ។ យើងអាច



www.elibraryofcambodia.org

និងស្មានបានថានាងសួយាច្បាស់ជាអង្វរកលោកសួន ឲ្យចូលដណ្ដឹងនាងតាមច្បាប់ដែរ ប៉ុន្តែលោកសួនមិនយល់តាម ព្រោះលោកមិនប្រាថ្នានឹងយកសួយាជាប់ ហើយក៏ប្រើល្បិចល្បាយផ្សេងៗ ដែលជានុយយ៉ាងផ្អែមបបោសអង្អែលចិត្តស្ត្រីទាល់តែនារីគំនិតខ្លីស្លាប់ចិត្តស្លុក ។ ដោយឃើញលោកសួនមានបណ្ដាសក្តិ ហើយដោយខ្លាចលោកសួនលែងត្រូវការនឹងនាងផងនោះ សួយាក៏ប្ដូរផ្ញើខ្លួនកាត់ចិត្តចោលកេរ្តិ៍ខ្មាស ទៅបំពានលើច្បាប់ប្រពៃណីខ្មែរ ។

***កិរិយាមារយាទនាងម៉ានយ៉ាន*** :

ក-ម៉ានយ៉ានជានារីចិត្តស្រាល មិនបានគិតដល់ពាក្យចាស់ពោលថា "ខឹងខុសខឹងខាត ខឹងខក" ឡើយ ។ គ្រាន់តែឃើញនាងអូរីចេញពីបន្ទប់សូផាតប៉ុណ្ណោះ ក៏ចាប់ផ្ដើមតោះតើយនឹងសូផាតភ្លាម ឥតពិចារណារកសេចក្ដីពិតឲ្យឃើញសិន ។ កំហឹងឥតរកហេតុឲ្យច្បាស់លាស់នេះ ធ្វើឲ្យសូផាត ទទួលសេចក្ដីព្រួយលំបាកជាទម្ងន់ ចំណែកខ្លួនម៉ានយ៉ានទៀតក៏ទទួលទុក្ខសោកស្ទើរនឹងក្ស័យប្រាណ ។

ខ-ម៉ានយ៉ានស្មោះត្រង់ចំពោះនាង : ដែលហៅថាស្មោះត្រង់ចំពោះខ្លួនឯងនោះគឺ បើធ្វើខុសរ៉ាប់ទទួលក្នុងចិត្តថាខុសមែនមិនគេចកែដោះស្រាយ លុបលាងកំហុសរបស់ខ្លួនឡើយ ដូចត្រង់ដែលម៉ានយ៉ានយល់ច្បាស់ថា "សូផាតលោតទឹកស្លាប់ គឺពីព្រោះនាង សូផាតប្រល័យខ្លួនបង់ ពីព្រោះក្ដីកំហុសរបស់នាងជាអ្នកបង្កើតកម្មគ្រោះ" ពោលគឺនាងរ៉ាប់រងក្នុងចិត្តថានាងប្រព្រឹត្តខុសមែន ។ ម្យ៉ាងទៀត ក្នុង



www.elibraryofcambodia.org

លោកនេះមនុស្សដែលបានប្រព្រឹត្តអំពើអ្វីមួយខុសហើយ ចេះយកកំហុសនោះមកពិចារណានឹងខឹងចិត្តនឹងការកំហុសនោះលោកចាត់ថាជាជនប្រសើរណាស់ ព្រោះមនុស្សជំពូកនេះអាចនឹងកែប្រែគំនិតមារយាទឲ្យល្អបានទៅថ្ងៃក្រោយ អាចជៀសវាងអំពើដែលធ្លាប់តែប្រព្រឹត្តខុសមកហើយនោះបាន ។ ឯនាងម៉ានយ៉ានក៏បុគ្គលមួយគួរចាត់ថាជាអ្នកចេះខឹងចិត្តនឹកស្តាយកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តខុសមកហើយដែរ គឺនឹកស្តាយដែលស្មានខុសថា សូផាតក្បត់ចិត្តនាងដោយលួចស្រឡាញ់នាងអូរី ប៉ុន្តែទោះបីយ៉ាងណា នាងម៉ានយ៉ានក៏ត្រឡប់ជាខុសធ្ងន់ទៅវិញ ព្រោះកាលបើបានយល់ច្បាស់ថា ខ្លួនខុសហើយ នាងមិនគិតកែប្រែធ្វើខ្លួន ឲ្យប្រសើរឡើងទៅជាគិតសម្លាប់ខ្លួនទៅវិញ ។

គ-ការដែលចង់សម្លាប់ខ្លួននេះ គឺមកពីសេចក្តីទុក្ខព្រួយ សោកស្តាយសូផាត ជាគូសង្សារ ។ យើងឃើញថា ម៉ានយ៉ានស្មោះត្រង់នឹងសូផាត មែនហើយ គឺនាងមិនចង់ប្រតិព័ទ្ធនឹងនរណាក្រៅពីសូផាតកំសត់ឡើយ ប៉ុន្តែបើទុកជាព្រួយយ៉ាងណាក៏ដោយ ការដែលសម្លាប់ខ្លួនជាការមិនប្រសើរឡើយ បើនិយាយតាមច្បាប់ចរិយាសាស្ត្រ មនុស្សសម្លាប់ខ្លួនទុកជាមនុស្សទន់ខ្សោយ ទុកឲ្យសេចក្តីទុក្ខសោក "ដឹកច្រមុះឲ្យស្ទុះខ្លួនធ្លាក់ក្នុងជំរៅរណ្តៅ" បាន ៖

<u>*សំគាល់*</u> ៖ យើងឃើញថានារីទាំងពីរខាងលើនេះ ជាមនុស្សទន់ខ្សោយដោយចិត្តពិតប្រាកដ ៖

- នាងសូយា ទុកឲ្យសេចក្តីសោកនិងកំហឹងចូលគ្របសង្កត់បង្កើត



www.elibraryofcambodia.org

ជាជម្ងឺ ដែលអាចផ្តាច់អាយុសង្ខារបាន ។

- នាងម៉ានយ៉ានក៏ដូចគ្នា គឺសេចក្តីអស់សង្ឃឹមនិងទុក្ខព្រួយចូលជិះជាន់ទន្រ្ទានចិត្ត នាំឲ្យនាងរត់ទៅលោតទឹកសម្លាប់ខ្លួនបាន ។

នារីទាំងពីរគំនិតខ្លីនេះ មិនគិតដល់បញ្ហាដែលថា "រស់នៅគឺប្រយុទ្ធគឺតស៊ូនឹងឧបសគ្គគ្រប់ជំពូក" ។ សរុបទៅគឺជាមនុស្សខ្វះសេចក្តីក្លាហាន ព្រោះក្នុងច្រកដែលចង្អៀត ដែលមានចំរូងបន្លាមិនគិតរកផ្លូវបំរះចេញឲ្យផុត មិនគិតខាំមាត់សង្កត់ចិត្តអត់ធន់ខំតស៊ូផ្សះ "ជម្ងឺចិត្ត" នោះ ទៅជាយល់ថាស្លាប់ទៅល្អជាងវិញ ។

**៤០**-បើគេឲ្យអ្នករើសខាងអានសៀវភៅ ឬខាងមើលរាត្រីសមោសរដែលមានរឿងដូចគ្នា តើអ្នកចូលចិត្តរើសយកខាងណាវិញ? ហេតុដូចម្តេច ?

## ចំលើយ

(រើសយកខាងអានសៀវភៅ)

### សេចក្តីផ្តើម

បើគេឲ្យខ្ញុំរើសខាងអានសៀវភៅ ឬខាងមើលរាត្រីសមោសរមានរឿងដូចគ្នា នោះខ្ញុំចូលចិត្តខាងអានសៀវភៅវិញ ។

*ហេតុដូចម្តេចបានជាខ្ញុំចូលចិត្តអានសៀវភៅ?*

ក-ព្រោះខ្ញុំមានសេរីភាពនឹងអានសៀវភៅ នៅពេលណាក៏បានតាមតែចំណង់របស់ខ្ញុំ ។



www.elibraryofcambodia.org

នៅឱកាសដែលខ្ញុំត្រូវចេញដើរលេង ខ្ញុំអាចនឹងយកសៀវភៅទៅជាប់នឹងខ្លួនបាន ហើយទៅរកកន្លែងមួយស្ងាត់ ដែលជាទីមនោរម្យគាប់ចិត្តខ្ញុំ ដើម្បីនឹងអានតែឯង ។

ជួនកាលភូមិភាគខ្លះមានទេសភាពដ៏វិចិត្រ ស៊ីគ្នានឹងទេសភាពដែលអ្នកប្រាជ្ញបានពណ៌នាយ៉ាងក្បោះក្បាយ ក្នុងសៀវភៅជាការធ្វើឲ្យនឹកភ្នកដល់រូបនិពន្ធបណ្ឌិត ដែលតាមស្មានទៅប្រហែលជាអង្គុយតែឯកឯង ហើយទស្សនាសង្កេតមើលលំអនៃធម្មជាតិដូចខ្ញុំក្នុងពេលនោះដែរ ។

ម្យ៉ាងទៀត បើខ្ញុំចេញដើរទៅណាមិនបាន ខ្ញុំអាចនឹងសន្ធឹងលើគ្រែខ្ញុំ ឬក៏ចំខែងក្នុងកៅអីយោលយោកយ៉ាងស្រួល ដើម្បីនឹងអានសៀវភៅ ។

ខ- ខ្ញុំអាចនឹងមើលទៀតជាច្រើនដងបាន នៅសេចក្តីណាដែលខ្ញុំមិនទាន់យល់ច្បាស់ ឬភាគណាជំពូកណាដែលខ្ញុំយល់ឃើញថា មានសារៈសំខាន់ជាងគេ ។ ខ្ញុំអាចនឹងមើលរឿងមួយក្នុងពេលយូរថ្ងៃបាន ។

គ- ខ្ញុំអាចនឹងមើលលើកដាក់សម្លេង ទឹង កាច ស្លូត តំអូញញ័រ... ហើយធ្វើអាកប្បកិរិយា និងកាយវិការដោយសេរីបាន មានការលើកដៃឬប្រើទឹកមុខជាដើមតំណាងតួអ្នកលេងក្នុងរឿងនោះ ព្រោះដោយការមើលសៀវភៅនេះ ខ្ញុំអាចនឹងយល់បានថាតួនីមួយៗមានមនោសញ្ចេតនា នឹងឥរិយាបថយ៉ាងណាៗបាន ។

ឃ- ការអានសៀវភៅ ធ្វើឲ្យខ្ញុំបានចម្រើនណាស់ក្នុងការរៀន



www.elibraryofcambodia.org

ភាសា គឺខ្ញុំប្រទះឃើញពាក្យដែលខ្ញុំត្រូវការស្គាល់ ខ្ញុំអាចនឹងដឹងបានថា និពន្ធបណ្ឌិតនេះសរសេរប្រយោគល្អ ហើយងាយយល់ អ្នកនិពន្ធនោះចូលចិត្តប្រើប្រយោគវែងៗ ឬប្រើពាក្យពិបាក ។ ខ្ញុំអាចនឹងស្រង់សេចក្តីណាសំខាន់ៗទុករៀនឲ្យចាំមាត់ ។

**សេចក្តីបញ្ចប់**

ការមើលសៀវភៅនេះ ឃើញថាមានសារៈសំខាន់ណាស់ដូចបានសាធកៈមកហើយ ប៉ុន្តែបើអានសៀវភៅហើយថែមទាំងបានមើលរាត្រីសមោសររឿងដូចគ្នាទៀត នោះនឹងរឹងតែយល់ច្បាស់ ហើយចាំល្អណាស់ទៅទៀត ។ ដូច្នេះដោយហេតុដែលរាត្រីសមោសរ មិនសូវមានលេងជាញឹកញាប់នោះ ខ្ញុំត្រូវឆ្លៀតឱកាសទៅមើលមិនហ៊ានខានដែរ ។

## ទំនងតែង

(ការរើសខាងមើលរាត្រីសមោសរ)

**សេចក្តីផ្តើម**

ដោយខ្ញុំជាអ្នកចូលចិត្តលាយឡំក្នុងចំណោមជនគ្រប់ឋានៈឥតរៀនខ្មាស ឥតប្រកាន់ខ្លួន ឥតធុញថប់ នោះខ្ញុំរីករាយចិត្តពេក ក្នុងការមើលរាត្រីសមោសរ ។

*<u>ហេតុដូចម្តេចបានជាខ្ញុំចូលចិត្តមើលរាត្រីសមោសរ ?</u>*

ក- គួរឲ្យសប្បាយនៅឱកាសដែលជួបជុំគូកនមិត្តភក្តិដែលមានទឹក



www.elibraryofcambodia.org

មុខស្រស់បស់មុនល្ហោនលេង ។ ការចូលចិត្តក្នុងចំណោមធំ ដ៏មានជនគ្រប់ឋានៈយ៉ាងនេះ អាចទម្លាប់ចិត្តឲ្យអស់សេចក្តីអៀនខ្មាស ហើយឲ្យស្គាល់របៀបសុជីវធម៌ក្នុងសង្គមផង ។ ជនណាដែលមិនសូវចូលចិត្តក្នុងចំណោមធំនឹងគេ ជននោះមិនសូវស្គាល់លក្ខណៈល្អ ឬអាក្រក់របស់មនុស្សទេ ។

ខ-នៅរាត្រីសមោសរអ្នកលេងអាចបញ្ចេញមនោសញ្ចេតនាឲ្យឃើញជាក់ស្តែងនឹងភ្នែកដោយការបង្ហាញនូវកាយវិការ និងអាកប្បកិរិយារបស់តួក្នុងរឿង ពោលគឺសេចក្តីទុក្ខព្រួយក៏ឃើញជាក់ស្តែងឡើងដោយទឹកភ្នែក ឬសម្លេងតំអូញនៃអ្នកលេង សេចក្តីសប្បាយក៏ឃើញជាក់ស្តែងឡើង នៅទឹកមុខញញឹមស្រស់នៃអ្នកលេង ពាក្យកំប្លែងក៏ធ្វើឲ្យអ្នកស្តាប់សើចក្អាកក្អាយបំភ្លេចអស់សេចក្តីទុក្ខព្រួយទាំងអម្បាលម៉ាន ។

ឃ-ផ្ទួនកាល អ្នកលេងមានស្លៀកពាក់តាមរបៀបដែលអ្នកស្រុកនិយមប្រើក្នុងជំនាន់ដើម ជាការធ្វើឲ្យយើងឃើញស្តែងៗ ហាក់ដូចជាយើងកើតក្នុងសម័យមុននោះដោយពិតៗ ។ ផ្ទួនកាលវាំងនន ឬវត្ថុតុបតែងឆាកដែលតំណាងវិការដ្ឋាននៃរឿង ក៏ឲ្យស្គាល់របៀបប្លែកៗ កាលជំនាន់បុរាណសម័យនោះខ្លះដែរ ។

ម្យ៉ាងទៀត សូរស័ព្ទនៃចំរៀង និងដូរ្យតន្ត្រីយ៉ាងពីរោះធ្វើឲ្យរីតតែរំភើបចិត្តណាស់ទៅទៀត ត្រង់នេះហើយឃើញថាសំខាន់ជាងអានសៀវភៅ ព្រោះពាក្យចំរៀងដែលចុះលើក្រដាសមានតែសេចក្តីដែល



www.elibraryofcambodia.org

យើងអាចមើលឲ្យយល់បាន តែមិនបានពីរោះដូចមានគេច្រៀង ហើយបន្ទរភ្លេងឲ្យស្តាប់នោះឡើយ ។

**សេចក្តីបញ្ចប់**

ការមើលរាត្រីសមោសរនេះ ជាការជំនួយឲ្យមើលសៀវភៅបានយល់សាច់រឿងយ៉ាងល្អិតល្អន់ ហើយឲ្យចាំស្ទាត់នូវរឿងនោះបានយូរ ព្រោះសតិរបស់យើងបានទទួលអារម្មណ៍ដោយចក្ខុនិងសោតវិញ្ញាណផង ។

✧✧✧

## ពាក្យចោទផ្សេងៗ

៤១-តើគេសំគាល់មនុស្សដែលមានមនសិការដោយអំពើអ្វី? ចូររកឧទាហរណ៍ណាមួយមកបញ្ជាក់ផងអំពីបុគ្គលមានមនសិការក្នុងវិជ្ជាជីវៈរបស់ខ្លួន ។

## មនសិការ

**ក-ន័យរបស់ពាក្យ "មនសិការ"**

មនសិការប្រែថា "ការកំណត់ទុកក្នុងចិត្ត" ឬ ការមិនភ្លេចខ្លួន" បានសេចក្តីថា ការយកចិត្តទុកដាក់មិនមានភ្លេចស្មារតី មិនមានធ្វេសប្រហែសឡើយ ។



www.elibraryofcambodia.org

**ខ-តើគេសំគាល់មនុស្សដែលមានមនសិការដោយអ្វី?**

គឺដោយអំពើដែលមនុស្សនោះ បានប្រព្រឹត្តក្នុងការបំពេញ

-ចេះប្រើពេលវេលាដោយទៀងទាត់

-ចេះស្រឡាញ់តែការងារណាដែលធ្វើបានល្អ

-ចេះបារម្ភជានិច្ចក្រែងមិនបានសេចក្ដីចំរើនទៅអនាគត

__*១-សេចក្ដីទៀងត្រង់*__ : សិស្ស ឬភ្នាក់ងារក្នុងតំណែងរាជការណាមួយដែលមានមនសិការ តែងទៅសាលា ឬកន្លែងធ្វើការមុនម៉ោងជរាប ។ ការងារទាំងឡាយដែលគ្រូ ឬនាយចៅហ្វាយចាត់ឲ្យធ្វើ សិស្ស ឬភ្នាក់ងារនេះសុទ្ធតែធ្វើរួចស្រេច កាលណាគេត្រួតត្រាមើល ។ ការអ្វីដែលត្រូវធ្វើឲ្យហើយក្នុងថ្ងៃនេះ មិនដែលទុកដល់ថ្ងៃស្អែកឡើយ ។

ក្នុងការសង់អាគារមួយ បើកូនជាងយកចិត្តទុកដាក់មិនបង្អែរបង្អង់ឲ្យខាតពេលវេលា ឬក៏អ្នករ៉ាប់រងខាងគ្រឿងសង់បញ្ជូនរបស់មកឲ្យដោយទៀងទាត់ នោះអ្នកទទួលការស្ថាបនានេះ ក៏អាចបង្ហើយផ្ទះឲ្យទាន់កំណត់ពេលតាមកិច្ចសន្យាបាន ។

__*២-សេចក្ដីស្រឡាញ់ការងារដែលធ្វើបានល្អ*__

សិស្សមានមនសិការខ្លះ ខំផ្ចិតផ្ចង់អក្សរតាំងពីដើមទំព័រដល់ចុងទំព័រ ហើយខំរចនាសៀវភៅដោយអក្សរយ៉ាងវិចិត្រ ។ ភ្នាក់ងារខ្លះបើប្រារព្ធធ្វើការអ្វីមួយ ចង់ឲ្យតែការនោះគាប់ភ្នែកត្រូវចិត្តអ្នកផងទាំងពួង ។ កសិករខ្លះធ្វើរង ឬជីករណ្ដៅដាំដំណាំជាជួរយ៉ាងត្រង់ ដើម្បីឲ្យគាប់ភ្នែកអ្នកដទៃ ។ ជាងឈើខ្លះខំផ្ចិតផ្ចង់ការរបស់ខ្លួនឲ្យវត្ថុដែលធ្វើរួចនោះ ត្រូវចំណុចចិត្តអ្នកទិញ ។

គេគ្រាន់តែក្រឡេកមើល សាច់ការដែលអ្នកទាំងនេះធ្វើគេអាច



www.elibraryofcambodia.org

ដឹងថា អ្នកទាំងនេះ ចេះស្រឡាញ់ការងាររបស់ខ្លួន ពោលគឺធ្វើការដោយមានមនសិការនេះឯង ។

<u>*៣-សេចក្តីបារម្ភក្រែងមិនបានចំរើនទៅអនាគត*</u>

សិស្សឬភ្នាក់ងារ ឬកម្មករដែលមានមនសិការ ចង់ឲ្យតែបំណងណាមួយរបស់ខ្លួនឲ្យបានសម្រេចដូចចិត្ត ។ លុះបំណងនេះបានសម្រេចហើយ អ្នកទាំងនេះក៏នឹកឃើញបំណងអ្វីដែលប្លែកទៅទៀត ហើយចង់ឲ្យបំណងលើកក្រោយនេះ បានលទ្ធផលល្អលើសដើមទៅទៀត ការដែលចង់ឲ្យសេចក្តីបំណងទាំងឡាយនេះបានល្អឡើងៗ គឺមិនមែនដោយសេចក្តីលោភ ឬប្រកួតចង់យកឈ្នះចាញ់ដើម្បីបណ្តុះបង្អាប់អ្នកដទៃនោះទេ គឺប្រាថ្នាចង់ឲ្យតែចំណេះវិជ្ជា និងអាជីវៈរបស់ខ្លួនបានចំរើនជាលំដាប់ទៅ ។

<u>*៤-សេចក្តីបញ្ចប់*</u> : ដែលហៅថាសិស្សមានមនសិការនោះ មិនមែនសំដៅយកតែសិស្សណា ដែលរៀនពូកែឆើតដាច់គេក្នុងថ្នាក់នោះទេ ។ បើទុកជាសិស្សណាមួយរៀនអន់ជាងគេ ក៏ប៉ុន្តែយកចិត្តទុកដាក់ ដោយកាន់សេចក្តីទៀងទាត់ ដោយចេះស្រឡាញ់ការងាររបស់ខ្លួននោះហើយចេះព្រួយបារម្ភជានិច្ច ដោយខ្លាចក្រែងមិនបានចំរើនទៅអនាគតសិស្សនេះក៏សន្មតថាមានមនសិការដែរ ។ គេសង្កេតឃើញថាមនុស្សគ្រប់ឋានៈក្នុងលោកនេះ ឲ្យតែខំយកចិត្តទុកដាក់ក្នុងវិជ្ជាជីវៈរបស់ខ្លួនហើយ កម្រនឹងធ្លាក់ខ្លួនទៅក្នុងហីនភាពបានឡើយ ។



www.elibraryofcambodia.org

៤២- យុវជនទាំងឡាយ ដែលអ្នកមករៀននៅវិទ្យាល័យនេះ តើមានប្រយោជន៍អ្វី?

## ចំលើយ

យុវជន យុវនារី ដែលមករៀននៅវិទ្យាល័យនេះដើម្បី:

**ក- ជាប្រយោជន៍ដល់ខ្លួនគឺ :**

១ - ឲ្យមានចំណេះវិជ្ជាផ្សេងៗ គឺចេះអាន ចេះសរសេរ

២ - ឲ្យមានប្រាជ្ញាជ្រៅជ្រះ (ឲ្យចេះស្គាល់ការល្អអាក្រក់ ឲ្យចេះពិចារណារកសេចក្ដីពិត គឺលែងជឿអំពើអ្វីទាំងឡាយណាដែលមនុស្សល្ងង់តែងតែជឿ)

៣ - ឲ្យមានកិរិយាមារយាទល្អ (ឲ្យស្គាល់ច្បាប់ចរិយាសាស្ត្រ និងច្បាប់សុជីវធម៌ ឲ្យចេះគោរពវិន័យសាលា ដើម្បីដល់ថ្ងៃក្រោយទៅ ជាពលរដ្ឋចេះគោរពច្បាប់សំរាប់ស្រុក)

៤ - ឲ្យមានទម្លាប់ធ្វើការ ដោយមានរបៀបសណ្ដាប់ធ្នាប់ (មានរបៀបចែកពេលវេលាធ្វើការឲ្យបានទៀងទាត់ជាដើម)

៥ - ឲ្យស្គាល់របៀបរស់នៅក្នុងសង្គម (សិស្សណាដែលសំណាក់អាស្រ័យជាមួយគ្នាក្នុងសង្គម នឹងអាចពិនិត្យសង្កេតកិរិយាមារយាទគ្នាឯងបានគ្រប់សព្វ គឺស្គាល់ភាពនៃមនុស្សកាច ឬស្លូត ស្គាល់ភាពមនុស្សខ្ជិល ឬឧស្សាហ៍ដឹងថាកិរិយាយ៉ាងនេះ ធ្វើឲ្យគេចូលចិត្ត យ៉ាងនោះធ្វើឲ្យគេជិនឆ្អន់ សរុបទៅ គឺធ្វើឲ្យចេះជៀសវាងអំពើអាក្រក់ ដែលអាចហុចទុក្ខទោសឲ្យជាញឹកញាប់ ក្នុងដំណើរជីវភាពរបស់មនុស្ស)

៦ - ឲ្យអនាគតរបស់ខ្លួនបានល្អ គឺថ្ងៃក្រោយទៅឲ្យមានវិជ្ជាជីវៈ



www.elibraryofcambodia.org

មួយ(ក្នុងតំណែងរាជការក្តីក្នុងកសិកម្ម ឬពាណិជ្ជកម្ម ឬឧស្សាហកម្មក្តី) ដែលអាចចិញ្ចឹមខ្លួនឯងបានដោយស្រួលហើយថ្លៃថ្នូរផង ។

**ខ-ជាប្រយោជន៍ដល់គ្រួសារ**

បើថ្ងៃក្រោយយុវជននេះ មានវិជ្ជាជីវៈដែលអាចចិញ្ចឹមខ្លួនដោយស្រួលហើយ គ្រួសាររបស់គេក៏មានមុខមាត់ ហើយអាចរស់នៅបានដោយស្រួល ដោយសារតែគុណបំណាច់នៃចំណេះរបស់គេដែលបានស្វែងនៅសាលានេះឯង ព្រោះ"ចំណេះជាស្បៀងរកកំរៃ គ្មានអ្វីថ្លៃជាងវិជ្ជានេះឡើយ" ។

**គ-ប្រយោជន៍ដល់ជាតិ និងមាតុភូមិ**

យុវជនមករៀននៅវិទ្យាល័យសព្វថ្ងៃ ដើម្បីដល់ថ្ងៃក្រោយនឹងទៅជាពលរដ្ឋខ្មែរមួយដែលចេះអាន ចេះសរសេរ ។

- ដែលមានប្រាជ្ញាភ្លឺថ្លា
- ដែលមានកិរិយាមារយាទល្អ

ពោលគឺជាពលរដ្ឋមួយ ដែលមានសមត្ថភាព និងគុណសម្បត្តិដ៏បរិបូណ៌ដែលអាចទ្រទ្រង់ជាតិឲ្យថ្លៃថ្នូរ និងគាំពារកម្ពុជាឲ្យរឹងជំហរក្នុងឋានៈជាប្រទេសឯករាជ្យអង្វែងទៅបាន ។

**៤៣**-តើអ្វីដែលហៅថាពលរដ្ឋ ? តើពលរដ្ឋមានករណីយកិច្ចយ៉ាងណាខ្លះ ?

## ចំនងតែង

### សេចក្តីផ្តើម

ពលរដ្ឋគឺជាសមាជិករបស់រដ្ឋ ។ ឧទាហរណ៍ដូចជាក្នុងប្រទេសខ្មែរ



www.elibraryofcambodia.org

ជនជាតិខ្មែរ និងជនដែលរាប់ជាខ្មែរ ដូចជាចាម-គួយជាដើម និងជនខ្លះដែលផ្លាស់សញ្ជាតិជាខ្មែរ ជាពលរដ្ឋខ្មែរ ។ ឯជនបរទេសដែលនៅក្នុងព្រះរាជាណាចក្រ ដូចជាចិន-យួន-ក្លឹង្គ មិនមែនជាពលរដ្ឋខ្មែរទេ ។ ជនទាំងនេះគ្មានសិទ្ធិពេញដូចខ្មែរទេ គ្មានសិទ្ធិបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រជាដើម ។

ម្យ៉ាងទៀត ពាក្យពលរដ្ឋបានសេចក្ដីថា "កម្លាំងរបស់ប្រទេស" ព្រោះប្រទេសនីមួយៗ ដែលរុងរឿងរស់រានមានជីវិត ក៏អាស្រ័យនូវសមាជិករបស់ប្រទេសនោះឯង ។

ពលរដ្ឋគឺជនដែលមានសិទ្ធិពេញទី ។ កាលមានសិទ្ធិហើយនោះ ក៏ត្រូវមានករណីយកិច្ចផងដែរ ។

<u>*ករណីយកិច្ចរបស់ពលរដ្ឋ*</u> :

១-ពលរដ្ឋត្រូវមានចិត្តចង់ដឹងចង់ស្គាល់នូវកិច្ចការសាធារណៈទាំងឡាយ ដែលមានវិបត្តិកើតឡើងជាលំដាប់នៅក្នុងប្រទេសរបស់ខ្លួន និងព្រឹត្តិការណ៍ផ្សេងៗ ដែលផ្ទុះឡើងក្នុងសកលលោក ។ ត្រូវឆ្លៀតឱកាសអានសារពត៌មាន ស្ដាប់វិទ្យុ និងការឃោសនាផ្សេងៗ ដែលជាប្រទីបបំភ្លឺឲ្យដឹងការរាក់ជ្រៅសព្វយ៉ាង ។ ត្រូវចង់ដឹងឲ្យណាស់នូវដំណើរនយោបាយ ដែលសមាជិកនៃរដ្ឋាភិបាលរបស់ប្រទេសខ្លួនបានប្រើប្រាស់ជាលំដាប់មករាល់ៗថ្ងៃ ។

២-នៅពេលដែលរដ្ឋាភិបាលកំណត់ឲ្យបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រម្ដងៗ នោះពលរដ្ឋត្រូវចាំឲ្យច្បាស់ថា អនាគតរបស់ខ្លួន និងជីវិតនៃនគរនៅក្នុងសន្លឹកឆ្នោតដែលខ្លួនទំលាក់ទៅក្នុងហិបនោះឯង ។



www.elibraryofcambodia.org

ដូច្នេះមុននឹងទៅបោះឆ្នោត ត្រូវពិនិត្យពិចារណាឲ្យច្បាស់លាស់ កុំបោះទាំងប្រថុយ ទាំងងងឹតល្ងង់ ។ ពលរដ្ឋនីមួយៗត្រូវចង់ទៅបោះឆ្នោតដោយស្មោះ ដោយមានចិត្តពោរពេញទៅដោយសេចក្ដីសង្ឃឹមជានិច្ច ព្រោះករណីយកិច្ចរបស់ខ្លួន ។ ទោះបីរវល់យ៉ាងណាក៏ដោយ ក៏ត្រូវតែឆ្លៀតឱកាសទៅបោះឆ្នោតនេះដែរ ។

៣-ពលរដ្ឋត្រូវគោរពប្រតិបត្តិច្បាប់សំរាប់រដ្ឋ ។ មិនត្រឹមតែគោរពទេ គឺត្រូវឲ្យស្គាល់ច្បាប់នោះផង ។ ការដែលស្គាល់ច្បាប់នេះអាចធ្វើឲ្យពលរដ្ឋជៀសវាងទុក្ខទោសផ្សេងៗបាន ព្រមទាំងមិនហ៊ានបំពានច្បាប់ ឬធ្វើរំលោភលើសិទ្ធិអ្នកដទៃផង ។

៤-ពលរដ្ឋត្រូវបង់ពន្ធជូនរាជការ ព្រោះរាជការត្រូវការប្រាក់យកទៅចំណាយក្នុងប្រយោគសាធារណៈគ្រប់ជំពូក មានសាលារៀន មន្ទីរពេទ្យ ធ្វើថ្នល់ និងស្ពានជាដើម ឬក៏ទិញសព្វាវុធ ដើម្បីការពារស្រុកទេសឲ្យឋិតនៅក្នុងសន្តិសុខ ។ ជនណាដែលគេចវៀសមិនបង់ពន្ធ នឹងទុកជាជនក្បត់ច្បាប់ហើយ នឹងត្រូវរាជការផ្ដន្ទាទោស ។

៥-ពលរដ្ឋត្រូវប្ដូរជីវិតបូជាជាតិ និងមាតុភូមិ នៅពេលដែលប្រទេសរបស់ខ្លួន មានអាសន្នដោយសត្រូវចង់ពាធា ។ ដូច្នេះពលរដ្ឋទាំងប្រុស-ស្រី ត្រូវចេះវិជ្ជាទាហានគ្រប់ៗគ្នា ដើម្បីជាកំផែងរាំងរាទឹកដីបូរីនគររបស់ខ្លួន តាមទេសៈកាលៈដែលហុចឲ្យ ។

៦-ពលរដ្ឋមានករណីយកិច្ចដែលត្រូវបំពេញតែរាល់ៗថ្ងៃ គឺត្រូវខំធ្វើការក្នុងអាជីវៈរបស់ខ្លួន ដើម្បីសេចក្ដីចំរើនដល់នគរ ។

-ត្រូវគ្រប់គ្រងគ្រួសារឲ្យមានសុខភាពល្អ ត្រូវដុសខាត់ចរិយា និងបញ្ញារបស់បុត្រ-ធីតាឲ្យហ្មត់ចត់ ដើម្បីធ្វើឲ្យកុមារទាំងឡាយ ទៅជា



www.elibraryofcambodia.org

ពលរដ្ឋដែលមានគុណសម្បត្តិ និងសមត្ថភាពយ៉ាងពេញបរិបូណ៌ ក្នុងពេលខាងមុខនេះ ។

## សេចក្តីបញ្ចប់

ដោយដឹងច្បាស់ថា ជីវិតនគររំពឹងលើពលរដ្ឋខេមរជាតិទាំងឡាយត្រូវតម្រង់ចិត្ត ប្រែគំនិតគិតធ្វើម្តេច ឲ្យបានពេញជា "ពលរដ្ឋចេះដឹង-ស្មោះត្រង់-ឧស្សាហ៍-ក្លាហាន ហើយមានចិត្តភក្តីចំពោះជាតិ និងព្រះរាជបល្ល័ង្ក ដែលជាទីពំនាក់យ៉ាងកក់ក្តៅរបស់ខ្លួន ។

## ៤៤-កាលដែលឈឺធ្ងន់ យកជីវិតទៅបន់ដល់ជម្ងឺស្រន់ យកពងមាន់ទៅថ្វាយ

(សញ្ញាប័ត្រមធ្យមសិក្សាលើកទី១ ឆ្នាំ១៩៤២)

## សេចក្តីអធិប្បាយជាគំរូ

បុថុជ្ជនគ្រប់ប្រភេទ ក្នុងរយៈកាលដែលរស់នៅ សុទ្ធតែត្រូវជួបប្រទះនឹងភ័យ ឬឧបសគ្គណាមួយមិនខាន គឺមានភិតភ័យខ្លាចជាប់ទោសក្នុងផ្លូវតុលាការ ឬភិតភ័យក្នុងការនៅពេលដែលមានរោគាពាធមកញាំញី នៅពេលដែលសង្គ្រាមកំពុងផ្ទុះ នៅពេលដែលមានអាសន្នផ្សេងៗ ដូចយ៉ាងអគ្គីភ័យ ឬមានភ័យក្នុងចោរកម្មជាដើម ។ គេសង្កេតឃើញប្រាកដថា ជាធម្មតាជនភាគច្រើនកាលណាឈឺខ្លាំង ហើយក៏តាំងបន់ស្រន់សំបូងសម្រូងរកអស់អារ័ក្សទេព្រ័ក្សឬអ្វីៗទាំងឡាយ ដែលគេជឿជាក់ថាពូកែស័ក្តិសិទ្ធមែន ដោយពោលជាស័ព្ទវាចាថា បើខ្លួនបានរួចពីគ្រោះថ្នាក់ គឺសេចក្តីស្លាប់នោះនឹងមានដង្វាយ ឬរង្វាន់លាបំណន់យ៉ាងប្រសើរជាដាច់ខាត ។



www.elibraryofcambodia.org

ឯពាក្យថា "ឈឺធ្ងន់" នេះ មានន័យទូលំទូលាយទៅទៀត គឺសំដៅយកការភ័យខ្លាំង ដោយមានហេតុជាអាសន្នណាមួយ ។ ដែលថា "យកដីរីទៅបន់នោះ" គឺយករង្វាន់ណាដែលមានតម្លៃធំដុំ ដែលសន្យាថានឹងថ្វាយ ឬជូនឲ្យធ្ងនចិត្តដល់បុគ្គលដែលសន្មតថា មានមហិទ្ធិឫទ្ធិអាចជួយសង្គ្រោះឲ្យផុតពីភយន្តរាយបាន ។

អុញ! លោកថា "ដល់ជម្ងឺស្រន់យកពងមាន់ទៅថ្វាយ" សោះ គឺលុះកាលណាបានផុតភ័យហើយ គេមិនឃើញមានយក "ដីរីទៅ" ឬជាងណាទៅយកង៉ "ពងមាន់" ដែលជារបស់កំទេចកំទីឥតតម្លៃ ឥតខ្លឹមសារទៅលាបំណន់ គឺយកទៅជូនជារង្វាន់ខាន់ខៅវិញ ។ នរណាក៏តូចចិត្តដែរ បើនិយាយមិនទៀងយ៉ាងនេះ! ។

ជនជំពូកនេះ កាលបើឈឺខ្លាំង ទៅនិយាយនឹងលោកគ្រូពេទ្យថា សូមតែជួយកែរោគឲ្យជាចុះ នឹងរ៉ាប់រងនៅបំរើឥតយកឈ្នួលពាត់អ្វីឡើយ ។ ខ្លះទៀតកាលមានរឿងអ្វីមួយហើយខ្លាចជាប់គុកក៏ទៅអង្វរចៅក្រម ឬពឹងពាក់នរណាមួយសូមឲ្យជួយឲ្យផុតពីគ្រោះថ្នាក់ និងលក់គោលក់ផ្ទះតបស្នងសងគុណឲ្យធ្ងនចិត្ត មានខ្លះទៀតកាលដែលឃើញអាសន្នមកដល់ហើយ ក៏បន់ព្រះវត្តនេះវត្តនោះ ថាឲ្យតែរួចពីមរណភ័យចុះនឹងកសាងព្រះវិហារ ឥដ្ឋឬធ្វើបុណ្យអ្វីមួយយ៉ាងអស្ចារ្យរំឭកគុណ តែគេសង្កេតឃើញថាពាក្យសន្យាទាំងអម្បាលម៉ាននេះគ្រាន់តែបន្លឺឡើង ក្នុងពេលដែលកំពុងភ័យនោះទេ កាលផុតពីអន្លង់ទុក្ខហើយ ជនទាំងនោះ ច្រើនតែរកឧបាយនាយអាយដោះស្រាយគេចកែសំដីដើមអស់ ឬក៏ជូនជារង្វាន់បន្តិចបន្តួចសោះតែខានបំណ្ណោះឯង ។

អាស្រ័យហេតុនេះ គប្បីចាំឲ្យជាក់ថា បើបុគ្គលណាមកអង្វររកឲ្យ



www.elibraryofcambodia.org

ជួយក្នុងកិច្ចការកង្វល់ណាមួយ បើល្មមនឹងជួយសង្គ្រោះបានក៏សង្គ្រោះដោយស្មោះស្ម័គ្រទៅ កុំស្តាប់ស័ព្ទវាចាដែលសន្យាថា នឹងឲ្យនេះឲ្យនោះជាឧត្តមរង្វាន់ទៅថ្ងៃក្រោយ ព្រោះក្រែងជួនជាមិនបានរង្វាន់ធំ ដូចពាក្យសន្យានោះទេ នាំតែម្នោម្នេញខ្ទាញ់ក្នុងចិត្តជាក្រោយឥតអំពើ ។

ចំណែកបុគ្គលដែលមិនធ្វើតាមពាក្យសន្យាវិញ ត្រូវឲ្យដឹងខ្លួនថា ក្នុងមួយជីវិតនេះមិនមែនមានភ័យតែម្តងប៉ុណ្ណោះទេ ត្រូវចាំឲ្យច្បាស់ថា ជីវភាពរបស់មនុស្សក្នុងលោកីយ រមែងស្មុគ្រស្មាញទៅដោយចំរូងអាសន្នគ្រប់ជំពូក មិនលែងថ្ងៃណាមួយនឹងត្រូវការពឹងពាក់គេទៀតឡើយ ដូច្នេះមិនគួរនឹងធ្វើកន្តើយចំពោះគុណបំណាច់របស់គេទេ ។

## ៤៥-ទុកវាចាស់ ប្រើណាស់វាថ្មី

(សញ្ញាប័ត្រមធ្យមសិក្សាលើកទី១ ឆ្នាំ១៩៤៥)

## សេចក្តីផ្តើម

ដោយសង្កេតឃើញថាជនខ្លះ តែងតែបោះបង់ចោលនូវដំរេះ ឬវិជ្ជាផ្សេងៗដែលបានស្វែងមកហើយ ទើបចាស់ៗចងជាបទបញ្ញាថា "ទុកវាចាស់ ប្រើណាស់វាថ្មី" ដើម្បីជាឱវាទដាស់តឿនរំឭកឲ្យជនដែលមានសុវិជ្ជាណាមួយ ខំព្យាយាមឲ្យរឹតតែភ្លឺយល់ច្បាស់ ការជ្រៅជ្រះតទៅទៀត ។

__*អត្ថរសនៃភាសិត*__ : ចូរយើងសង្កេតមើលកាំបិតព្រាដែលគេបោះបង់ចោលនៅក្រោមគ្រែ សាច់វាឡើងខ្មៅអែ ច្រេះចាប់ស៊ីសព្វសាច់ដែក នឹងយកប្រើការប្រាស់រាល់ៗ ថ្ងៃមុខវាសផ្ទាវ ឡើងរលោងភ្លឺថ្លា ប្រើការកាប់អ្វីមុតយ៉ាងចំណាប់ ល្អលើសកាំបិតដែលទើបនឹងច្រុងរួចទៅ



www.elibraryofcambodia.org

ទៀត ។ ឯកាំបិតដែល "ទុកចោល" នោះវា "ចាស់" ខូចចោលម្យៀត ចំណែកកាំបិតដែលគេ "ប្រើណាស់" នោះវារឹតតែ "ថ្មី" ទៅវិញ ត្រង់នេះព្រឹទ្ធបណ្ឌិតចង់ពន្យល់ថា ចំណេះវិជ្ជាសព្វសារពើ ដែលមានក្នុងខ្លួន ទោះតិចក្តីច្រើនក្តី បើមិនព្យាយាម ប្រើប្រាស់ទេ នឹងអាប់ស្រពោនអន់ថយ ឬក៏ភ្លេចបាត់សូន្យសុងអស់ទៅវិញជាមិនខាន ។ ចំណែកវិជ្ជាណាដែលបានប្រើប្រាស់ជាអចិន្ត្រៃយ៍ ចំណេះវិជ្ជានោះរឹតតែកើតចំរើនមានរស្មីជាលំដាប់រៀងដរាបទៅ ។

*ឧទាហរណ៍* : អ្នកចេះខាងវិជ្ជាគុណដំបង ចំបាប់ ប្រដាល់ បាញ់ស្នា បាញ់កាំភ្លើង អ្នកចេះខាងរបាំ អ្នកចេះស្ទាត់នូវធម៌អាថ៌មន្តអាគមសព្វសារពើ អ្នកពូកែលេងកីឡាគ្រប់ប្រភេទ អ្នកចេះភាសាជាតិដទៃណាមួយ អ្នកដែលមានចំណេះខាងអក្សរសាស្ត្រ វិទ្យាសាស្ត្រ គណិតសាស្ត្ររបស់ខ្លួន វិជ្ជានោះក៏អស់តម្លៃ អាប់រស្មីប្រើការមិនបាន ជួនកាលភ្លាំងភ្លេចទៅវិញក៏មាន ។ បើព្យាយាមប្រើប្រាស់ជានិរន្តរ៍ទៅ វិជ្ជាក៏រឹតតែចំរើនមានតម្លៃរុងរឿងដរាបដែរ ។

កាលពីឆ្នាំ ១៩៤៥ មានជនជាតិខ្មែរជាច្រើនចេះនិយាយភាសាជប៉ុន សព្វថ្ងៃនេះ ដោយហេតុដែលគ្មានប្រើប្រាស់ភាសានេះក្នុងស្រុកខ្មែរ ខ្មែរក៏ភ្លេចអស់រលីងទៅវិញ ។ សាស្ត្រាចារ្យណាដែលត្រូវបង្រៀនដោយពិសេសដាច់មុខខាងគណិតសាស្ត្ររាល់ៗថ្ងៃ សាស្ត្រាចារ្យនោះរឹតតែភ្លឺច្បាស់ខាងក្បួនតម្រានៃវិជ្ជានេះ គ្រាន់បើជាងកាលទើបនឹងចេញពីសាលារៀនទៅទៀត ។ សិស្សណាដែលចេញពីសាលាទៅ ខំសង្វាតអានសៀវភៅ ឬសរសេរជាពត៌មានផ្សេងៗ នឹងបានចំរើនខាងអក្សរសាស្ត្រជាដាច់ខាត ។



www.elibraryofcambodia.org

## សេចក្ដីបញ្ចប់

ដោយបានជ្រាបច្បាស់នូវអត្ថរសនៃសុន្ទរោវាទនេះហើយ គប្បីកុំកន្ដើយរាយមាយបោះបង់ចោលនូវសុវិជ្ជា ដែលបានស្វះស្វែងអស់កាលដ៏យូរអង្វែងមកហើយ ។ សុវិជ្ជាជាទ្រព្យដ៏ឧត្ដម ហើយវិសេសជាងទ្រព្យនានា ។ គួរឲ្យមានសេចក្ដីស្ដាយជាអនេកអនន្ត ចំពោះរបស់វិសេសនេះដែលបានមកពីនៅក្នុងកណ្ដាប់ដៃហើយៗវិនាសសាបសូន្យទៅវិញបាត់ ព្រោះតែការធ្វេសប្រហែសខ្វះធម៌ព្យាយាមមួយយ៉ាងប៉ុណ្ណោះ ។

## ៤៦-សំដីសជាតិ មារយាទសត្រកូល

(សញ្ញាប័ត្រមធ្យមសិក្សាលើកទី១ ឆ្នាំ១៩៤៥)

## សេចក្ដីអធិប្បាយជាគំរូ

មាត់ជាគ្រឿងលាតត្រដាងនៃចិត្ត និងគំនិតឲ្យគេស្គាល់ ។ កិរិយាដែលប្រព្រឹត្តជាអចិន្ត្រៃយ៍ម៉ែឲ្យស្គាល់ភាពបុគ្គលល្អ ឬអាក្រក់ ជាបណ្ឌិតឬពាល ។ ដោយជ្រាបច្បាស់នូវហេតុការណ៍ទាំងឡាយនេះហើយ បានជាបុព្វាចារ្យរបស់យើងបានចងជាបញ្ហាទុកមកថា "សំដីសជាតិ មារយាទសត្រកូល" ។

"សំដី" មានពីរយ៉ាង គឺសេចក្ដីដែលនិយាយ និងសេចក្ដីដែលសរសេរចុះក្នុងក្បួនតម្រាផ្សេងៗ ។ លោកថា "សំដីសជាតិ" គឺសំដីនេះហើយដែលបំផុសឲ្យឃើញជាក់ស្ដែងនូវលក្ខណៈកិរិយារបស់ជាតិកំណើតនៃបុគ្គលណាមួយឬសាសន៍ណាមួយ ។ គេសំគាល់មនុស្សណា



www.elibraryofcambodia.org

ម្នាក់ឬជនជាតិណាមួយ ឆ្លាតឬល្ងង់ ពាលឬបណ្ឌិត កាចឬស្លូត ល្អឬអាក្រក់ ដោយសំដីដែលបុគ្គលនោះឬជនជាតិនោះ ប្រាស្រ័យនិយាយឬសរសេរ ។ បើជាតិជាបណ្ឌិតសំដីនិយាយក៏បរិបូណ៌ដោយគំនិតប្រាជ្ញា បើជាតិជាអ្នកប៉ិនរកស៊ី សំដីថ្វីមាត់ក៏ធ្វើឲ្យឃើញថា ស្ទាត់ជំនាញខាងជំនួញមែន បើជាតិកំណើតជាអ្នកជឿខ្មោចអារក្ស មេមត់បង់បត់ សំដីដែលសម្ដែងក៏ថ្លែងឲ្យឃើញថា ជាអ្នកល្ងង់ជឿតែការផ្ដាសៗ ។ បើជាតិកំណើត "អាអ្នកលេងកាប់ចាក់" វោហារដែលខ្ជាក់មកក៏បញ្ជាក់ភ្លាមថា ជាអ្នកកាចសាហាវ ពោរពេញទៅដោយពុតពាល ។ កុមារដែលមានសំដីផ្អែមពីរោះចេះស្គាល់ខ្ពស់ទាប នឹងត្រូវគេសំគាល់ថា ជាកុមារមានជាតិកំណើតល្អត្រឹមត្រូវ ។ អ្នកស្រែក្បែរព្រៃភ្នំ បើនឹងហារនិយាយឡើង ក៏ធ្វើឲ្យឃើញច្បាស់ថា ជាជនអ្នកមិនទាន់ស្គាល់អារ្យធម៌ច្បាស់លាស់នៅឡើយ ។ ឯពាក្យ "សំដីសជាតិ" នេះ មានអត្ថរសដូចគ្នានឹងសេចក្ដីដែលព្រះបាឡាត់ឧត្តមលិខិតសុង-ស៊ីវ បានចងទុកក្នុង "សៀវភៅសុភាសិតសង្គ្រោះ" ថា "ស្គាល់ ឆ្លាត ឬល្ងង់ វៀចវេរឬត្រង់ដោយការចរចា" ។

ឯពាក្យថា "មារយាទសត្រកូល" វិញនោះក៏មានន័យប្រហែលៗនឹងសេចក្ដីនៃវគ្គទី១ដែរ តែគេសំដៅខាងមារយាទវិញ ។ មារយាទគឺឫកពា ឥរិយានៃការប្រព្រឹត្តទូទៅក្នុងផ្លូវល្អ ឬអាក្រក់ ។ ពាក្យថា "សត្រកូល" មានន័យថា មារយាទល្អឬអាក្រក់របស់បុគ្គលម្នាក់ ឬសាសន៍ណាមួយ អាចបំផុសឲ្យឃើញនូវពូជពង្សផៅ ល្អឬអាក្រក់របស់ខ្លួនបាន ។ បើមារយាទថោក ត្រកូលក៏ថោក បើមារយាទថ្លៃត្រកូលក៏ថ្លៃ ។ ក្នុងគ្រួសារដែលមានកូនម្នាក់ធ្លាក់មានដៃលួចគេ និងកាន់មារយាទចោរ



www.elibraryofcambodia.org

ត្រកូលនោះត្រូវសំគាល់ថាជាពូជចោរ ។ តរុណីណាដែលមានមារយាទមិនសមរម្យ គឺប្រព្រឹត្តខុសគន្លងប្រពៃណីនៃនារីខ្មែរ នឹងបង្ហាញឲ្យឃើញថាត្រកូលរបស់តរុណីនោះ ជាត្រកូលមិនថ្លៃថ្នូរ ជាហេតុធ្វើឲ្យគេញញើតមិនហ៊ានទៅលាយឡំក្នុងពូជពង្សជាមួយផង ។ កុមារណាដែលមានមារយាទសុភាពរាបសា ស្គាល់ខ្ពស់ទាប កុមារនោះធ្វើឲ្យសំគាល់បានថាជាអ្នកមានពូជអម្បូរល្អបរិសុទ្ធ ។

ដោយហេតុដឹងច្បាស់ថា "សំដីសជាតិ មារយាទសត្រកូល" យ៉ាងនេះ គប្បីជនានុជនប្រុងសតិសម្បជញ្ញៈ ក្នុងការនិយាយស្ដី ហើយព្យាយាមកាន់ឬកពាមារយាទឲ្យថ្លៃថ្នូរ ធ្វើខ្លួនឲ្យសមរម្យជាជនអ្នកជាតិកំណើត និងត្រកូលល្អ ខ្ពង់ខ្ពស់អង្វែងទៅ ។

## ៤៧-ត្រីក្នុងមួយត្រក តែស្អុយមួយ វាស្អុយទាំងអស់

(សញ្ញាប័ត្រមធ្យមសិក្សាលើកទី២ ឆ្នាំ ១៩៤៨)

## សេចក្ដីអធិប្បាយជាគំរូ

ដើម្បីជាសេចក្ដីទូន្មានដល់សមាជិកក្នុងគ្រួសារ ក្នុងសង្គមទាំងមូលឲ្យប្រព្រឹត្តត្រឹមត្រូវល្អ នោះចាស់បុរាណបានប្រឌិតនូវពាក្យមួយបទថា "ត្រីក្នុងមួយត្រក តែស្អុយមួយវាស្អុយទាំងអស់" ។

សង្គមតូចធំគ្រប់ប្រភេទ នឹងមានកិត្តិយសឧដុង្គឧត្តម ឬអាប់យសថោកទាប ក៏អាស្រ័យឥរិយាបថនៃសមាជិកក្នុងសង្គមនោះ ។ សមាជិកតែម្នាក់សោះ កាលបើបានប្រព្រឹត្តអំពើដ៏លាមកណាមួយហើយ រមែងធ្វើឲ្យសៅហ្មងដល់នាមនៃសង្គមទាំងមូលបានមិនខុសគ្នាពីត្រីស្អុយតែ



www.elibraryofcambodia.org

មួយសោះ ធ្វើឲ្យគេសរុបសេចក្តី ត្រឹមក្នុងមួយត្រកស្គុយទាំងអស់ដែរ ។

សមាជិកម្នាក់ ដែលធ្វើឲ្យខូចឈ្មោះសម្លេងនៃសង្គមទាំងមូលយ៉ាងនេះ មានការប្រៀបធៀបទៅនឹងសាកសពអសុភតែមួយអាចធ្វើឲ្យសាយក្លិនអសោចន៍ពេញសួនច្បារឧទ្យានបាន ។

ដោយអាស្រ័យហេតុនេះ គប្បីសមាជិកម្នាក់ៗ ប្រុងសតិរៀងៗខ្លួនជៀសវាងអំពើពុតអាក្រក់ទាំងឡាយដែលមានពិសពាល អាចធ្វើឲ្យក្រុមសង្គមទាំងមូលខូចកិត្តិយសបាន ។

បុត្រធីតាក្នុងគ្រួសារ គប្បីកាន់កិរិយាមារយាទឲ្យវិសេស ពលរដ្ឋគ្រប់ឋានៈ ត្រូវដឹងឲ្យប្រាកដថានគរទាំងមូល នឹងមានកិត្តិស័ព្ទល្អ ក៏អាស្រ័យតែពលរដ្ឋមានសមត្ថភាព និងគុណសម្បត្តិដ៏បរិបូណ៌ដែរ ។

ឧបមាដូចជាមានជនជាតិខ្មែរម្នាក់ ត្រូវចេញទៅបំពេញបេសកកម្មផ្សេងៗ នៅប្រទេសក្រៅ កាលបើជនជាតិខ្មែរនេះ ប្រព្រឹត្តមិនត្រឹមត្រូវមានស៊ីផឹកស្រវឹងឡែឡពេញផ្លូវថ្នល់ ឬក៏ចាប់កូនក្រមុំគេ ដោយកម្លាំងពាល ឬនិយាយតែផ្តេសផ្តាសឥតគិតមុខក្រោយនោះ ជនជាតិខ្មែរទាំងស្រុកទាំងប្រទេស ក៏ត្រូវគេល្មួចតិះដៀលថាជាជនជាតិមិនថ្លៃថ្នូរបាន ។

នារីណាមួយ ដែលមានឫកពាមិនសមរម្យតាមគន្លងប្រពៃណីនៃត្រកូលខ្មែរ នឹងធ្វើឲ្យគ្រួសាររបស់ខ្លួនអាម៉ាស់មុខជាអង្វែងអស់មួយពូជ ។ សិស្សណា ទាហានណា ភ្នាក់ងារណា ឬបព្វជិតណាមួយប្រព្រឹត្តអំពើដ៏លាមក នឹងត្រូវដៅថាពួកសាលានេះ កងទាហាននេះ ក្រុមក្រសួងឯណោះ វត្តណោះទៀត សុទ្ធតែពួកខិលខូចព្រហើនកោងកាចទាំងអស់ ។

ហេតុដូច្នេះ ដើម្បីជាសិរីកិត្តិយស ដើម្បីសេចក្តីចំរើនដល់សង្គម



www.elibraryofcambodia.org

គ្រួសារ ដល់ជាតិសាសនាទាំងមូលត្រូវកាន់គំនិតមារយាទឲ្យប្រសើរជាអង្វែងទៅ ។

**៤៨-អ្នកមានរក្សាខ្សត់ ដូចសំពត់ពាំទពីក្រៅ អ្នកក្រជួររក្សា ដូចសំពៅនួចសំង៉ាន**

(សញ្ញាប័ត្រមធ្យមសិក្សាលើកទី១ ឆ្នាំ១៩៤៩)

## ចំលងតែង

### សេចក្ដីផ្ដើម

ក្នុងលោកសន្និវាសនេះ កុំនរណាអួតអាងថា រស់នៅដោយឥតពឹងពាក់គ្នាទៅវិញទៅមកនោះ ។ ព្រឹទ្ធបណ្ឌិតបានទូន្មានថាឲ្យចេះយកអាសាគ្នាទៅវិញទៅមក ទើបជីវភាពមានដំណើរទៅក្រោយស្រួល ទៅកាន់សេចក្ដីសុខចំរើនគ្រប់ប្រការ ។ លោកបានចងជាបទប្រស្នាថា :

" **អ្នកមានរក្សាខ្សត់ ដូចសំពត់ពាំទពីក្រៅ**

**អ្នកក្រជួររក្សាខ្លៅ ដូចសំពៅនួចសំង៉ាន** "

*វគ្គទី១* : **អ្នកមានរក្សាខ្សត់ ដូចសំពត់ពាំទពីក្រៅ**

អ្នកមានភោគសម្បត្តិ ត្រូវមានធម៌សន្ដោសប្រោសមេត្តាករុណាបីបាច់ចិញ្ចឹមអ្នកកំសត់ទុគ៌ត ឲ្យរស់រានមានជីវិតស្ថិតស្ថេរនឹងគេ ឲ្យមានមុខរបរចិញ្ចឹមពោះ ឲ្យមានសេរីភាពក្នុងការផ្សេងៗ លើកទឹកចិត្តអ្នកក្រីក្រឲ្យរីករាយដោយសម្មាវាចាផ្អែមពីរោះ បិទបាំងរាំងរាការពារអ្នកក្រីក្រឲ្យជ្រកកោនក្រោមម្លប់របស់ខ្លួន...កិច្ចសង្គ្រោះទាំងអស់នេះហើយហៅថា "រក្សាខ្សត់" ។ លោកប្រៀបធៀប សង្គហកម្មនេះទៅនឹងសំពត់

ដែលស្រោបបិទបាំង សរីរៈរាងកាយមិនឲ្យក្ដៅរងាបាន ។

*វគ្គទី២* : **អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន**

អ្នកមានចំណេះវិជ្ជា មានសតិបញ្ញាជ្រៅជ្រះ ត្រូវណែនាំអ្នកខ្លៅ អ្នកឆោត អ្នកល្ងង់ ឲ្យចាកអន្លង់ងងឹតគឺអវិជ្ជា ទៅកាន់ឋានដ៏ភ្លឺស្វាងវិញ គឺបើកភ្នែក បើកត្រចៀក បើកមាត់អ្នកល្ងង់ ឲ្យឈប់ខ្វាក់ ឈប់ថ្លង់ ឈប់គតទៅទៀត ណែនាំគ្នាដោយសន្សឹមៗបន្តិចម្ដងៗ ឲ្យដល់ត្រើយ កុំបោះបង់ចោលដោយឥតមេត្តា ឥតធម៌សន្ដោសត្រូវគាំពារ រក្សាអ្នកល្ងង់ យិតយោងសណ្ដោងគ្នា បានរស់នៅដោយសុខសាន្ត ក្រោមអានុភាពនៃចំណេះវិជ្ជារបស់ខ្លួនផង ។ ការស្រោចស្រង់អ្នកល្ងិតល្ងង់ ដែលឥតដំរេះវិជ្ជានេះហើយហៅថា " រក្សាខ្លៅ " លោកប្រៀបធៀប " អ្នកប្រាជ្ញដែលរក្សាខ្លៅ " នេះទៅនឹង " សំពៅដែលរក្សានូវសំប៉ាន " ។ សំពៅជាភេត្រា នាវាធំៗ ផ្ទុកអ្នកដំណើរនិងអីវ៉ាន់សព្វសារពើកាត់សមុទ្រសាគរដ៏ធំធេង ។ សំពៅតែងសណ្ដោងយកទៅជាមួយនូវកូនសំប៉ានគឺទូកចម្លងតូចៗ ។

*ខ្លឹមសារនៃភាសិត* : សុភាសិតនេះញ៉ាំងអ្នកមានឲ្យចេះរក្សាអ្នកខ្សត់ ញ៉ាំងអ្នកប្រាជ្ញឲ្យចេះរក្សាអ្នកខ្លៅ តើដោយហេតុអ្វី ? ។ អ្នកមានដែលត្រូវរក្សាខ្សត់ ឬប្រាជ្ញដែលត្រូវរក្សាអ្នកខ្លៅ ក៏មកពីយល់ឃើញថាក្នុងការរស់នៅ គឺសុទ្ធតែមានពឹងពាក់គ្នាទៅវិញទៅមក សេចក្ដីអកុសលជាធម៌មិនទៀង វាតែងវិលវល់ប៉ះពាល់រាល់រូបកាយ ។ នៅពេលដែល " អ្នកមាន " ឬ " អ្នកប្រាជ្ញ " មានអាសន្នអន្តរាយ នោះត្រូវពឹងកម្លាំង " អ្នកក្រ " និង " អ្នកល្ងង់ " ទាំងនេះឯងវិញ ។ អ្នកមានរក្សាអ្នកក្រដោយកម្លាំងទ្រព្យ អ្នកប្រាជ្ញរក្សាអ្នកខ្លៅដោយកម្លាំងចំណេះវិជ្ជានិងបញ្ញា ឯអ្នកក្រ



www.elibraryofcambodia.org

និងអ្នកល្ងង់យកអសារអ្នកមាននិងប្រាជ្ញដោយកម្លាំងកាយវិញដែរ ។ កិច្ចរក្សាគ្នាទៅវិញទៅមកនេះ មានការប្រៀបប្រដូចទៅនឹងសំពៅដែលសណ្តោងសំប៉ាននោះឯង ។ នៅពេលដែលសំពៅលេចធ្លុះធ្លាយត្រូវកូនសំប៉ានចេញប្រសាច ផ្ទេរអីវ៉ាន់ និងសង្គ្រោះអ្នកដំណើរក្នុងសំពៅនោះ ឬបើគ្មានគ្រោះថ្នាក់អ្វីទេ កាលបើសំពៅចូលចតនៅអែបឆ្នេរសមុទ្រពុំបានដោយរាក់ក៏ត្រូវកូនសំប៉ានចេញព្រាតព្រូតគ្នាដឹកជញ្ជូនអ្វីៗទាំងឡាយពីក្នុងសំពៅទៅដាក់ច្រាំងឬពីមាត់ច្រាំងទៅដាក់សំពៅវិញដែរ ។

**សេចក្តីបញ្ចប់**

កុំអាងតែខ្លួនមានទ្រព្យ ស្អប់ខ្ពើមអ្នកខ្សត់ កុំអាងតែខ្លួនចេះ ស្អប់ខ្ពើមអ្នកល្ងង់ ត្រូវយកអសារគ្នាទៅវិញទៅមកជាដរាប នេះហើយដែលបណ្ឌិតតែងសរសើរថាជាឱវាទដ៏ប្រពៃអាចញុំាងលោកឲ្យទៅកាន់នូវសន្តិភាព វឌ្ឍនភាពគ្រប់កាលវេលា ។

### ៤៩-អណ្តាតជាអាទិកន្លង បានសុខទុកផងពីព្រោះអណ្តាត

(សញ្ញាប័ត្រមធ្យមសិក្សាលើក២ ឆ្នាំ១៩៥០)

## សេចក្តីអធិប្បាយជាគំរូ

ជាតិអំពៅមានរសផ្អែមវិសេសណាស់ តែបណ្ឌិតយល់ថា សុភាសិតមានជាតិលើសអំពៅទៅទៀត ដូច្នេះហើយបានជាបណ្ឌិតនានាក្នុងសកលលោកមិនជិនណាយនឹងចារឹកក្នុងក្បួនច្បាប់ នូវសុភាសិតគ្រប់បែបផែន ដូចមានសេចក្តីថា" អណ្តាតជាអាទិកន្លង បានសុខទុកផង ពីព្រោះអណ្តាត" នេះជាដើម ។ យើងនឹងអធិប្បាយសំរាយដោយសង្ខេប



www.elibraryofcambodia.org

នូវសុភាសិតនេះ ដើម្បីនឹងបំផុសឲ្យឃើញថាតើរសជាតិនៃសម្មាវាចាផ្អែមពីរោះយ៉ាងណាទៅ ។

សុខ និងទុក្ខ សេចក្ដីចំរើននិងអន្តរាយ កើតឡើងពី "អណ្ដាត" គឺពីមាត់ដែលជាគ្រឿងលាតត្រដាងគំនិត និងមនោសញ្ចេតនា ។ គួរតែប្រយ័ត្នមាត់កុំនិយាយឲ្យផ្លាតខុស ព្រោះសំដីដែលបន្លឺឡើងអាចនាំទុក្ខទោសដល់អាត្មាបាន ។ បើអណ្ដាតដែលរលាស់សំដីទៅធ្វើឲ្យគេត្រេកអរសាទរ ចូលចិត្តស្រឡាញ់រាប់អាន គោរពកោតខ្លាច គេសន្មតថាអណ្ដាតបង្កើតនូវសេចក្ដីសុខ សេចក្ដីចំរើន គឺធ្វើមនុស្សឲ្យមានសិរីសួស្ដី ។ ផ្ទុយទៅវិញ បើអណ្ដាតដែលគ្រលៀសសំដីទៅធ្វើឲ្យក្ដៅក្រហាយឈឺចិត្តអាម៉ាស់មុខ ឃ្លាងលាភផ្សេងៗ គេសន្មតថា អណ្ដាតជាគ្រឿងបង្កើតនូវទុក្ខទោសជាអនេកកប្បការ មានបង់ប្រាក់កាស ជាប់គុកឬបង់អាយុសង្ខារក៏មាន ដូចយ៉ាងនិយាយអាក្រក់ពីគេ ជេរបញ្ចោរគេ អួតអាងពីខ្លួនឯង សម្ដែងមតិដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃជាដើម ។

ដោយអាស្រ័យហេតុនេះហើយ បានជាអ្នកប្រាជ្ញបានចងជាតម្រាសុភាសិតជាច្រើនទៀត ដែលមានអត្ថរសដូចៗគ្នាគួរត្រិះរិះពិចារណាគឺសុខតែទូន្មានឲ្យចេះប្រុងប្រយ័ត្នជាទីបំផុតក្នុងការនិយាយស្ដី ។ ក្នុងសៀវភៅ " សុភាសិតសង្គ្រោះ " ព្រះបាឡាត់ឧត្ដមលិខិតសុង-ស៊ីវបានសរសេរចុះជា "ភ្លាត់មាត់មិនទប់កំពប់ប្រាក់" ។ សុភាសិតកមួយទៀតសម្ដែងថា "បើរនាបបាក់មានឫស្សីជួស បើពាក្យវាហួសគ្មានអ្វីជួសបាន " ។ ពាក្យទំនៀមមួយវិញនោះប្រឌិតថា "ភ្លាត់ជើងៗបាក់មានថ្នាំបិទ ភ្លាត់មាត់មិនគិតបានទុក្ខទោស" ។



www.elibraryofcambodia.org

ដូច្នេះក្នុងការនិយាយស្តី គួរតែប្រុងប្រយ័ត្នឲ្យណាស់ ព្រោះពាក្យសំដីដែលនិយាយហួសទៅហើយ មិនងាយឡើយនឹងលុបលាងវិញបាន ។ ភាសិតបារាំងមួយទៀតទូន្មានថា "ត្រូវបង្វិលអណ្តាតប្រាំពីរជុំមុននឹងនិយាយ " គឺមុននឹងសម្តែងមតិណាមួយ គប្បីយកមតិនោះមកពិចារណា ឲ្យល្អិតល្អន់ជ្រៅជ្រះមុនសិន ។ ត្រូវចាំឲ្យច្បាស់នូវពាក្យទូន្មានពីបុរាណថា " ស្តីការមុខក្រោយកុំឲ្យភ្លាត់ កុំអាងមានមាត់ចេះតែថា ពាក្យពុលតែជ្រុសទៅកាលណា កើតទោសវេរាគួរកុំភ្លេច " ។

**៥០-តើមានន័យយ៉ាងណាខ្លះ ពាក្យចាស់ដែលថា "ចិត្តល្អក្រខ្លួន" និង "ចិត្តល្អក្រមិនយូរ" ចូរពិនិត្យសេចក្តីទាំងពីរនេះ តើណាមួយខុស ណាមួយត្រូវ ឬត្រូវទាំងពីរ។ ចូររកឧទាហរណ៍មកបញ្ជាក់ឱ្យបានច្បាស់លាស់ផង។**

## ចំលើយ

### សេចក្តីផ្តើម

ច្បាប់ចរិយាសាស្ត្រ និងពុទ្ធឱវាទបានទូន្មានឲ្យប្រព្រឹត្តតែអំពើល្អចំពោះអ្នកដទៃ ។ តាមធម្មតា អំពើល្អដែលបានធ្វើនេះ លោកថាមិនបាត់ទៅណាឡើយ ព្រោះកាលណាយើងឲ្យសុខទៅគេៗ ក៏ឲ្យសុខមកយើងវិញក៏មាន ប៉ុន្តែឲ្យចេះប្រយ័ត្នក្នុងការធ្វើល្អនេះ ព្រោះការធ្វើល្អឥតពិចារណា ជាហេតុធ្វើឲ្យបានផលអាក្រក់វិញក៏មាន ដូច្នេះហើយបានជាព្រឹទ្ធាចារ្យរបស់យើងលោកបានចែងជាបទប្រស្នាពីរប្រការឲ្យត្រិះរិះគឺ "ចិត្តល្អក្រខ្លួន" និង "ចិត្តល្អក្រមិនយូរ" ។

<u>*ន័យរបស់ឃ្លាទីមួយ*</u> : "ចិត្តល្អក្រខ្លួន" :



www.elibraryofcambodia.org

ចិត្តល្អនេះ បានសេចក្ដីថា ធ្វើចិត្តសប្បុរសចំពោះអ្នកដទៃ ដោយចំណាយប្រាក់កាសទ្រព្យសម្បត្តិផ្សេងៗ ដើម្បីជួយស្រោចស្រង់សង្គ្រោះអ្នកដទៃ ។ ឯពាក្យថា "ចិត្តល្អក្រខ្លួន" បានសេចក្ដីថាការដែលសប្បុរសនេះ បើចេះតែធ្វើដោយឥតពិចារណា ឥតមានព្រំដែនទេនឹងនាំឲ្យ "ក្រខ្លួន" គឺអស់ទ្រព្យសម្បត្តិរបស់ខ្លួន ឬទទួលគ្រោះថ្នាក់អ្វីម្យ៉ាងៗដល់ខ្លួនវិញក៏មាន ។

*ឧទាហរណ៍* : ក-ការដែលចំណាយធ្វើទានច្រើនហួសចំណូលធម្មតា នឹងនាំឲ្យលេចលង់ខ្លួនក្នុងសេចក្ដីក្រីក្រលំបាក ។

ខ-បុគ្គលខ្លះ ដោយសេចក្ដីទុកចិត្តគេពេក ក៏ជួយគេជាប្រាក់កាសរាប់ម៉ឺនរៀល ឬក៏យកមាសពេជ្រគ្រឿងអាភរណ៍របស់ខ្លួនទៅបញ្ចាំយកប្រាក់ឲ្យគេខ្ចី ធ្វើដើមទុនរកស៊ី ។ ដល់ថ្ងៃក្រោយមកលុះអ្នកដែលខ្ចីនោះវាអន្តរធានខ្លួន ដោយខាតបង់អស់រលីងក្នុងរបរវា អ្នកម្ចាស់បំណុលក៏ត្រូវធ្លាក់ខ្លួនដូចគ្នាដែរ ។

គ-មានជនខ្លះទោរទន់ចិត្ត ដោយសេចក្ដីអង្វរកររបស់គេ ក៏រ៉ាប់រងធានាគេឲ្យរួចពីទុក្ខទោសណាមួយ មានធានាពីរឿងជំពាក់ប្រាក់ ឬធានាអ្នកដែលជាប់ទោសឲ្យនៅក្រៅឃុំជាដើម ។ គេតែងប្រទះឃើញជនដែលចិត្តល្អឥតពិចារណានេះ ធ្លាក់ខ្លួនទៅជាខ្ញុំកញ្ចះគេ ឬជាប់ឃុំជំនួសគេទៅវិញ ព្រោះម្នាក់នោះភ័យខ្លួនក៏រត់ចោលស្រុកបាត់ទៅ ។

*ន័យរបស់ឃ្លាទីពីរ* : "ចិត្តល្អមិនក្រយូរ"

ពាក្យនេះមានន័យពីរប្រការគឺ :

១-ជនណាដែលក្រពីកំណើតស្រេចទៅហើយ កាលបើកាន់ចិត្តល្អបរិសុទ្ធ សប្បុរសជួយសង្គ្រោះដោះទុក្ខអ្នកដទៃដោយកាយវាចាចិត្ត



www.elibraryofcambodia.org

នោះមិននៅតែក្រអស់មួយជីវិតឡើយ ព្រោះមានអ្នកផងទាំងពួង គេស្រឡាញ់ស្រណោះអាណិតយកទៅចិញ្ចឹមផ្គុំផ្គង ឲ្យមានមុខរបររកស៊ីនឹងគេ ។

មានខ្លះជាបាវព្រាវគេ ប៉ុន្តែដោយនាយចៅហ្វាយសង្កេតឃើញថាជាមនុស្សល្អត្រឹមត្រូវល្មមយកអាសាគេបាន គេក៏ឲ្យរួចជំពាក់ប្រាក់ព្រមទាំងចែកគោក្របី និងដីស្រែ ឲ្យដាំស្រូវយកផលខ្លួនឯង ហើយជួយឧបត្ថម្ភក្នុងការផ្សេងៗទៀត ទាល់តែមានជីវភាពមួយគ្រាន់បើនឹងគេឡើង ។

២ - អ្នកដែលធ្លាប់មានទ្រព្យហើយចិត្តល្អ បើទុកជាធ្លាក់ក្រក៏មិនក្រយូរ ។ ឯក្រនេះគឺដោយអស់ទ្រព្យសម្បត្តិ ឬមានអាសន្នអន្តរាយផ្សេងៗ (ដោយត្រូវភ្លើងឆេះផ្ទះ ចោរប្លន់ជាដើម) ។ ជនជំពូកនេះក្នុងពេលយូរ ឬឆាប់នឹងមានបានឡើងវិញ ឬឆាប់ដកខ្លួនពីអាសន្នណាមួយព្រោះមានគេស្រណោះអាណិតជួយជ្រោមជ្រែងរាល់ៗគ្នា ។

*សីលធម៌របស់ភាសិតទាំងពីរ* (សំរាប់ជាសេចក្តីបញ្ចប់)

ពាក្យទាំងពីរឃ្លា "ចិត្តល្អក្រខ្លួន" និង "ចិត្តល្អមិនក្រយូរ" នេះមានប្រយោជន៍ទាំងអស់ ព្រោះជាគតិណែនាំលោកឲ្យជៀសផុតនូវទុក្ខទោសទាំងឡាយបាន :

ពាក្យទីមួយទូន្មានថា "កុំធ្វើល្អឥតបើគិត" ឬកុំធ្វើល្អហួសប្រមាណ មានខ្លឹមសារប្រហែលគ្នានឹងសុភាសិត ក្នុងច្បាប់កេរ្តិ៍កាល : "សប្បុរសពេកចាញ់ធន" ឬ "សប្បុរសយល់ដោយមុខ ស៊ុតគ្រលុកពេកពុំជា" ។

ពាក្យទីពីរ ទូន្មានថា ឲ្យមានចិត្តល្អបរិសុទ្ធ ដឹងទុក្ខធុរៈអ្នកដទៃ ព្រោះអំពើនេះអាចនឹងទាញខ្លួនឲ្យចាកផុត សេចក្តីក្រីក្រលំបាក ឬ



www.elibraryofcambodia.org

អាសន្នណាមួយបាន ។

" កុំល្អឥតបើគិត កុំមានចិត្តអាក្រក់" នេះហើយជាសុន្ទរោវាទ គឺឱវាទដ៏ប្រពៃដែលត្រូវចងចាំកុំបីភ្លេចឡើយ ។

**៥១-ប្រាក់ក៏បង់ ថង់ក៏ដាច**

## ខំនងតែង

### សេចក្ដីផ្ដើម

គ្រោះថ្នាក់ ទុក្ខទោស សេចក្ដីអកុសល ការបង់ខាតទ្រព្យសម្បត្តិ សុទ្ធតែជាហេតុមិនទៀង វារមែងធ្វើឲ្យមនុស្សលោកធ្លាក់ចុះអាប់ឱនក្នុងសេចក្ដីអន្តរាយជាអនេកកប្បការ ។ ជួនកាលបុគ្គលតែមួយរូបអាចខាតបង់ទ្រព្យធនផ្ទួនៗគ្នាជាហេតុធ្វើឲ្យបុគ្គលនោះពោលដោយខ្នាញ់ថា:" ប្រាក់ក៏បង់ ថង់ក៏ដាច" នេះឯង ។

<u>*អត្ថសេចនៃសុភាសិត*</u> : ភាសិតនេះមានន័យពីរយ៉ាង :

១-"**ប្រាក់ក៏បង់ ថង់ក៏ដាច**" គឺទ្រព្យសម្បត្តិធនធានក៏បាត់បង់វិនាសអន្តរាយ កេរ្តិ៍ឈ្មោះក៏ស្រពោនអាប់ឱនសូន្យទាំងជីវិតក៏មាន ។

២-**ប្រាក់ក៏បង់ ថង់ក៏ដាច** គឺប្រាក់ក៏ខាតបង់អសារឥតការ ទ្រព្យសម្បត្តិដទៃក៏វិនាស អន្តរាយថែមទៅទៀត ។

<u>*ឧទាហរណ៍បញ្ជាក់ន័យទីមួយ*</u>: ១-ជនណាដែលប្ដឹងចោទប្រកាន់ទោសកំហុសនរណាមួយ ហើយដល់ទីបំផុត ត្រូវក្ដីចាញ់គេទៅវិញ ដោយហេតុគូក្ដីម្ខាងប្រសប់ប្រើមធ្យោបាយជាង នោះនឹងឃើញប្រាកដថា" ប្រាក់ក៏បង់ " ព្រោះក្នុងការក្ដីក្ដាំងទាំងឡាយក៏ត្រូវអស់សោហ៊ុយ



www.elibraryofcambodia.org

អាសន្នណាមួយបាន ។

" កុំល្អឥតបើគិត កុំមានចិត្តអាក្រក់ " នេះហើយជាសុន្ទរោវាទ គឺឱវាទដ៏ប្រពៃដែលត្រូវចងចាំកុំបីភ្លេចឡើយ ។

## ៥១-ប្រាក់ក៏បង់ ថង់ក៏ដាច

# ចំនងតែង

## សេចក្តីផ្តើម

គ្រោះថ្នាក់ ទុក្ខទោស សេចក្តីអកុសល ការបង់ខាតទ្រព្យសម្បត្តិសុទ្ធតែជាហេតុមិនទៀង វារមែងធ្វើឲ្យមនុស្សលោកធ្លាក់ចុះអាប់ឱនក្នុងសេចក្តីអន្តរាយជាអនេកកប្បការ ។ ជួនកាលបុគ្គលតែមួយរូបអាចខាតបង់ទ្រព្យធនផ្ទួនៗគ្នាជាហេតុធ្វើឲ្យបុគ្គលនោះពោលដោយខ្នាញ់ថា:" ប្រាក់ក៏បង់ ថង់ក៏ដាច " នេះឯង ។

<u>*អត្ថសេចនៃសុភាសិត*</u> : ភាសិតនេះមានន័យពីរយ៉ាង :

១-"**ប្រាក់ក៏បង់ ថង់ក៏ដាច**" គឺទ្រព្យសម្បត្តិធនធានក៏បាត់បង់វិនាសអន្តរាយ កេរ្តិ៍ឈ្មោះក៏ស្រពោនអាប់ឱនសូន្យទាំងជីវិតក៏មាន ។

២-**ប្រាក់ក៏បង់ ថង់ក៏ដាច** គឺប្រាក់ក៏ខាតបង់អសារឥតការ ទ្រព្យសម្បត្តិដទៃក៏វិនាស អន្តរាយថែមទៅទៀត ។

<u>*ឧទាហរណ៍បញ្ជាក់ន័យទីមួយ*</u>: ១-ជនណាដែលប្តឹងចោទប្រកាន់ទោសកំហុសនរណាមួយ ហើយដល់ទីបំផុត ត្រូវក្តីចាញ់គេទៅវិញ ដោយហេតុគូក្តីម្ខាងប្រសប់ប្រើមធ្យោបាយជាង នោះនឹងឃើញប្រាកដថា" ប្រាក់ក៏បង់ " ព្រោះក្នុងការក្តីក្តាំងទាំងឡាយក៏ត្រូវអស់សោហ៊ុយ



www.elibraryofcambodia.org

ចាយវាយជាច្រើន មានប្រាក់ប្រដាប់ក្ដីជាដើម ព្រមទាំងខាតពេលធ្វើការរកស៊ីផង ។ កាលបើក្ដីចាញ់ហើយ ក៏កើតនូវសេចក្ដីខ្មាសអៀនអាប់កេរ្ដិ៍ឈ្មោះទៀតស្របគ្នានឹងពាក្យថា"ថង់ក៏ដាច" នោះឯង ។

២-អ្នកណាដែលទិញរបស់អ្វីមួយ ដែលជារបស់ចោរលួចយកមកលក់ឲ្យយ៉ាងថោក នោះកាលបើថ្ងៃក្រោយមកម្ចាស់ទ្រព្យគេស្គាល់ច្បាស់ជារបស់គេនោះ នឹងត្រូវចាប់ថ្នាក់ប្ដឹងផ្ដល់យកទ្រព្យគេទៅវិញតាមផ្លូវច្បាប់ ជាហេតុនាំឲ្យអ្នកដែលទទួលទិញ"បង់ប្រាក់" ឥតប្រយោជន៍ដោយចំណាយទិញរបស់នោះ ព្រមទាំងខាតបង់ក្នុងការក្ដីក្ដាំង ហើយថែមទាំងខូចកេរ្ដិ៍ឈ្មោះដោយគេចោទថា ខ្លួនសមនឹងចោរជួយលាក់បំបាំងអំពើទុច្ចរិតផងក៏មាន ។

៣-មានមាតាបិតាខ្លះ ខ្នះខ្នែងដណ្ដឹងធីតាជាគូភរិយាឲ្យបុត្ររបស់ខ្លួន ។ កូនកម្លោះនោះមិនពេញចិត្តនឹងចង់រៀបអាពាហ៍ពិពាហ៍សោះព្រោះមានទាក់ទាមពីរឿងអ្វីផ្សេងៗ ។ ទោះបីប្រកែកយ៉ាងណាក៏ដោយក៏ឪពុកម្ដាយចេះតែបង្ខំឲ្យរៀបការ ។ ប៉ុន្ដែតមកក៏ឃើញគូស្វាមីភរិយាថ្មីមិនសុខសាន្តនឹងគ្នា មានរឿងហេតុដល់ទៅលែងលះគ្នាទៀតជាហេតុធ្វើឲ្យឃើញថា"ប្រាក់ក៏បង់"ចោលម្សៀតក្នុងកិច្ចរៀបមង្គលការ ព្រមទាំងកេរ្ដិ៍ឈ្មោះដ៏អាប់ឱនបង្កើតនូវសេចក្ដីខ្មាសអាម៉ាសមុខថែមទាំងមានញាតិមិត្តគេបន្ទោសដល់គ្រួសារទាំងមូលផង ។

<u>*ឧទាហរណ៍បញ្ជាក់ន័យទីពីរ*</u> : ១-ឈ្មួញម្នាក់ចំណាយប្រាក់ទិញជ័រទឹកជាច្រើនបំរុងនឹងយកទៅលក់ឯភ្នំពេញ ។ ដោយការដែលធ្វេសប្រហែសពេក ចៃដន្យធ្វើឲ្យឆេះរោងដាក់ជ័រ នាំឲ្យឆេះទាំងផ្ទះរបស់ខ្លួនឯង ហើយក៏ពោលប្រាប់គេឯងថា"ប្រាក់ក៏បង់" ថង់ក៏ដាច" យ៉ាង



www.elibraryofcambodia.org

នេះឯង ។

២-ពាណិជ្ជម្នាក់ បានចំណាយប្រាក់ទិញរថយន្តឈ្នួលកញ្ចាស់មួយ រត់ផ្លូវសៀមរាប កំពង់ធំ ។ តាំងពីចាប់ទិញមក ឡានចេះតែខូចដើរមិនសូវទៀងពេលវេលា ជាហេតុធ្វើឲ្យអ្នកដំណើរធុញទ្រាន់នឹងជិះរថយន្តនេះ ។ ម្ចាស់ឡានខាតបង់ជាច្រើនក្នុងការសែមសមម៉ាស៊ីនចាស់ ព្រមទាំងមិនសូវមានអ្នកជិះទៀតផង "បង់ប្រាក់" ។ ប៉ុណ្ណោះហើយមានថែមទាំងអន្តរាយទាំងរថយន្តទៀត ព្រោះកន្លងមកមួយខែតែកុងប្រហែលបើកទៅបុកស្ពានប្រឡប់ឡានធ្លាក់ក្នុងស្ពានភ្លោះ ជាគ្រោះថ្នាក់យ៉ាងធ្ងន់ដល់ម្ចាស់ឡានដែលជិះក្នុងនោះផង ។ នេះឃើញថាអស់ប្រាក់នឹងទិញឡានហើយ អន្តរាយទាំងឡានទៅទៀត ស្របគ្នានឹងពាក្យថា : "ប្រាក់ក៏បង់ ថង់ក៏ដាច" នេះឯង ។

## សេចក្តីបញ្ចប់

តាមហេតុទាំងអម្បាលម៉ានដែលបានសាធកៈមកហើយនេះ គប្បីជនប្រុសស្រីខ្លាចជាទីបំផុត នូវទុក្ខទោសដែលផ្ទួនៗគ្នាយ៉ាងនេះ ។ សេចក្តីប្រុងប្រយ័ត្ននិងពិចារណាមុនប្រកបកិច្ចការអ្វីអាចធ្វើឲ្យមនុស្សលោកជៀសវាងនូវទុក្ខទោសខ្លះបាន ។



www.elibraryofcambodia.org

## ៥២-ស្រឡាញ់កុំទៅញឹកៗ រឭកសឹមទៅម្តងៗ

## សេចក្តីអធិប្បាយ

ដើម្បីនឹងរក្សាចំណងនៃមិត្តភាព ឲ្យបានរឹងប៉ឹងឋិតថេរចិរកាល លោកអ្នកប្រាជ្ញបានប្រដៅថា "ស្រឡាញ់កុំទៅញឹកៗ រឭកសឹមទៅម្តងៗ" ។

ឯពាក្យក្នុងឃ្លាដំបូង ធ្វើឲ្យយើងងឿងឆ្ងល់ណាស់ ។ តើហេតុដូចម្តេចក៏ចាស់លោកទៅជាប្រដៅថា បើស្រឡាញ់នរណាហើយ កុំទៅលេងញឹកញយពេក បើស្តាប់តែមួយភ្លែតមិនសង្កេតឲ្យឃើញជ្រៅជ្រះពាក្យលោកដូចជាខុស ត្បិតយើងយល់ថា" តែស្រឡាញ់ហើយតោងទៅឲ្យញឹក តែមិនទៅឲ្យញឹកញាប់ គេថាយើងធ្វើព្រងើយកន្តើយមិនសូវគិតទៅគេ" ។ ដែលយើងគិតយ៉ាងដូច្នេះនេះខុសសោះ ព្រោះយើងនៅខ្ចីសេចក្តីពេក ចាស់ៗលោកបានស្គាល់ការពិសោធន៍ជាច្រើនមកហើយ លោកឈ្វេងយល់នូវកិច្ចការល្អអាក្រក់គ្រប់ជំពូក លោកពិនិត្យឃើញថា បើយើងទៅលេងនឹងសំឡាញ់យើងញឹកៗ ពេកទៅមិនលែងថ្ងៃណាមួយសំឡាញ់យើងនឹងធុញទ្រាន់ជិនឆ្អន់នឹងយើង ដោយគេខាតពេលវេលានឹងទទួលយើង ហើយមិនឈ្នះនឹងធ្វើបដិសណ្ឋារៈ ចំពោះយើងរាល់ៗថ្ងៃផង ។ បើយើងនឹងទៅលេងនឹងគេម្តង នោះគេរៀបទទួលដោយស្មោះ ហើយសប្បាយរីករាយនឹងយើងផង បើថ្ងៃស្អែកយើងទៅទៀត គេទទួលយើងមិនដល់ថ្ងៃមុនទេ តែបើព្រឹកទៅល្ងាចទៅរាល់ទិនទិវារាត្រីនោះ គេលែងទាំងដាក់ស្លាបារីហៅអង្គុយកៅអីផង ជួនកាលបើគេមិនចង់ជួបនឹងយើង គេពួនក្នុងបន្ទប់ ហើយប្រាប់បាវព្រាវគេឲ្យ



www.elibraryofcambodia.org

កុហកយើងថា ម្ចាស់ផ្ទះទៅឯណោះបាត់ទៅហើយក៏មាន គេលះបង់សេចក្តីរាប់អានអស់ទៅ ។ មានអ្នកខ្លះទៀត មិនត្រឹមតែស្អប់យើង គេថែមទាំងពេបជ្រាយ និយាយដើមយើងប្រាប់ញាតិជិតខាងផង ។

បើគិតឲ្យល្អិតល្អន់វែងឆ្ងាយជាងនេះ យើងយល់ទៀតថាតែយើងទៅលេងផ្ទះសំឡាញ់យើង ឬផ្ទះខាងយើងញឹកៗញយៗពេកទៅ លុះពេលណាគ្មានរឿងអ្វីនឹងសំណេះសំណាលលេង ក៏តាំងចាប់ផ្តើមពីរឿងនេះរឿងនោះលេង ខ្លះមែនខ្លះជាមិនខាន ជួនកាលរឿងនោះ ធ្វើឲ្យគេស្គាល់គំនិតមារយាទអាក្រក់របស់យើង រឿងខ្លះធ្វើឲ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ។ បើជួនជាសំដីដែលចេញពីមាត់យើងទៅ វាមិនគប្បីផងនោះនឹងកើតជារឿងរ៉ាវវែងឆ្ងាយនាំឲ្យសៅហ្មងដល់ខ្លួនឥតប្រយោជន៍ ។

ក្នុងឃ្លាទីពីរ លោកប្រដៅយើងថា "បើរពួកសឹមទៅម្តងៗ" ។ធម្មតាចិត្តសំឡាញ់ក្តី ឬអ្នកជិតខាងយើងក្តី បើយូរៗយើងទៅលេងទៅជួបនឹងគេម្តង គេមុខជានឹងមានសេចក្តីត្រេកអរសាទរមាត់រួសរាយហៅរកដាក់ស្លាបារី លើកកៅអីមកឲ្យអង្គុយដោយគួរសមសួរសុខទុក្ខពីស្រុកស្រែ ហើយមានសេចក្តីមេត្រីបដិសណ្ឋារៈរាប់អានយើងណាស់ ជួនកាលគេឃាត់ឲ្យបាយទឹកឲ្យនៅលេងនឹងគេបានពីរឬបីថ្ងៃផង ត្បិតគេរពួកយើងដោយមិនសូវបានជួបនឹងយើងជាយូរថ្ងៃណាស់មកហើយ ។

មានរឿងមួយដំណាលថា ៖ គ្រូបង្រៀនពីរនាក់ជាកល្យាណមិត្តជិតដិតស្និទ្ធស្នាលនឹងគ្នាអស់ពីចិត្ត ។ គ្រូទាំងពីរធ្វើការក្នុងខេត្តផ្សេងពីគ្នា ហើយតែមានចិត្តរពួកគ្នាជាប្រក្រតី ត្បិតក្នុងមួយឆ្នាំ បានជួបគ្នាតែម្តង គឺនៅពេលដែលរាជការប្រជុំគ្រូទៅរាជធានី ដើម្បីពិនិត្យកែសេចក្តីដែល



www.elibraryofcambodia.org

សិស្សប្រឡងវិញ្ញាបនប័ត្របឋមសិក្សា ។ កាលបើបានជួបគ្នាម្តងៗ គ្រូទាំងពីរនេះរាក់ទាក់រកគ្នាអស់ពីចិត្ត ។ លុះកន្លងមួយឆ្នាំមក គ្រូទាំងពីរក៏ត្រូវរាជការផ្លាស់ឲ្យទៅធ្វើការ នៅរាជធានីតាមសេចក្តីសុំ ។ ឯគ្រូទីមួយមានភរិយាហើយ ចំណែកគ្រូទីពីរនៅលីវនៅឡើយ ។ គ្រូកម្លោះតែងទៅលេងផ្ទះគ្រូ ដែលមានប្រពន្ធជារាល់ថ្ងៃ ជួនកាលនៅបាយទឹកដេកលេងពីរឬបីថ្ងៃទើបត្រឡប់ទៅផ្ទះវិញ ។ ដល់ទៅមកញឹកញាប់ពេកទៅប្រពន្ធលោកគ្រូទីមួយ ក៏ធុញទ្រាន់មិនឈ្នះរៀបបាយរៀបទឹក ខ្មើយមុង កន្ទេលទទួល ហើយក៏មានចិត្តស្អប់រអ៊ូរទាំលំអុកឲ្យប្តី ជួនកាលធ្វើមុខកញ្ចប់កញ្ចាវចងចិញ្ចើមដាក់គ្រូកម្លោះ មិនបានប៉ុន្មានខែផង គ្រូដែលមានប្រពន្ធ ដោយមិនឈ្នះទ្រាំនឹងពាក្យសំដីដុកដាន់ឌឺដងរបស់ភរិយាក៏មានចិត្តធុញទ្រាន់នឹងមិត្ត ហើយបែកចិត្តឈប់រាប់អានជិតដិតនឹងមិត្តសម្លាញ់ទៅ ។ តាំងពីនោះមកគ្រូកម្លោះ ដោយរអៀសខ្លួនពេកក៏លែងទៅមករាប់រកមិត្តចាស់លែងទាំងជាន់ផ្ទះសម្បែងទៀតផង ។

ចូរយើងស្តាប់រឿងនេះចុះ តើហេតុដូចម្តេចក៏មិត្តទាំងពីរដែលពីដើមរួមចិត្តមួយ ឥឡូវទៅជាសត្រូវនឹងគ្នា? នេះហើយរឿងហេតុដែលបណ្តាលពី "ស្រឡាញ់ទៅញឹកៗពេក" ។

✧✧ចប់✧✧



www.elibraryofcambodia.org

មានលក់ដុំ និងរាយ

តូបសៀវភៅសិក្សាគ្រប់មុខវិជ្ជា

បារាំង ចិន ខ្មែរ ថៃ ជប៉ុន កូរ៉េ វៀតណាម

ចំរៀងខារ៉ាអូខេ រឿងដោយរូបភាព

សៀវភៅខ្មែរ និងសៀវភៅទី ២

១. តូបលេខ 20+21+22+ & 77

☎ 012 862 018 012 646 881

២. តូបលេខ 68 ផ្សារថ្មី

☎ 012 863 315


www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្មៅ យុនសំរ៉ង ខ្មៅ យ៉ាតណៃ ខ្មៅសុខផល ខ្មៅ វិសាល ខ្មៅ វ៉ាមុន ខ្មៅ ភាភាដា ខ្មៅ ចំរើន ខ្មៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក **ខ្មៅ ពាញ** និង ឧបាសិកា **ឈរ យឿន**

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

## មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **ទាវ បញ្ញា**

កញ្ញា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ករុណាខ្មែរ

ផ្តល់ការ ដោះទុក្ខ ក្តីសង្ឃឹម

ខ្មៅ យុនសំរ៉ង

ប្រធាន

CAMBODIAN • EDUCATION • EXCELLENCE

មូលនិធិខ្មែរសម្រាប់ការសិក្សា

FOUNDATION

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org



# គីន ប៊ុនថន

មានលក់ដុំ និង លក់រាយនូវសៀវភៅសិក្សាគ្រប់មុខវិជ្ជា

បារាំង ចិន ខ្មែរ ថៃ អង់គ្លេស ជប៉ុន កូរ៉េ វៀតណាម

ចំរៀង KARAOKE រឿងដោយរូបភាព សៀវភៅធម៌ ខលខ

**ពិសេសមានលក់គម្ពីរព្រះត្រៃបិតក**

1. តូបលេខ 20 +21+22 ផ្សារអូរឫស្សី

ជាន់ឡៅតឿប៉ែកខាងកើត

ទូរស័ព្ទ : 012 862 018 ឬ 012 646 881

2. តូបលេខ 68 ផ្សារធំថ្មី ទូរស័ព្ទ : 012 863 315

អរគុណ !

www.elibraryofcambodia.org